សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
Universités Royal de Droit et des Sciences Economiques
Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីដីធ្លី
# កម្មសិទ្ធិឯកជននៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ម៉ែន ពេញបូរមី**
ក. **ខៀវ សុផាត់សន**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ទូរ សុខុម៉ា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ម៉ែន ពេញបូរមី** និងក.**ខៀវ សុផាត់សន** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៤ ជំនាន់ទី ១៣ ឆ្នាំសិក្សា ២០១៩-២០២០។ ជាដំបូង ខ្ញុំសូមលំឱនកាយក្រាបប្រណិប័តន និងសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះមាតាបិតាទាំងបួនរូបៈ

លោកឪពុក **ម៉ែន សារុន** អ្នកម្តាយ **កែវ សុវណ្ណា**

លោកឪពុក **ខៀវ ចាន់ម៉ាច** អ្នកម្តាយ **ជុន សុខសាន**

ដែលលោកបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកនោះឡើយ និងបានឲ្យកូនរៀនសូត្រមានចំណេះដឹង រហូតបញ្ចប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈដោយជោគជ័យ។ គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងបួន ដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។

+ សូមគោរពថ្លែងអំណរអរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលា ទាំងកម្លាំងកាយ កម្លាំងចិត្ត និងយកចិត្តទុកដាក់ បង្ហាត់បង្រៀនដល់យើងខ្ញុំទាំងពីររូប ក៏ដូចជាមិត្តនិស្សិតផ្សេងៗទៀត ដោយពុំគិតគូរពីភាពលំបាកនឿយហត់អ្វីឡើយ ផ្ទុយទៅវិញលោកខិតខំដាស់តឿន ទូន្មាន អប់រំសិស្សនិស្សិតឲ្យខិតខំសិក្សារៀនសូត្រ ស្វែងរកចំណេះវិជ្ជាមកដាក់ក្នុងខ្លួន និងពង្រឹងខ្លួនឯងធ្វើយ៉ាងណាឲ្យក្លាយជាមនុស្សម្នាក់ដែលមានសមត្ថភាពពេញលេញដែលសង្គមគេត្រូវការជាដើម។

+ ជាពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ បណ្ឌិត **ទូរ សុខម៉ា** ដែលជាសាស្ត្រាចារ្យណែនាំយើងខ្ញុំទាំងពីរនាក់ ដែលតែងតែផ្តល់នូវគន្លឹះ ទ្រឹស្តី និងការអនុវត្តក្នុងការស្វែងយល់លើប្រធានបទរបស់យើងខ្ញុំ សាស្ត្រាចារ្យមិនដែលរអ៊ូរទាំ ឬមានភាពធុញទ្រាន់ចំពោះការផ្តល់ចំណេះដឹង គំនិតយោបល់អ្វីឡើយ បើទោះបីជាមានការហត់នឿយក្នុងការបំពេញការងារយ៉ាងណាក្តី ក៏សាស្ត្រាចារ្យនៅតែផ្តល់ស្នាមញញឹម ហើយសប្បាយចិត្តពេលដែលបានឃើញសិស្ស និស្សិតខំសិក្សាស្រាវជ្រាវរាល់ឯកសារនានា ដែលពាក់ព័ន្ធនឹងប្រធានបទ។ សាស្ត្រាចារ្យព្យាយាមពន្យល់ណែនាំ និងប្រាប់នូវបទពិសោធន៍ល្អៗ ដើម្បីធ្វើឱ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយភាពជោគជ័យ។

\+ លើសពីនេះទៅទៀតសូមថ្លែងអំណរគុណដល់លោកប្រធាន អនុប្រធាន ថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិកទាំងអស់ នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានចុះសិក្សាស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងសារណានេះ។ ជាពិសេសលោក **សៀង ជៀវ** ដែលបានផ្តល់យោបល់ និងផ្តល់ឯកសារចាំបាច់ដល់ខ្ញុំទាំងពីរសម្រាប់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទដែលស្តីអំពី ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា ដើម្បីឲ្យការតាក់តែងសារណាមួយនេះប្រព្រឹត្តទៅដោយជោគជ័យ។

\+ ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរឱ្យលោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងមិត្តនិស្សិតទាំងអស់ ឱ្យមានសុខភាពល្អ សម្រេចបានគ្រប់កិច្ចការ និងសូមឲ្យសមប្រកបជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីក្លាយជាបការៈដទៃឡើយ។

# អារម្ភកថា

អស់រយៈពេលបួនឆ្នាំកន្លងមកនេះ ដែលបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដោយសិក្សារៀនសូត្រ និងស្រាវជ្រាវដោយយកចិត្តទុកដាក់ ហើយបានសរសេរសារណាបញ្ចប់ឆ្នាំសិក្សា។ រយៈពេលនៃការសិក្សាបួនឆ្នាំក្នុងការសិក្សាបរិញ្ញាបត្ររដ្ឋបាសាធារណៈ ក្រៅពីការណែនាំ អប់រំទូន្មានប្រៀនប្រដៅ ពីសំណាក់លោកឪពុកអ្នកម្តាយ ដែលជាគ្រូដំបូងរបស់យើងខ្ញុំ ដែលបានផ្តល់នូវការដាស់តឿនបង្ហាត់បង្រៀន បង្ហាញផ្លូវល្អ ហើយយើងខ្ញុំពិតជាមានសំណាងដែលបានមកសិក្សាបន្តនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលជាសាកលវិទ្យាល័យមួយដែលយើងខ្ញុំប៉ងប្រាថ្នាពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិ យើងខ្ញុំនឹងបន្តមកសិក្សានៅទីនេះ ឥឡូវបំណងរបស់យើងខ្ញុំក៏បានសម្រេច ហើយពិតជាមានភ័ព្វសំណាងណាស់ដែលបានជួបសាស្រ្តាចារ្យដែលមានចំណេះដឹង បទពិសោធន៍ ក្រមសីលធម៌ ក្នុងការបង្ហាត់បង្រៀន ផ្ទេរនូវចំណេះដឹង ចែករំលែក និងដាស់តឿនឱ្យខំសិក្សា រហូតដល់ថ្ងៃសរសេរសារណាដើម្បីបញ្ចប់ការសិក្សានៅទីនេះ។

ការលើកយកប្រធានបទដែលស្តីអំពី ការចុះបញ្ជីដីកម្មសិទ្ធិឯកជននៅកម្ពុជា មកធ្វើការសិក្សាស្រាវជ្រាវចងក្រងជាសារណា គឺដោយសារយើងខ្ញុំចង់ដឹងពីរបៀបរបប និងនីតិវិធីនៃការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា ក៏ដូចជាចង់ដឹងនូវបញ្ហាប្រឈមដែលតែងតែកើតមានឡើង នៅក្នុងការអនុវត្តការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា។ សារណាមួយនេះ គឺជាស្នាដៃដ៏តូចមួយដែលកកើតឡើងពីការស្វែងរកស្រាវជ្រាវដោយយកចិត្តទុកដាក់ វាបានកើតចេញពីការព្យាយាមយ៉ាងស្វិតស្វាញ និងការខិតខំប្រឹងប្រែងបំផុត អស់ពីកម្លាំងកាយចិត្តដែលបានបន្សល់ស្នាដៃមួយនេះឡើងដើម្បីទុកជាឯកសារសម្រាប់មិត្តនិស្សិតជំនាន់ក្រោយៗទៀត។ ទោះបីជាខ្លឹមសារនៅក្នុងសារណានេះមានការពិនិត្យយ៉ាងល្អិតល្អន់ យកចិត្តទុកដាក់យ៉ាងណាក្តី យើងខ្ញុំគិតថាសារណាមួយនេះពិតជានៅមានភាពខ្វះចន្លោះជាក់ជាមិនខានទាំងអត្ថន័យ អត្ថរស ភាពខុសឆ្គង អក្ខរាវិរុទ្ធដោយអចេតនា ឬការភ្លេចភ្លាំងខ្លះជាក់ជាមិនខានឡើយដោយសារសមត្ថភាពនៃការសិក្សា ស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត។ តែទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំទាំងពីរនាក់សូមទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនា ពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ មិត្តអ្នកអាន និស្សិត ទាំងអស់គ្នាដើម្បីឱ្យការសិក្សាស្រាវជ្រាវក្រោយទៀតកាន់តែមានភាពសុក្រិត និងល្អប្រសើរឡើងហើយទទួលបានអត្ថប្រយោជន៍ច្រើនដល់អ្នកអាន និងមិត្តនិស្សិតជំនាន់ក្រោយៗទៀត។ សូមមេត្តាអធ្យាស្រ័យចំពោះចំណុចខ្វះខាតដែលកើតមានឡើងហេតុនេះហើយយើងខ្ញុំសូមការអភ័យទោសពីសំណាក់អ្នកអានទាំងអស់គ្នាដោយក្តីអនុគ្រោះផង។ សូមអរគុណ !!

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


**១. លំនាំបញ្ហានៃការស្រាវជ្រាវ** .......... ១

**២.ចំណោទបញ្ហានៃការស្រាវជ្រាវ** .......... ២

**៣. គោលបំណងនៃការស្រាវជ្រាវ** .......... ២

**៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ** .......... ៣

**៥. សារៈសំខាន់នៃការស្រាវជ្រាវ** .......... ៣

**៦. វិធីសាស្ត្រនៃការស្រាវជ្រាវ** .......... ៤

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** .......... ៦


## ជំពូក ១

## បទដ្ឋានគតិយុត្តក្នុងការចុះបញ្ជីដីកម្មសិទ្ធិឯកជន


**១.១. សញ្ញាណទូទៅនៃការការពារសិទ្ធិលើដីធ្លី** .......... ៧

**១.២. ច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី** .......... ៨

១.២.១. ឋានានុក្រមនៃច្បាប់ .......... ៨

១.២.២. បទដ្ឋានគតិយុត្តក្រោមច្បាប់ .......... ១០

**១.៣. ប្រវត្តិអចលនទ្រព្យក្នុងការចុះបញ្ជី** .......... ១១

**១.៤. លក្ខខណ្ឌទទួលបានការចុះបញ្ជី** .......... ១៣

១.៤.១. សន្តតិកម្ម .......... ១៣

១.៤.២. ការលក់ទិញ .......... ១៤

# ជំពូក ២

# ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជន

**២.១. ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីដីធ្លី** ........ ១៦

២.១.១. រចនាសម្ព័ន្ធគណៈកម្មការសុរិយោដី ........ ១៦

២.១.២. តួនាទី និងភារកិច្ចរបស់អង្គភាពទទួលបន្ទុក ........ ១៧

**២.២. នីតិវិធីរដ្ឋបាលនៃការចុះបញ្ជីដីធ្លី** ........ ១៨

២.២.១. ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ........ ១៨

២.២.១.១. សេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ........ ១៨

២.២.២ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ........ ២៤

២.២.២.១ សេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ........ ២៥

**២.៣. សកម្មភាពចុះបញ្ជីដីបំពេញបន្ថែម** ........ ៣១

២.៣.១. គោលបំណង និងភាពចាំបាច់ ........ ៣២

២.៣.២. លក្ខខណ្ឌដែលតម្រូវឲ្យមានការចុះបញ្ជីដីបំពេញបន្ថែម ........ ៣២

២.៣.៣. សេវានៃការចុះបញ្ជីដីបំពេញបន្ថែម ........ ៣៣

**២.៤ ប្រភេទនៃវិវាទដីធ្លី** ........ ៣៤

២.៤.១. សភាពនៃវិវាទដីធ្លី ........ ៣៥

២.៤.២. វិវាទក្នុងកំឡុងពេលវាស់វែង ........ ៣៥

២.៤.៣. វិវាទទាក់ទងនឹងទិន្នន័យនៃការវិនិច្ឆ័យ ........ ៣៦

**២.៥. យន្តការដោះស្រាយវិវាទដីធ្លី** ........ ៣៦

២.៥.១. ការដោះស្រាយដោយគណៈកម្មការសុរិយោដីចំពោះដីមិនទាន់ចុះបញ្ជី ........ ៣៧

២.៥.១.១. ក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៣៧

២.៥.១.២. គណៈកម្មការរដ្ឋបាល ........ ៣៧

២.៥.១.៣. គណៈកម្មការសុរិយោដី ........ ៣៨

២.៥.២. ការដោះស្រាយដោយស្ថាប័នតុលាការ ចំពោះដីចុះបញ្ជីរួច ........ ៤២

## ជំពូក ៣

## លទ្ធភាព និងការវិភាគ

**៣.១. លទ្ធផលនៃការពិភាក្សាការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ** ........ ៤៤

**៣.២. លទ្ធផលនៃការពិភាក្សាការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ** ........ ៤៥

**៣.៣. ចំណុចខ្លាំង និងចំណុចខ្សោយនៃការចុះបញ្ជីដីធ្លី** ........ ៤៦

៣.៣.១. ចំណុចខ្លាំង ........ ៤៦

៣.៣.២. ចំណុចខ្សោយ ........ ៤៨

សេចក្ដីសន្និដ្ឋាន ........ ៥១

អនុសាសន៍

គន្ថនិទ្ទេស

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

កម្មសិទ្ធិឯកជននៅក្នុងប្រទេសកម្ពុជា ត្រូវបានទទួលស្គាល់ជាបណ្តើរៗឆ្នាំ១៩៨៩និងក្រោយមកទៀត កាន់តែមានលក្ខណៈទូលំទូលាយច្រើន ពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់។ ច្បាប់ភូមិបាល បានកំណត់ច្បាស់លាស់អំពីលក្ខណៈនៃកម្មសិទ្ធិក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាសិទ្ធិមួយចំនួនទៀតរបស់អ្នកដែលនឹងក្លាយជាកម្មសិទ្ធិករ។ លើសពីនេះពេលដែលក្រមរដ្ឋប្បវេណីត្រូវបានដាក់ឲ្យប្រើប្រាស់ បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិលើកម្មសិទ្ធិនៅកម្ពុជាកាន់តែមានភាពច្បាស់លាស់ហើយលក្ខណៈនៃកម្មសិទ្ធិមួយចំនួនទៀត ក៏កាន់តែមានភាពល្អប្រសើរដល់អ្នកដែលនឹងទទួលបានសិទ្ធិជាកម្មសិទ្ធិករ។ ក្នុងនោះផងដែរ យើងសង្កេតឃើញថា សិទ្ធិលើកម្មសិទ្ធិនៃដីធ្លីនៅកម្ពុជាបាននឹងកំពុងបង្ហាញនូវភាពប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ស្របពេលដែលប្រជាពលរដ្ឋគ្រប់ៗរូបបានយល់ជ្រាបកាន់តែច្បាស់ពីសិទ្ធិ ករណីយកិច្ច និងកាតព្វកិច្ចរបស់ខ្លួន ដើម្បីរួមចំណែកការអភិវឌ្ឍនៅក្នុងសង្គម។ ទោះបីជាមានការរីកដុះដាល់ក៏ពិតមែន ក៏ប៉ុន្តែបញ្ហាដីធ្លីក៏នៅតែឃើញមានការកើតឡើងជាបន្តបន្ទាប់រហូតមកដល់ពេលបច្ចុប្បន្ននេះ។ ដោយសារតែបញ្ហាដូចមានការរៀបរាប់ខាងលើទើបបណ្តាលឲ្យយើងខ្ញុំ សម្រេចចិត្តក្នុងការជ្រើសយកប្រធានបទដែលស្តីពី ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា ដើម្បីជាសញ្ញាណដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយយល់បានកាន់តែស៊ីជម្រៅបន្ថែមទៀតទៅលើទិដ្ឋភាពច្បាប់ និងនីតិវិធីរបស់ស្ថាប័នពាក់ព័ន្ធដែលមានភារកិច្ចក្នុងការចុះបញ្ជីដីធ្លីនៅកម្ពុជានាពេលបច្ចុប្បន្ន ព្រមទាំងដើម្បីចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាផងដែរ។ តាមរយៈប្រធានបទខាងលើនេះ យើងខ្ញុំមានការសង្ឃឹមយ៉ាងមុតមាំថាវាពិតណាស់នឹងជួយចូលរួមចំណែកក្នុងការបញ្ជ្រាបការយល់ដឹងរបស់ សិស្ស និស្សិត និងប្រជាពលរដ្ឋកម្ពុជា ក្នុងការផ្តល់ជាពុទ្ធិថ្មីមួយសម្រាប់ប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃអោយកាន់តែមានភាពងាយស្រួលទៅថ្ងៃអនាគត។ ប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជាទាំងមូល ដើម្បីបង្កើនការយល់អោយកាន់តែច្បាស់អំពី តួនាទី កាតព្វកិច្ច និងភារកិច្ចក្នុងការចូលរួមចុះបញ្ជី និងស្នើសុំចុះបញ្ជី ទាំងដីសាធារណៈ និងដីឯកជនជាពិសេស គឺផ្តោតទៅលើការចុះបញ្ជីដីកម្មសិទ្ធិឯកជននៅកម្ពុជា ដោយតម្រូវអោយមានការសិក្សាស្រាវជ្រាវអោយលំអិតទៅលើប្រធានបទមួយនេះ ដើម្បីអោយមាននៅភាពងាយស្រួលក្នុងយល់ពីខ្លឹមសារយល់ន័យសេចក្តី បំបាត់ចោលនូវភាពការភ័យព្រួយ ការភ័យខ្លាចការគាបសង្កត់ ដោយបង្ករជាភាពងាយស្រួលយល់ដឹងពីបញ្ហានៃវិវាទព្រំប្រទល់ដីធ្លី និងដើម្បីឆ្លើយតបទៅនឹងបញ្ហាចោទមួយចំនួនជុំវិញការចុះបញ្ជីដីធ្លីនៅកម្ពុជារួចចាប់ផ្តើមធ្វើការស្វែងរកដំណោះស្រាយរាល់បញ្ហាផ្សេងៗទៀតដែលកើតមាន ក្នុងគោលបំណងបង្កើនប្រសិទ្ធិភាព និងលទ្ធផលខ្ពស់នៃការចុះបញ្ជីដីធ្លីឱ្យប្រព្រឹត្តិទៅដោយស្មើភាពគ្នា សមភាព សាមគ្គីភាព នៅក្នុងសង្គម។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្តែកទៅលើលំនាំបញ្ហាដែលមាននៅខាងលើ ដោយយើងខ្ញុំធ្វើការសិក្សាស្រាវទៅលើការចុះបញ្ជីដីធ្លីដើម្បីចង់យល់ដឹងថា ឧបសគ្គដែលប្រឈមក្នុងការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជនកម្ពុជាទាំងការចុះបញ្ជីដីធ្លីទាំងពីរប្រព័ន្ធ ហើយតើក្រសួងស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធត្រូវធ្វើយ៉ាងណាដើម្បីឲ្យការចុះបញ្ជីដីធ្លីមានប្រសិទ្ធិភាពដែលអាចបម្រើផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋ ដែលជាម្ចាស់កម្មសិទ្ធិករស្របច្បាប់។ ដើម្បីសម្រេចនូវគោលបំណង យើងបានដាក់ចេញនូវសំណួរចោទសួរលើនីតិវិធីនៃការចុះបញ្ជីដីកម្មសិទ្ធិឯកជនដូចខាងក្រោមនេះ៖

១. តើអ្វីដែលជាឧបសគ្គប្រឈមនៅក្នុងការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា ?

២. តើធ្វើយ៉ាងណា ដើម្បីឲ្យការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជនមានប្រសិទ្ធភាពសម្រាប់ការកាន់កាប់ស្របច្បាប់ ?

៣. តើប្រជាពលរដ្ឋកម្ពុជា ទទួលបានសិទ្ធិអ្វីខ្លះលើកម្មសិទ្ធិក្រោយពីដីធ្លីរបស់ខ្លួនបានចុះបញ្ជីរួច ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងដូចខាងក្រោម៖

១). ស្វែងយល់ពីការទទួលបាននូវសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លី ព្រមទាំងនីតិវិធីរដ្ឋបាលនៃការចុះបញ្ជីដីកម្មសិទ្ធិឯកជននៅក្នុងប្រទេសកម្ពុជាឲ្យបានស៊ីជម្រៅ និងយល់កាន់តែច្បាស់អំពីកាតព្វកិច្ច និងភារកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការត្រៀមរៀបចំខ្លួនមុនពេលចុះបញ្ជី កំឡុងពេលចុះបញ្ជី និងក្រោយពេលចុះបញ្ជីដោយធ្វើយ៉ាងណាកុំអោយមានការខ្វែងគំនិតគ្នា ឬមានទំនាស់ដីធ្លីកើតឡើងរវាងភាគីនៃម្ចាស់ព្រំដី និងភាគីអ្នកជាប់ព្រំដី ពោលគឺត្រូវចេះយោគយល់គ្នាទៅវិញទៅមកមុនពេលដែល អាជ្ញាធរមានសមត្ថកិច្ចក្នុងមូលដ្ឋានអនុវត្តន៍តាមពេលវេលាកំណត់ជាក់លាក់ណាមួយ។

២). ធ្វើការកំណត់និងតាមដានពីការអនុវត្តការងាររបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋចាប់តាំងពីថ្ងៃបិទប្រកាសជាសាធារណៈនូវកាលបរិច្ឆេទនៃការចុះវាស់វែងដីធ្លី រហូតដល់ថ្ងៃប្រកាសជាសាធារណៈនូវការផ្តល់វិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុជូនដល់ប្រជាពលរដ្ឋដែលជាកម្មសិទ្ធិករនៃដីធ្លីនោះ។

៣). សិក្សាពីដែនកំណត់ ឥទ្ធិពល និងអានុភាពនៃអចលនវត្ថុក្រោយពីទទួលបានការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី សិទ្ធិនៃការចាត់ចែង បែងចែករបស់កម្មសិទ្ធិករលើអចលនវត្ថុក្រោយការចុះបញ្ជី។

៤). ទុកជាឯកសារសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ក៏ដូចជាអ្នកសិក្សាទូទៅ យកទៅពង្រឹងពុទ្ធិរបស់ពួកគេបន្ថែមទៀតដើម្បីយល់អោយកាន់តែច្បាស់ពីការចុះបញ្ជីដីធ្លីនៅកម្ពុជា ហើយត្រៀមខ្លួនក្នុងការចូលរួមអនុវត្តន៍រួមគ្នាជាមួយប្រជាពលរដ្ឋក្នុងតំបន់ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចក្នុងមូលដ្ឋាន ដើម្បីឲ្យដំណើរការនេះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

សារណានេះគ្របដណ្តប់លើ ការចុះបញ្ជីដីកម្មសិទ្ធិឯកជននាពេលបច្ចុប្បន្ន។ ការសិក្សាស្រាវជ្រាវនេះបានផ្តោះទៅលើនីតិវិធីច្បាប់ដែលមានស្រាប់ដូចជា៖

(១). ក្រមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ( ជំពូក៣ អំពី សិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ត្រង់មាត្រា ៤៤ )។

(២). ក្រមរដ្ឋប្បវេណី នៃព្រះរាជជាណាចក្រកម្ពុជា ឆ្នាំ២០០១ ( គន្ថីទី២ ជំពូក១ រូបវន្តបុគ្គល ផ្នែកទី១ អំពី សមត្ថភាពទទួលបានសិទ្ធិ ត្រង់មាត្រា៩ កថាខណ្ឌ៣, គន្ថីទី៥ ជំពូកទី១ ការទិញលក់ ផ្នែកទី១ លក្ខណៈនៃការលក់ និងការបង្កើតកិច្ចសន្យាលក់ទិញ ត្រង់មាត្រា ៥១៥ និងមាត្រា ៥១៦, គន្ថីទី ៨ ជំពូកទី១ ផ្នែកទី១ ការចាប់ផ្តើមធ្វើសន្តតិកម្ម ត្រង់មាត្រា ១៤៤៥ ដល់មាត្រា ១៤៤៧ )។

(៣). ច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១ ។

(៤). ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សារាចរ ព្រមទាំងសេចក្តីណែនាំបន្ថែមរបស់រាជរដ្ឋាភិបាល ក្នុងការជួយជម្រុញការអនុវត្តការងាររបស់អាជ្ញាធរសុរិយោដី។

ចំពោះដែនកំណត់នៃការសិក្សាស្រាវជ្រាវ គឺយើងខ្ញុំជ្រើសយករាជធានីភ្នំពេញជាទីតាំងដើម្បីលើកយកមកសិក្សាស្វែងយល់ឲ្យកាន់តែបានស៊ីជម្រៅក្នុងប្រធានបទមួយនេះ ហើយក្រុមរបស់យើងខ្ញុំសម្រេចចិត្តថា និងធ្វើការចុះស្រង់និងប្រមូលទិន្នន័យនៅក្នុងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីធ្វើឲ្យសារណាមួយនេះកាន់តែមានភាពស៊ីជម្រៅថែមទៀត។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

**សារៈសំខាន់ចំពោះសង្គម៖** កាត់បន្ថយនូវវិវាទរវាងម្ចាស់កម្មសិទ្ធិដីធ្លី ឬប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់របស់ខ្លួន ជួយបញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋ ដើម្បីទទួលបានសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួនស្របទៅតាមច្បាប់កំណត់ ដោយពុំមានបង្ករជាបញ្ហា ឬក៏វិវាទដែលកើតឡើងជាយថាហេតុក្នុងកំឡុងពេលនៃការកាន់កាប់ដីធ្លីរបស់ខ្លួនស្របពេលដែលមានការចុះបញ្ជីដីធ្លីដែលស្ថិតនៅក្នុងតំបន់។

**សារៈសំខាន់ចំពោះអាជ្ញាធរ៖** ផ្តល់ភាពងាយស្រួលដល់អាជ្ញាធរក្នុងការកាត់សេចក្តី ទាក់ទងនិងវិវាទដីធ្លី កាលណាមានវិវាទកើតឡើងក្នុងកំឡុងពេលអនុវត្តន៍ការងាររបស់ខ្លួន ដោយវាផ្តល់ជាសញ្ញាណ ឬមូលដ្ឋានគ្រឹះ ដែលគាំទ្រដល់អាជ្ញាធរដើម្បីមានភាពងាយស្រួលសម្រាប់ដោះស្រាយ ហើយវាក៏អាចក្លាយជាឯកសារបន្ថែមចំណេះដឹងបន្តិចបន្តួចទៅដល់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការជួយក្រើនរំលឹកគំនិត ស្មារតី របស់អាជ្ញាធរផងដែរ។ លើសពីនេះទៅទៀត វាក៏ផ្តល់ភាពងាយស្រួលដល់អាជ្ញាធរ ក្នុងការកំណត់ប្រភេទដី ការប្រើប្រាស់ដីក្នុងមូលដ្ឋាន ឬការដោះដូរម្ចាស់កម្មសិទ្ធិ តាមរយៈមតកសាសន៍ការលក់ដូរនិងតាមរយៈការជួលជាអចិន្ត្រៃយ៍។

**សារៈសំខាន់ចំពោះស្ថាប័នជាតិ៖** ចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានីខេត្ត គឺអាចទទួលបាននូវព័ត៌មានទូលំទូលាយ អំពីស្ថាប័នអាជ្ញាធរមានសមត្ថកិច្ចក្នុងការអនុវត្តការងារចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ ថាតើការអនុវត្តការងារល្អដល់កម្រិតណា? តើមានការគំរាមគំហែង ឬបង្ខិតបង្ខំ ស៊ីសំណូកសូកប៉ាន់ដែរឬទេ? ដោយទទួលបានតាមរយៈអ្នកដែលទទួលសេវា ឬប្រជាពលរដ្ឋតាមរយៈទូរសារឬលិខិតដែលយើងខ្ញុំបានធ្វើការចុះស្រាវជ្រាវនិងជួបផ្ទាល់ជាមួយប្រជាពលលរដ្ឋនៅក្នុងតំបន់ដែលទទួលបានការវិនិច្ឆ័យវាស់វែងនោះ។

**សារៈសំខាន់ចំពោះខ្លួនឯង៖** បង្កើនការយល់ដឹងកាន់តែច្បាស់អំពីនីតិវិធីតាមផ្លូវច្បាប់ ការងាររដ្ឋបាល និងជាពិសេសបញ្ចប់ការសិក្សាដោយទទួលបាននូវភាពជោគជ័យក្នុងជីវិត។

ចំពោះយើងខ្ញុំផ្ទាល់ កិច្ចការមួយនេះបានពង្រឹង ពង្រីកចំណេះដឹង និងការស្រង់យកបទពិសោធន៍ថ្មីៗជាច្រើនតាមរយៈការរុករកនូវឯកសារស្រាវជ្រាវ ការប្រមូលផ្តុំឯកសាររូបភាពជាច្រើនដូចជា ការចុះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញដោយផ្ទាល់ក្នុងការសុំកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីសម្ភាសន៍ក្នុងគោលបំណងប្រមូលនូវទិន្នន័យ ឯកសារ ព័ត៌មានដែលមានប្រភពច្បាស់លាស់ និងជាក់ស្តែង ដើម្បីចងក្រងជាសារណាមួយនេះឡើងមក។

លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវមួយនេះបានផ្តល់នូវពុទ្ធិ និងភាពវៃឆ្លាតក្នុងការទាញយកប្រភពព័ត៌មាន លិខិតបទដ្ឋានគតិយុត្តិនានា ខ្លឹមសារច្បាប់សំខាន់ៗ ព្រមទាំងសម្រង់ប្រសាសន៍របស់ថ្នាក់ដឹកនាំជាដើម។ ជារួមសារៈសំខាន់ចម្បងនៃការសិក្សាស្រាវជ្រាវនេះ គឺបង្កើនសមត្ថភាពរបស់យើងខ្ញុំផ្ទាល់ទៅលើបច្ចុប្បន្នភាពនៃការចុះបញ្ជីដីកម្មសិទ្ធិឯកជនតែម្តង ក៏ដូចជាការស៊ើបសួរព័ត៌មានបន្ថែមទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដែលចូលរួមក្នុងដំណើរប្រតិបត្តិការណ៍ការចុះបញ្ជីដីធ្លីនេះផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវលើប្រធានបទនេះ មានលក្ខណៈវិទ្យាសាស្ត្រ និងមានកម្រិតនៃការជឿជាក់ខ្ពស់ ដោយផ្អែកលើទិន្នន័យ និងការវិភាគទិន្នន័យ។ ដើម្បីធ្វើការកំណត់ទិសដៅស្វែងរកទិន្នន័យ យើងចាំបាច់ណាស់ត្រូវកំណត់អថេរជាមុនសិន ដែលអថេរមានពីរគឺ អថេរឯករាជ្យ និងអថេរមិនឯករាជ្យ។

អថេរឯករាជ្យសំដៅលើច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា៖

+ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
+ សន្ធិសញ្ញាអន្តរជាតិ
+ ព្រះរាជក្រឹត្យ
+ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

+ ច្បាប់ភូមិបាលឆ្នាំ ២០០១
+ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

អថេរមិនឯករាជ្យ ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា។

**ការប្រមូលទិន្នន័យ**

កិច្ចការស្រាវជ្រាវមួយនេះ ត្រូវបានរៀបចំចងក្រងឡើងដោយឆ្លងកាត់នូវដំណាក់កាលចំនួនពីរគឺៈ

ដំណាក់កាលទី១ ៖ ស្វែងរកអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលមានស្រាប់ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណារបណ្ណាល័យធំៗ វេបសាយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមរយៈហ្វេសប៊ុកផេករបស់សមាគមន៍សាលាត្រាជូរ សមាគមន៍អ្នកច្បាប់ខ្មែរ និងតាមរយៈគេហទំព័រយូធូបជាដើម។

ដំណាក់កាលទី២ ៖ ចុះប្រមូលទិន្នន័យតាមបែបគុណវិស័យដោយធ្វើបទសម្ភាសន៍ផ្ទាល់មាត់ជាមួយលោក សៀង ជៀវ ( អតីតប្រធានលេខាធិការដ្ឋាន គណៈកម្មការសុរិយោដីរាជធានីភ្នំពេញ បច្ចុប្បន្នជាមន្ត្រីជាប់កិច្ចសន្យា ធ្វើការនៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីរាជធានីភ្នំពេញ ) ដែលជាសាស្ត្រាចារ្យដឹកនាំក្នុងការសាកសួរព័ត៌មានអំពីព័ត៌មានដែលទាក់ទងនឹងការចុះបញ្ជីដូចជា ការត្រៀមខ្លួនមុនពេលចុះបញ្ជីដី ដំណើរការនៃការចុះបញ្ជីដីធ្លី ដំណើរការដោះស្រាយវិវាទដីធ្លី បញ្ហាប្រឈមដែលអាចនឹងកើតមាន លក្ខខណ្ឌដែលទទួលបានការចុះបញ្ជី និងគោលការណ៍របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានីខេត្ត នឹងធ្វើការសាកសួរជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការនុវត្តការងារចុះបញ្ជីដីដើម្បីបង្កើនការយល់ដឹងបន្ថែមអំពី ការងារជាក់ស្តែងរបស់មន្ត្រីក្នុងការវាស់វែងដីធ្លី។

**ការវិភាគទិន្នន័យ**

ទិន្នន័យដែលប្រមូលបានមក បានវិភាគតាមបែបពិពណ៌នា និងប្រៀបធៀបការអនុវត្តជាក់ស្តែងជាមួយនឹងបទដ្ឋានគតិយុត្តដែលមានចែងនៅក្នុងច្បាប់ ថាតើមានលក្ខណៈខុសគ្នា ឬក៏ដូចគ្នាបែបណា? ការអនុវត្តរបស់មន្ត្រីទទួលបន្ទុកធ្វើបានក្នុងកម្រិតណា? មានបញ្ហាអ្វីខ្លះដែលប៉ះពាល់ដល់មន្ត្រី ឬប្រជាពលរដ្ឋក្នុងពេលចុះវាស់វែង? មានផលប្រយោជន៍អ្វីខ្លះដល់ប្រជាពលរដ្ឋក្រោយការចុះវាស់វែង? ស្វែងរកគុណសម្បត្តិ និងគុណវិបត្តិ ចំណុចខ្លាំង ឬចំណុចខ្សោយនៃការអនុវត្តការងារចុះបញ្ជីដីធ្លី រួចធ្វើការចង្អុលបង្ហាញពីចំណុចខ្វះខាត ដើម្បីកែប្រែនូវកំហុសខុសឆ្គង ភាពខ្វះខាតដើម្បីឲ្យការអនុវត្តការងារប្រព្រឹត្តិទៅដោយរលូន។ យើងខ្ញុំក៏នឹងធ្វើការវិភាគលើដំណើការការនៃការចុះបញ្ជីដីធ្លីទាំងពីរប្រព័ន្ធផងដែរ ថាតើវាមានការខុសគ្នាយ៉ាងណាខ្លះចំពោះដំណើរការចុះបញ្ជី ព្រមទាំងចំណុចខ្លាំងនឹងចំណុចខ្សោយនៃការចុះបញ្ជីដីធ្លីទៀតផង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រោយពីបានពិភាក្សាក្រុម និងការស្វែងរកប្រភពឯកសារពាក់ព័ន្ធនានារួចមក យើងបានសម្រេចបែងចែករចនាសម្ព័ន្ធស្រាវជ្រាវជា ១ កថាខណ្ឌ និង ៣ ជំពូកដូចខាងក្រោម៖

កថាខណ្ឌទី១ សេចក្តីផ្តើម ដែលបរិយាយអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវគោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវវិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី១៖ បទដ្ឋានគតិយុត្តិក្នុងការចុះបញ្ជីដីកម្មសិទ្ធិឯកជន ដែលសិក្សាទៅលើ ច្បាប់នឹងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ប្រវត្តិនៃការចុះបញ្ជីដី និងលក្ខខណ្ឌទទួលបានការចុះបញ្ជី ។

ជំពូកទី២៖ ការចុះបញ្ជីដីធ្លីកម្មសិទ្ធឯកជន ដែលធ្វើការសិក្សាទៅលើ រចនាសម្ព័ន្ធរបស់ស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជី នីតិរដ្ឋបាលនៃការចុះបញ្ជីដីធ្លី យន្តការដោះស្រាយវិវាទដីធ្លីក្នុងពេលចុះបញ្ជី។

ជំពូកទី ៣៖ លទ្ធភាព និងវិភាគ ដែលធ្វើការសិក្សាទៅលើការចុះបញ្ជីដីធ្លីទាំងពីរប្រព័ន្ធ ទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃការចុះបញ្ជីដីធ្លី។

សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖ ធ្វើការសន្និដ្ឋានលើគ្រប់ចំណុច និងផ្តល់ជាអនុសាសន៍បន្តិចបន្តួចទៅលើចំណុចដែលខ្វះខាត ដើម្បីឲ្យមានការកែសម្រួលនឹងបណ្តុះជាកូនគំនិតមួយដែលអាចក្រើនរំឭកស្មារតីដល់អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការចុះបញ្ជីដីធ្លី។

# ជំពូក ១
# បទដ្ឋានគតិយុត្ត
# ក្នុងការចុះបញ្ជីដីកម្មសិទ្ធិឯកជន

# ជំពូក ១

# បទដ្ឋានគតិយុត្តក្នុងការចុះបញ្ជីដីកម្មសិទ្ធិឯកជន

## ១.១. សញ្ញាណទូទៅនៃការការពារសិទ្ធិលើដីធ្លី

ដី គឺជាវត្ថុមានតម្លៃនិងមិនអាចខ្វះបានសម្រាប់ប្រជាកសិករខ្មែរយើង ជាពិសេសគឺនៅតាមជនបទ។ មនុស្សប្រើប្រាស់ដីដើម្បីទាញយកផលិតផលកសិកម្ម តាំងពីយូរយាណាស់មកហើយក្នុងការចិញ្ចឹមជីវិត និងភាពសុខដុមរមនានៃសហគមន៍ដែលពួកគេបានរស់នៅទាំងមូល។ ជាទូទៅការគ្រប់គ្រង និងការប្រើប្រាស់ដីផ្អែកជាចម្បងលើការប្រើប្រាស់ជាក់ស្តែងសម្រាប់បម្រើផលិតកម្ម ហើយការទទួលស្គាល់ និងការអនុវត្តសិទ្ធិនេះត្រូវបានគោរពទៅតាមទំនៀមទម្លាប់ប្រពៃណីតំបន់នីមួយៗ។ ប៉ុន្តែក្រោយពីមានការបើកទូលាយខាងសេដ្ឋកិច្ចមក ដីត្រូវបានគេប្រើប្រាស់បន្តិចម្តងៗ សម្រាប់ពាណិជ្ជកម្ម ជាហេតុធ្វើឲ្យតម្លៃនៃដីធ្លីកើនឡើងបន្តិចម្តងៗរហូតមកដល់សព្វថ្ងៃនេះ។សិទ្ធិប្រើប្រាស់ និងគ្រប់គ្រងលើដីធ្លីកាន់តែផ្អែកច្រើនឡើងៗទៅលើមធ្យោបាយខាងផ្លូវច្បាប់ ព្រោះគេយល់ថាច្បាប់ផ្តល់នូវការការពារសិទ្ធិលើដីធ្លីមួយរឹងមាំល្អជាងការការពារដោយផ្អែកលើទំនៀមទម្លាប់ប្រពៃណី។

មនុស្សគ្រប់ៗរូប ក៏អាចស្វែងរកការការពារអចលនវត្ថុ(សំដៅដល់ដីធ្លី) របស់ខ្លួនផងដែរតាមរយៈអាជ្ញាធរឬស្ថាប័នដែលពាក់ព័ន្ធដើម្បីមានវិធានការការពារនឹងនីតិវិធីផ្សេងៗទៀតដើម្បីការពារវត្ថុទាំងនោះឲ្យមានសុវត្ថិភាព គ្មានការភ័យខ្លាចពីការបាត់បង់ ឬរំលោភបំពានឡើយ។ ការការពារដីធ្លី ត្រូវបានគេធ្វើឡើងក្រោមរូបភាពជាការចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺការចុះបញ្ជីដើម្បីសម្គាល់ភាពជាម្ចាស់កម្មសិទ្ធិនៃដីធ្លី ដែលបានកាន់កាប់ដីត្រឹមត្រូវតាមការកំណត់របស់ច្បាប់។

ជាទូទៅកម្មសិទ្ធិដីធ្លីត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជីក៏ពិតមែន ប៉ុន្តែវាក៏មានការប្រែប្រួល និងវិវត្តន៍ទៅតាមពេលវេលានៃបរិបទសង្គមនីមួយៗផងដែរ។ ដោយមើលឃើញពីបញ្ហានេះ ព្រះរាជាណាចក្រកម្ពុជាក៏មានច្បាប់ជាច្រើន និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែរ ដែលបានចងក្រងឡើងដើម្បី ធ្វើការការពារក្នុងការផ្តល់សិទ្ធិលើកម្មសិទ្ធិដីធ្លីជូនដល់ប្រជាពលរដ្ឋ និងការពារសិទ្ធិរបស់បុគ្គល ឬប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសផងដែរ។ នៅក្នុងជំពូកនេះ យើងនឹងធ្វើការសិក្សាទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងដែលមានតាមឋានានុក្រមនៃច្បាប់ និងបទដ្ឋានគតិយុត្តក្រោមច្បាប់ផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជា ដែលចងក្រងឡើង ដើម្បីបកស្រាយអំពីការផ្តល់កម្មសិទ្ធិដីធ្លី និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ការសិក្សាពីប្រវត្តិអចលនទ្រព្យក្នុងការចុះបញ្ជី លក្ខខណ្ឌដែលអាចធ្វើការចុះបញ្ជី នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីដីធ្លី ការដោះស្រាយវិវាទផងដែរ ដែលកើតមានឡើងនៅក្នុងសង្គម។

## ១.២. ច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី

ច្បាប់ និងបទបញ្ញត្តិជាច្រើនបានចែងអំពីសិទ្ធិក្នុងការកាន់កាប់ដីធ្លីស្របច្បាប់របស់ប្រជាពលរដ្ឋកម្ពុជា។ខាងក្រោមនេះ យើងនិងសិក្សាបន្ថែមទៅលើច្បាប់ និងលិខិតបទប្បញ្ញត្តិដែលមានការពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់នៅកម្ពុជា ដែលមានដូចទៅនេះ ៖

### ១.២.១. ឋានានុក្រមនៃច្បាប់

ឋានានុក្រមច្បាប់នៅកម្ពុជា គឺមានតាមលំដាប់លំដោយចាប់ពីកម្រិតខ្ពស់បំផុតរហូតដល់កម្រិតទាបបំផុត។ រដ្ឋធម្មនុញ្ញនៃព្រះរាជានៃចក្រកម្ពុជា គឺជាច្បាប់កំពូលនៅក្នុងប្រទេសកម្ពុជា។ រាល់ច្បាប់ ឯកសារគតិយុត្ត និងសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋទាំងឡាយត្រូវតែអនុលោមទៅតាមច្បាប់។

#### ក. ក្រមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ [១]

រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាន់នូវរបបប្រជាធិបតេយ្យដែលបង្កើតឡើងលើកដំបូងនៅក្នុងឆ្នាំ១៩៤៧មកម្ល៉េះ។ បច្ចុប្បន្ននេះ កម្ពុជាកំពុងប្រើប្រាស់រដ្ឋធម្មនុញ្ញលើកទី៦ ដែលត្រូវបានអនុម័ត ដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ហើយត្រូវបានអតីតព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលមាន១៦ ជំពូក និង១៥៨មាត្រា។ សព្វថ្ងៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានវិសោធនកម្មមានចំនួន៦លើកមកហើយ ដែលមាន១៧ជំពូក និង១៦០មាត្រា។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើការធានានូវសិទ្ធិសេរីភាពជាម្ចាស់នៃកម្មសិទ្ធិលើដីធ្លីជូនប្រជាពលរដ្ឋដែលធានាបាននូវការមិនត្រូវបានរំលោភបំពាន ដោយបុគ្គលណា ឬក្រុមអង្គការរដ្ឋណាទេ។

បើយើងក្រឡេកទៅមើល ក្រមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងយ៉ាងច្បាស់លាស់ផងដែរទាក់ទងនឹងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ មិនត្រូវបានរំលោភបំពាន ការផ្តល់សិទ្ធិឲ្យស្មើៗគ្នានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ជំពូកទី៣ មាត្រា៤៤ ត្រង់កថាខណ្ឌទី១រឹតតែបានបញ្ជាក់យ៉ាងច្បាស់លាស់អំពីភាពជាម្ចាស់នៃកម្មសិទ្ធិគឺ ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់នៃកម្មសិទ្ធិដីធ្លី។ រដ្ឋធម្មនុញ្ញការពារសិទ្ធិមានកម្មសិទ្ធិឯកជនលើអចលនវត្ថុ និងនាំឲ្យសិទ្ធិប្រជាពលរដ្ឋក្នុងការមានកម្មសិទ្ធិឯកជនត្រូវបានការពារយ៉ាងរឹងមាំថែមទៀត។ កម្ពុជាបានក្លាយជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនដែលការពារសិទ្ធិមានកម្មសិទ្ធិឯកជនរួមមាន សិទ្ធិមាននិវេសនដ្ឋានសមរម្យ និងមិនទទួលការដកហូតតាមអំពើចិត្ត សិទ្ធិមានអាហារ

[១] **ក្រមរដ្ឋធម្មនុញ្ញ** នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ហូបចុកគ្រប់គ្រាន់ សិទ្ធិធ្វើការងារ សិទ្ធិខាងសុខភាព សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងការជួបជុំ និងសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព[២]។

**ខ. ច្បាប់ភូមិបាល ឆ្នាំ២០០១** [៣]

មុនច្បាប់ភូមិបាល ចូលជាធរមាន ប្រជាបលរដ្ឋកម្ពុជា ទទួលបានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលប្រជាពលរដ្ឋខ្មែរនិយមហៅថា ប័ណ្ណស្លាបមាន់ ឬងសន្លឹកដែលចេញដោយអាជ្ញាធរខេត្តក្រុង មុនច្បាប់ភូមិបាលចូលជាធរមាន។ ច្បាប់ភូមិបាលឆ្នាំ២០០១ ដែលផ្អែកទាំងស្រុងលើរដ្ឋធម្មនុញ្ញនិងលើមូលដ្ឋាននៃការប្រែប្រួលនៃរបបកម្មសិទ្ធិលើដីធ្លី និងស្ថានភាពជាក់ស្តែងនៃការកាន់កាប់ដីធ្លីបានចែងបញ្ជាក់នៅក្នុងមាត្រា៦ថា មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលនាំឲ្យបានកម្មសិទ្ធិ។ រដ្ឋក៏អាចផ្តល់កម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុដែលជារបស់រដ្ឋក្នុងព្រំដែនជាក់លាក់ដែលបានកំណត់ដោយច្បាប់នេះ ដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសញ្ញាតិខ្មែរ។ ចំពោះលទ្ធកម្មនៃកម្មសិទ្ធិច្បាប់នេះបញ្ជាក់ថា ភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ១៩៨៩ អាចបង្កើតជាពិសេសនូវភណ្ឌិកលើអចលនវត្ថុ និងនាំទៅដល់លទ្ធកម្មនៃកម្មសិទ្ធិដោយអ្នកកាន់កាប់ទ្រព្យក្នុងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ។

តាមមាត្រា៣៨ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដគ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានការអាក់ខាន និងដោយសុច្ចរិត។ ជារួមភោគៈស្របច្បាប់ដែលនឹងក្លាយជាកម្មសិទ្ធិបាន គឺភោគៈស្របតាមលក្ខខណ្ឌទាំងប្រាំខាងលើ កើតឡើងនៅមុនច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន នៅលើដីដែលមិនមែនជាចំណែកដីសាធារណៈរបស់រដ្ឋនិងអនុវត្តបានយ៉ាងតិចប្រាំឆ្នាំ។ មាត្រា២២៦ នៃច្បាប់ភូមិបាលឆ្នាំ២០០១ កម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាដោយរដ្ឋ។ តាមគោលដៅនេះ រដ្ឋបាលសុរិយោដី ក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចធ្វើអត្តសញ្ញាណកម្មទ្រព្យ កសាងប្លង់សុរិយោដី ចេញប័ណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទ ទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗដែលអាចមាននៅលើក្បាលដីនោះ។ ច្បាប់នេះក៏បានបែងចែងចែកអំពីលទ្ធកម្មនៃកម្មសិទ្ធិ អំពីកម្មសិទ្ធិឯកជន កម្មសិទ្ធិសាធារណៈ អំពីប្រភេទនិងទម្រង់ផ្សេងៗនៃកម្មសិទ្ធិ។ល។ ដែលមួយភាគធំទាក់ទងនឹងនីតិឯកជនហើយត្រូវបញ្ចូលនិងចែងលម្អិតនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

---

[២] សេចក្តីប្រកាសជាសកល **ស្តីពីសិទ្ធិមនុស្ស** ត្រូវបានអនុម័ត និងប្រកាសដោយសេចក្តីសម្រេចចិត្ត នៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ២១៧ A ( III ) នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

[៣] គោលនយោបាយដីធ្លី **សៀវភៅសដីធ្លី** ទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ( ទំព័រទី៦ និង៧ )។

**គ. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧** [៤]

ក្រមរដ្ឋប្បវេណី ដែលជាច្បាប់មូលដ្ឋានក្នុងការកំណត់គោលការណ៍ទូទៅនៃទំនាក់ទំនងគតិយុត្ត ផ្នែករដ្ឋប្បវេណី ទំនាក់ទំនងជាមួយទ្រព្យសម្បត្តិ ទំនាក់ទំនងញាតិ ត្រូវបានអនុម័តនៅឆ្នាំ២០០៧ និងត្រូវបានចាប់ផ្តើមអនុម័តនៅខែធ្នូ ឆ្នាំ២០១១។ ដូច្នេះ ផ្នែកពាក់ព័ន្ធនឹងសិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលលើអចលនទ្រព្យ ដែលមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានអនុវត្តន៍ទៅតាមបញ្ញត្តិដែលមានចែងលម្អិតក្នុងក្រមរដ្ឋប្បវេណីវិញ។ ទោះជាយ៉ាងណាក៏ដោយទាំងពីរនេះរក្សាអត្ថន័យនៃការគ្រប់គ្រងអលនវត្ថុដែលធ្លាប់បានអនុវត្តពីមុនមក ដោយកំណត់ឲ្យមានការចុះបញ្ជីអចលនវត្ថុក្នុងសៀវភៅគោលបញ្ជីដីធ្លី។

នៅព្រះរាជាណាចក្រកម្ពុជាការគ្រប់គ្រងដីធ្លី ឬរដ្ឋបាលដីធ្លី ត្រូវបានអនុវត្តតាមប្រព័ន្ធចុះបញ្ជីក្បាលដីក្នុងសៀវភៅគោលបញ្ជីដីធ្លីនិងប្លង់សុរិយោដីនៅរដ្ឋបាលសុរិយោដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្នុងន័យនេះ ពិតមែនតែមាត្រា១៣៣ នៃក្រមរដ្ឋប្បវេណីបានចែងថា ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាពតាមការព្រមព្រៀងរវាងភាគី ប៉ុន្តែមាត្រា១៣៤ បានចែងថា កាបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ ក្រៅពីសិទ្ធិកាន់កាប់ សិទ្ធិឃាត់ទុក សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានចុះបញ្ជីសិទ្ធិនោះតាមបញ្ញត្តិនៃច្បាប់ឬបទដ្ឋានគតិយុត្តផ្សេងដែលទាក់ទងនឹងការចុះបញ្ជី ហើយជាពិសេសមាត្រា១៣៥នៃក្រមនេះបានចែងបញ្ជាក់ថា ទោះបីមានបញ្ញត្តិនៃមាត្រា១៣៣(ការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) និងមាត្រា១៣៤( លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ) នៃក្រមនេះក៏ដោយក៏ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មិនមានអានុភាពបើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់និងបទដ្ឋនគតិយុត្តផ្សេងទៀតស្តីពីការចុះបញ្ជី។

**១.២.២. បទដ្ឋានគតិយុត្តក្រោមច្បាប់**

លិខិតបទដ្ឋានក្រោមច្បាប់ គឺជាអត្ថបទច្បាប់ បទបញ្ជា លិខិតស្នាម ដែលមានចេញដោយស្ថាប័ន ឬក្រសួងមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងទំនាក់ទំនងគ្នាក្នុងផលប្រយោជន៍សាធារណៈឲ្យមានសន្តិសុខសុខុមាលភាពប្រជាជន ទំនាក់ទំនងការទូត និងការពារជាតិ។ នៅឆ្នាំ២០០១ អង្គនីតិបញ្ញត្តិបានអនុម័តច្បាប់ភូមិបាលដែលតម្រូវឲ្យបង្កើតរដ្ឋបាលសុរិយោដីដែលស្ថិតក្រោមក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។ ក្នុងនោះផងដែរ យើងក៏សង្កេតឃើញមាន អនុក្រឹត្យ សេចក្តីប្រកាស និងសេចក្តីជូនដំណឹងជាច្រើនដែលទាក់

[៤] គោលនយោបាយដីធ្លី **សៀវភៅសដីធ្លី** ទទួលបានការឯកភាពពីគណៈរដ្ឋមន្រ្តីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៥ ( ទំព័រទី៧ និង៨ )។

ទងនឹងដីធ្លីត្រូវបានចេញដោយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងស្ថាប័នដែលពាក់ព័ន្ធ សម្រាប់ការធានានូវភាពប្រក្រតីនៃការកាន់កាប់ដីធ្លី សិទ្ធិលើដីធ្លី ការការពារស្របច្បាប់របស់កម្មសិទ្ធិករ។ អនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, អនុក្រឹត្យលេខ៤៨ អនក្រ/បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, គោលនយោបាយដីធ្លី សៀវភៅសដីធ្លី ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៥, សេចក្តីណែនាំលេខ១១ សណន ស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី, សារាចរណែនាំ លេខ០០១ ដនស/សជ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី នឹងសៀវភៅគោលបញ្ជីដីធ្លី ប្រកាស សារាចរ សេចក្តីណែនាំ ជាច្រើនទៀតដែលលិខិតបទដ្ឋានគតិយុត្តទាំងនេះមានគោលដៅនឹងគោលបំណងនឹងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ សុខសុវត្ថិភាព ធានាឱ្យមាននូវការកាន់កាប់ដីធ្លីស្របច្បាប់របស់ប្រជាពលរដ្ឋ ការទទួលបាននូវការការពារដីធ្លីទាក់ទងនឹងការចុះបញ្ជីដីធ្លី ការបកស្រាយបង្ហាញពីរបៀបរបបនៃការចុះបញ្ជីដីធ្លី ពោលគឺធានាឱ្យបាននូវសមភាព យុត្តិធម៌សាមគ្គីភាពនៅក្នុងសង្គមសម្រាប់ប្រជាជនកម្ពុជាទាំងមូល។

## ១.៣. ប្រវត្តិអចលនទ្រព្យក្នុងការចុះបញ្ជី

អចលនវត្ថុសំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាច ផ្លាស់ប្តូរ ទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។ ប៉ុន្តែនៅក្នុងន័យនេះ អចលនវត្ថុដែលយើងធ្វើការផ្តោតជាសំខាន់ជាងគេគឺ ដីធ្លី។ មាត្រា៨ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ មានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតក្រោមការគាំពារនៃច្បាប់។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជាគឺពលរដ្ឋខ្មែរទាំងអស់សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជា ដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល ។ ជនបរទេសដែលក្លែងបន្លំ សញ្ជាតិដើម្បីឱ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជា នឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា២៥១ នៃច្បាប់ភូមិបាល។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋដោយគ្មានផ្តល់ជាសំណងឡើយ។

មាត្រា៧នៃច្បាប់ភូមិបាលឆ្នាំ២០០១បានចែងថា របបកម្មសិទ្ធិមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់ទេ។ នៅក្រោយឆ្នាំ១៩៧៩ ប្រជាពលរដ្ឋខ្មែរដែលបានចូលកាន់កាប់ដីធ្លីភាគច្រើនសុទ្ធតែគ្មានប័ណ្ណកម្មសិទ្ធិ នេះជាមូលហេតុបណ្តាលឲ្យកើតមានវិវាទដីធ្លីជាញឹកញាប់។ នៅឆ្នាំ១៩៨៩ រដ្ឋបានសម្រេចចិត្តផ្តល់កម្មសិទ្ធិឯកជនលើដីធ្លីដល់ប្រជាពលរដ្ឋ។ មេគ្រួសារដែលបានកាន់កាប់ដីធ្លី ត្រូវបានដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លីមកគណៈ

កម្មាធិការប្រជាជនស្រុក តាមរយៈឃុំដែលកំពុងរស់នៅតាមគម្រូបែបបទដែលក្រសួងកសិកម្មបោះពុម្ពចែកជូន[៥]។ រដ្ឋបានកំណត់ទំហំដីសម្រាប់ការកាន់កាប់ដោយកំណត់ដីលំនៅដ្ឋានមានទំហំត្រឹមតែ២.០០០ម$^{២}$ និងដីផលិតកម្មកសិកម្មមិនលើសពី ៥ហិកតា។

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តច្បាប់ភូមិបាលថ្មីមួយ គឺច្បាប់ភូមិបាលឆ្នាំ១៩៩២។ តាមរយៈច្បាប់នេះកម្មសិទ្ធិដីធ្លីឯកជននៅមានលក្ខណៈតូចចង្អៀតចង្អល់នៅឡើយ កម្មវត្ថុតែមួយគត់នៃកម្មសិទ្ធិដីធ្លីឯកជន គឺដីលំនៅដ្ឋាន[៦]។ ច្បាប់ភូមិបាលបានបង្កើតឲ្យមានការចុះបញ្ជីកម្មសិទ្ធិ ការចុះបញ្ជីភោគៈ និងការចុះចរន្តការផ្ទេរ ឬបំបែកក្បាលដីជាដើមការចុះបញ្ជីនេះត្រូវកត់ត្រាចូលសៀវភៅពីរផ្សេងគ្នា។ ចំពោះកម្មសិទ្ធិត្រូវចុះក្នុងសៀវភៅចុះបញ្ជីកម្មិសិទ្ធិអចលនវត្ថុ រីឯភោគៈត្រូវចុះក្នុងសៀវភៅភោគៈអចលនវត្ថុ។ រាល់ការធ្វើចរន្តការក៏ត្រូវចុះទៅតាម ប្រភេទកម្មសិទ្ធិ និងភោគៈដែរ ពោលគឺ ការធ្វើចរន្តការផ្ទេរកម្មសិទ្ធិត្រូវចុះក្នុងសៀវភៅចុះកម្មសិទ្ធិអចលនវត្ថុហើយការផ្ទេរភោគៈត្រូវកត់ត្រាចូលសៀវភៅចុះភោគៈអចលនវត្ថុ[៧]។ លុះដល់ឆ្នាំ ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើសហប្រតិបត្តិការបច្ចេកទេសភាគីជាមួយបណ្តាប្រទេសជឿនលឿនមួយចំនួនសំដៅបញ្ចូលបណ្តើរៗ នូវបច្ចេកទេសទំនើបលើការសាងសង់ប្លង់សុរិយោដីក្នុងការចុះបញ្ជីដីធ្លីលើការកាន់កាប់ទុកដាក់ឯកសារសុរិយោដី និងជាពិសេសការគ្រប់គ្រងប្រព័ន្ធទិន្នន័យ (Database Management System) អនុវត្តដោយ នាយកដ្ឋានសុរិយោដី និងអង្គការហ្វីនីមេផ ( FINIMAP)នៅខេត្តតាកែវ និងជាមួយប្រទេសបារាំងតាមគ្រោងកសាងផែនទី (Cadastral Mapping Project)អនុវត្តដោយមន្ទីរសុរិយោដីភ្នំពេញ និងអង្គការអាយជីអិន អែហ្វអាយ ( IGN.FI ) នៅរាជធានីភ្នំពេញ[៨]។ នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ច្បាប់ភូមិបាលថ្មីត្រូវបានប្រកាសឲ្យប្រើ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពនៃការអភិវឌ្ឍរបស់សង្គម។ ច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ បានបញ្ញត្តិបង្កើតឲ្យមានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងលក្ខណៈដាច់ដោយដុំនៅក្នុងប្រទេសកម្ពុជា។ នៅដើមឆ្នាំ២០០២ដោយមានការគាំទ្រពីប្រទេសម្ចាស់ជំនួយ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើចំណាត់ថ្នាក់ដីរដ្ឋ និងចាប់ផ្តើមចុះបញ្ជីក្បាលដីទាំងអស់ជូនដល់ប្រជាពលរដ្ឋ ដោយអនុលោមទៅតាមច្បាប់ភូមិបាលឆ្នាំ២០០១។ ការចុះបញ្ជីដីនេះធ្វើឡើង ក្នុងគោលបំណងបំបាត់ភាពមិនច្បាស់លាស់ជាម្ចាស់កម្មសិទ្ធិលើដី ដែលបានបង្កឡើងឱ្យមានទំនាស់ឥតឈប់ឈរ និងការចេញប័ណ្ណកម្មសិទ្ធិជូនដល់ប្រជាពលរដ្ឋ។

[៥] សេចក្តីណែនាំស្តីពី **ការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី**,លេខ០៣សណន,០៣ មិថុនា ១៩៨៩,ចំណុចទី២(តទៅហៅថា សេចក្តីណែនាំលេខ០៣)។

[៦] ច្បាប់ភូមិបាល ឆ្នាំ១៩៩២, មាត្រា១៩។

[៧] ច្បាប់ភូមិបាល ឆ្នាំ១៩៩២, មាត្រា២០៥ ដល់មាត្រា២០៨។

[៨] ហាប់ផល្លី, បញ្ហានានាពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា(១២.០៧.២០១០)។

## ១.៤. លក្ខខណ្ឌទទួលបានការចុះបញ្ជី

ដើម្បីធ្វើការស្នើសុំចុះបញ្ជីដីធ្លី ឬទទួលសេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីលក្ខណៈដាច់ដោយដុំឲ្យបាន ប្រជាពលរដ្ឋដែលជាម្ចាស់នៃកម្មសិទ្ធិលើដីធ្លី ត្រូវចូលរួមសហការទាំអស់គ្នាជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជម្រុញឲ្យការងារចុះបញ្ជីនេះអនុវត្តន៍ទៅដោយរលូន និងឆាប់រហ័ស។ ក្នុងនោះផងដែរ ប្រជាពលរដ្ឋជាម្ចាស់ដី មានភារកិច្ចសំខាន់ក្នុងការចូលរួមបំពេញកាតព្វកិច្ចជាប្រជាពលរដ្ឋ ដោយតម្រូវឲ្យត្រៀមខ្លួនរួចជាស្រេច នូវរាល់សំណុំឯកសារនានាដែលពាក់ព័ន្ធនឹងដីធ្លីរបស់ខ្លួន ដើម្បីបង្ហាញ ផ្ទៀងផ្ទាត់ និងប្រគល់ជូនដល់គណៈកម្មការសុរិយោដីធ្វើការពិនិត្យ និងសាកសួររាល់សំណួរផ្សេងៗអំពីដីធ្លីរបស់ខ្លួនក្នុងកំឡុងពេលធ្វើការវាស់វែងកំណត់ព្រំដី។

សំណុំឯកសារសំខាន់ៗដែលតម្រូវឲ្យមាននៅក្នុងកំឡុងពេលនៃការចុះបញ្ជីដីធ្លីមាន៖(១)សំបុត្របញ្ជាក់កំណើត (២)អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (៣)សៀវភៅគ្រួសារ (៤)សៀវភៅស្នាក់នៅ (៥)សំបុត្រអាពាហ៍ពិពាហ៍ (៦)បណ្តាំមរតក (៧)សាលក្រម ឬសាលដីការតុលាការ លិខិតទិញ ឬលក់អចលនវត្ថុ។ ប៉ុន្តែប្រសិនបើប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលគណៈកម្មការបានធ្វើការវាស់វែងរួច មិនទាន់បានចុះបញ្ជីដីធ្លីរបស់ខ្លួនជាលក្ខណៈប្រព័ន្ធ គឺពួកគាត់អាចធ្វើការស្នើសុំទៅកាន់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់នៃតំបន់ដែលខ្លួនរស់នៅដើម្បីទទួលបានសេវានៃការចុះបញ្ជីដីធ្លីជាលក្ខណៈដាច់ដោយដុំបានផងដែរ។ ពាក្យស្នើសុំត្រូវធ្វើជាពីរច្បាប់ និងត្រូវភ្ជាប់មកជាមួយនូវឯកសារដែលពាក់ព័ន្ធមួយចំនួនដូចជា ឯកសារនិងភ័ស្តុតាងទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី។ ពាក្យស្នើសុំដើម្បីធ្វើការចុះបញ្ជីដីធ្លីមាន៖ឈ្មោះនិងស្នាមមេដៃរបស់អ្នកដាក់ពាក្យ សេចក្តីពណ៌នាលំអិតអំពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងនៃក្បាលដីនោះ សេចក្តីពណ៌នាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជីឯកសារ និងភស្តុតាងទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី[៩]។ លក្ខខណ្ឌដើម្បីទទួលបានការចុះបញ្ជីដីធ្លីបានលុះត្រាតែអចលនវត្ថុទាំងនោះមានប្រវត្តិច្បាស់លាស់ត្រឹមត្រូវតាមគតិយុត្តដូចជា៖

### ១.៤.១. សន្តតិកម្ម

សន្តតិកម្ម ចាប់ផ្តើមដោយសារមរណភាពរបស់មតកជន នៅលំនៅដ្ឋានរបស់មតកជន នាពេលទទួលមរណភាព ហើយសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលជាទ្រព្យរបស់មតកជន នៅពេលចាប់ផ្តើមសន្តតិកម្ម (គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ) និងប្រសិនបើមានសន្តតិជនច្រើននាក់ ត្រូវ

[៩] សមាគមន៍សាលាត្រាជូរ **ឯកសាជំនួយស្មារតី ការចុះបញ្ជីដីដាច់ដោយដុំ** រៀបរៀងដោយ ជា អៀកងួន ថ្ងៃ០៧ មិថុនា ឆ្នាំ២០១៨ ។

សមាមាត្រនៃចំណែកមត៌ក។ មត៌តត្រូវចាត់ទុកថាជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន នៅពេលដែលមិនទាន់មានការបែងចែកត្រឹមត្រូវតាមច្បាប់ ឬការពិភាក្សាដែលមានលក្ខណៈអាចទទួលយកបានទាំងអស់គ្នា។ សន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬផ្អែកតាមឆន្ទៈមតកជន។ សន្តតិកម្មផ្អែកតាមបញ្ញត្តិនៃច្បាប់ហៅថា សន្តតិកម្មតាមច្បាប់។ សន្តតិកម្មផ្អែកតាមឆន្ទៈរបស់មតកជន ហៅថាសន្តតិកម្មតាមមតកសាសន៍។ បើបកស្រាយឱ្យងាយស្រួលឆាប់យល់យើងអាចនិយាយបានថាសន្តតិកម្ម គឺជាការប្រគល់ទ្រព្យសម្បត្តិទាំងឡាយណាដែលបន្សល់ទុកដោយជនដែលបានស្លាប់បាត់ទៅ ហើយឱ្យទៅបុគ្គលដែលត្រូវជាញាតិរបស់បុគ្គលដែលស្លាប់នោះ។ ទ្រព្យសម្បត្តិរបស់មតកជនទាំងចលនវត្ថុ និងអចនលវត្ថុ ត្រូវធ្លាក់មកសន្តតិជន ឬសហសន្តតិជនដោយស្វ័យប្រវត្តិ បន្ទាប់ពីមតកជនទទួលមរណភាព[10]។ ក្រមរដ្ឋប្បវេណីថ្មី មិនកំណត់ឲ្យមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុឡើយ ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែង ទោះបីជាសន្តតិជនទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចលើមត៌កដោយស្វ័យប្រវត្តិក៏ដោយ ក៏មានភាពលំបាកក្នុងការបង្ហាញតតិយជនថាគាត់ជាម្ចាស់កម្មសិទ្ធិស្របច្បាប់ដែរ។ ហេតុនេះហើយ ជាលក្ខណៈបច្ចេកទេសទាមទារឲ្យសន្តតិជនគ្រប់រូបធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយមូលហេតុសន្តតិកម្ម។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មិនបានកំណត់ឲ្យមានការចុះបញ្ជីចំពោះការទទួលកម្មសិទ្ធិតាមរយៈសន្តតិកម្មនោះទេ ព្រោះមិនមែនជាការផ្ទេរសិទ្ធិតាមរយៈការព្រមព្រៀងដែលត្រូវអនុវត្តន៍តាមមាត្រា១៣៥ នៃក្រមរដ្ឋប្បវេណីឡើយ តែដើម្បីទទួលបានលក្ខខណ្ឌតតាំងជាមួយតតិយជន អ្នកទទួលកម្មសិទ្ធិដោយមូលហេតុសន្តតិកម្មត្រូវធ្វើការចុះបញ្ជីនៅរដ្ឋបាលសុរិយោដី។

### ១.៤.២. ការលក់ទិញ

កិច្ចសន្យាទិញលក់ គឺជាកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់ដែលមានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិមកលើវត្ថុណាមួយទៅអោយភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នកទិញនេះមានករណីយកិច្ចទូទាត់ប្រាក់ជាថ្លៃនៃវត្ថុនោះទៅឲ្យអ្នកលក់[11]។ ស្របតាមនិយមន័យនេះយើងអាចកំណត់បានថាកិច្ច សន្យាទិញលក់អចលនទ្រព្យ គឺជាកិច្ចសន្យាមួយដែលភាគី (អ្នកលក់អចលនទ្រព្យ) មានករណីយកិច្ចត្រូវផ្ទេរ ឬប្រគល់នូវសិទ្ធិកាន់កាប់របស់ខ្លួនទៅភាគីម្ខាងទៀតដែលជា អ្នកទិញអចលនទ្រព្យ ហើយអ្នកទិញនេះមានករណីយកិច្ចទូទាត់ប្រាក់នៃថ្លៃទ្រព្យនោះទៅឲ្យអ្នកលក់។ ក្រោយពេលមានការទិញលក់អចលនវត្ថុ(ដីធ្លី) ភាគីអ្នកលក់គឺត្រូវមានកាតព្វកិច្ចក្នុងការចុះបញ្ជីកម្មសិទ្ធិដែលសំដៅទៅលើបុគ្គលដែលទទួលរងនូវការប៉ះពាល់ ផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជីឯភាគីអ្នកទិញជាបុគ្គលដែលមានសិទ្ធិចុះបញ្ជីគឺសំដៅលើបុគ្គលដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជីដី។ ក្នុងករណីដែលភាគីអ្នកទិញ បានធ្វើការដាក់ពាក្យស្នើរសុំចុះបញ្ជីដីដែលខ្លួនបាន

[10] **ក្រមរដ្ឋប្បវេណីខ្មែរ**, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៧ ចំណុច១។

[11] **ក្រមរដ្ឋប្បវេណីខ្មែរ**, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៥១៥។

ទិញនោះកម្មសិទ្ធិនឹងត្រូវបានផ្ទេរពីភាគីអ្នកលក់ មកភាគីអ្នកទិញវិញហើយបុគ្គលអ្នកទិញមានសិទ្ធិពេញលេញក្នុងការកាន់កាប់ ចាត់ចែង និងប្រើប្រាស់ដីធ្លីនោះ។ ហេតុនេះហើយការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី ឬអចលនវត្ថុ ( អ្នកលក់ទៅអ្នកទិញ) ជាលក្ខខណ្ឌមួយដែលបានបង្កើតអានុភាព មានន័យថាប្រសិនបើគ្មានការចុះបញ្ជីទេការព្រមព្រៀងផ្ទេរកម្មសិទ្ធិលើដី ឬអចលនវត្ថុនោះពុំបង្កើតអានុភាពឡើយ ពោលគឺអ្នកលក់នៅតែមានសិទ្ធិលើដីធ្លីនោះ ទោះបីជាការទិញលក់បញ្ចប់ទៅក៏ដោយ ( កម្មសិទ្ធិពុំត្រូវបានផ្ទេរ )។

# ជំពូក ២

# ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជន

# ជំពូក ២
# ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជន

## ២.១. ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីដីធ្លី

ស្ថាប័នដែលមានសមត្ថកិច្ចទទួលបន្ទុកក្នុងការចុះបញ្ជីដីធ្លីនៅកម្ពុជា គឺជាភារៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានធ្វើប្រតិភូកម្មជូនទៅ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ឬរដ្ឋបាលសុរិយោដីខេត្ត ក្រុង ដើម្បីទទួលភារៈចុះបញ្ជីក្បាលដី[១២]។

### ២.១.១ រចនាសម្ព័ន្ធគណៈកម្មការសុរិយោដី

គណៈកម្មការរដ្ឋបាលសុរិយោដីត្រូវបានគេបែងចែកជាបីទៀតគឺៈ[១៣]

\+ គណៈកម្មការរដ្ឋបាលសុរិយោដីថ្នាក់ជាតិ (គសជ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១៧ នៃអនុក្រឹត្យលេខ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី។ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាលជាអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រជាអ្នកទទួលបន្ទុករៀបចំសម្របសម្រួល និងត្រួតពិនិត្យប្រតិបត្តិការទាំងឡាយនៃការវាស់វែង សុរិយោដីដែលធ្វើឡើងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងរាល់ប្រតិបត្តិការកសាងប្លង់សុរិយោដី កសាងបញ្ជីឈ្មោះកម្មសិទ្ធិករកសាងសៀវភៅគោលបញ្ជី និងចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លី។ ក្រៅពីនេះអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវកំណត់វិធី និងស្តង់ដាទាក់ទងនឹងឯកសារ [១៤]។

\+ គណៈកម្មការរដ្ឋបាលសុរិយោដីថ្នាក់ខេត្តក្រុង ( គសខក ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១២នៃអនុក្រឹត្យលេខ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរយោដី។ រដ្ឋបាលសុរិយោដីខេត្ត-ក្រុង ឬ ស្រុក-ខ័ណ្ឌនីមួយៗត្រូវប្រតិបត្តិរាល់ការណែនាំពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។ រដ្ឋបាលសុរិយោដីខេត្ត-ក្រុង ឬ ស្រុកខណ្ឌ ទទួលធ្វើសម្រង់សុរិយោដីដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដទៃទៀត កាន់កាប់សៀវភៅគោលបញ្ជីដីធ្លី ធ្វើចរន្តការជាប្រចាំក្រោមការត្រួតពិនិត្យពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលរក្សាទុកឯកសារ និង ផ្តល់ព័ត៌មានដល់អ្នកស្នើសុំ [១៥]។

\+ គណៈកម្មការរដ្ឋបាលសុរិយោដីថ្នាក់ ស្រុក ខណ្ឌ ( គសសខ ) គឺជាគណៈកម្មការដែលបង្កើតឡើងដោយអនុលោមតាមមាត្រា៤ និងមាត្រា៥នៃអនុក្រឹត្យលេខ៤៧ អនក្រ/បក ស្តីពីការប្រព្រឹត្តិទៅនៃគណៈកម្មការ

---

[១២] អនុក្រឹត្យលេខ៤៨ មាត្រា១៧ ស្តីពី ***ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ*** ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។

[១៣] ប្រកាស លេខ១១២ ដនស/ប្រក ***ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី*** ចុះថ្ងៃទី២១ខែសីហាឆ្នាំ២០០២។

[១៤] ***ច្បាប់ភូមិបាល ឆ្នាំ២០០១*** ជំពូកទី១៥ អំពីរដ្ឋបាលសុរិយោដី មាត្រា២៣១។

[១៥] ***ច្បាប់ភូមិបាល ឆ្នាំ២០០១*** ជំពូកទី១៥ អំពីរដ្ឋបាលសុរិយោដី មាត្រា២៣២។

សុរិយោដី។ រដ្ឋបាលសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ត្រូវធ្វើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំ ឬសង្កាត់ ដែលពាក់ព័ន្ធ។ មេឃុំ ឬចៅសង្កាត់ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបពិគ្រោះយោបល់ហើយត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដីស្រុកខណ្ឌនូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន [១៦]។

### ២.១.២. តួនាទី និងភារកិច្ចរបស់អង្គភាពទទួលបន្ទុក

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានភារកិច្ចណែនាំ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្ត នឹងត្រូវកំណត់ស្តង់ដារបច្ចេកទេសសម្រាប់ការកំណត់ព្រំដី ការកសាងប្លង់សុរិយោដី និងការកសាងឯកសារផ្សេងៗ ព្រមទាំងកំណត់គំរូឯកសារដែលត្រូវប្រើក្នុងដំណើរការនៃការស្នើសុំចុះបញ្ជីដីធ្លីផងដែរ។

រដ្ឋបាលសុរិយោដីស្រុកខណ្ឌ ត្រូវទទួលខុសត្រូវក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យរាល់ក្បាលដី ដែលស្នើសុំចុះបញ្ជីក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌណាមួយមិនអាចបំពេញតាមលក្ខខណ្ឌសម្រាប់ការចុះបញ្ជីក្រោមក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ដោយសារតែសមត្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក ខណ្ឌនោះ អាចស្នើសុំឲ្យរដ្ឋបាលសុរិយោដីខេត្តក្រុង ជួយដល់ការអនុវត្តនូវការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យបាន[១៧]។ រដ្ឋបាលសុរិយោដីមានភារកិច្ចដូចតទៅ : (១).ធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធតាមបញ្ញត្តិ នៃអនុក្រឹត្យស្តីពីនីតិវិធី នៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដី (២).ធ្វើការពង្រឹងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ តាមនីតិវិធីដែលនឹងបញ្ញត្តិដោយអនុក្រឹត្យ (៣).អនុវត្តការអង្កេតវាស់វែងសុរិយោដី នៃក្បាលដីរួមមាន ការកំណត់ព្រំដីការបំបែកក្បាលដី ការបង្រួមក្បាលដី និងការតម្រូវព្រំប្រទល់នៃក្បាលដី និងជាទូទៅរាល់ការប្រែប្រួលអំពីទំហំ ដែលបណ្តាលមកពីធម្មជាតិ ឬ ដោយស្ម័គ្រចិត្ត(៤).កសាងសៀវភៅគោលបញ្ជីដីធ្លីហើយធ្វើលេខាចារិកឈ្មោះកម្មសិទ្ធិករ និងរាល់ទិន្នន័យប្រមូលបានទាក់ទងទៅនឹងលក្ខណៈរូប ទំហំ និង អត្តសញ្ញាណ នៃអចលនវត្ថុទាំងនោះ (៥).ធ្វើចរន្តការនូវរាល់ការផ្លាស់ប្តូរប្រែប្រួលទាក់ទងទៅនឹងសិទ្ធិ ដែលកើតឡើងដោយកិច្ចសន្យាផ្ទេរដូចជា ការលក់ ការឱ្យជាកាដូរ សន្តតិកម្ម ឬពាក់ព័ន្ធនឹងការដូរប្រភេទ ឬស្ថានភាពនៃដីដូចជា ការសាងសង់ ការចាក់បំពេញដី ការជីកកកាយយកដីជាដើម (៦).អភិរក្សនូវរាល់ឯកសារសុរិយោដីដែលមានប្លង់សុរិយោដី បញ្ជីឈ្មោះកម្មសិទ្ធិករ សៀវភៅគោលបញ្ជីដី និងរាល់ឯកសារគតិយុត្តិទាក់ទងទៅនឹងក្បាលដីនីមួយៗ (៧).ចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុជូនកម្មសិទ្ធិករ និងលិខិតបញ្ជាក់ផ្សេងៗទៀតទាក់ទងទៅនឹងក្បាលដី (៨).មានកាតព្វកិច្ចប្រគល់ជូនជន ដែលបានដាក់ពាក្យស្នើសុំប្លង់ថតចម្លង និង ឯកសារព័ត៌មានទាក់ទងទៅនឹងទីតាំង អត្តសញ្ញាណ ព្រំដី និង សិទ្ធិដែលទាក់ទង

[១៦] ***ច្បាប់ភូមិបាល ឆ្នាំ២០០១*** ជំពូកទី១៥ អំពីរដ្ឋបាលសុរិយោដី មាត្រា២៣៣។

[១៧] អនុក្រឹត្យលេខ ៤៨ អនក្រ.បក***ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ*** ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, ជំពូកទី២ មាត្រា២។

ទៅនឹងក្បាលដី (៩).ធ្វើលេខាចារិកនូវរាល់ហ៊ីប៉ូតែក ការបញ្ចាំ ការដាក់ធានា ការជួលរយៈពេលវែង ឬសេវភាពដែលបានបង្កើតឡើងលើទ្រព្យជាអចលនវត្ថុហើយផ្តល់ព័ត៌មានទៅគ្រប់ជនដែលសាកសួរមករដ្ឋបាលសុរិយោដីអំពីស្ថានភាពនៃកម្មសិទ្ធិដែលជាកម្មវត្ថុនៃការដាក់ហ៊ីប៉ូតែកដាក់បញ្ចាំ ដាក់ធានា ការជួលរយៈពេលវែង ឬសេវភាពនោះ[១៨]។

## ២.២. នីតិវិធីរដ្ឋបាលនៃការចុះបញ្ជីដីធ្លី

ក្នុងនីតិវិធីនៃការចុះបញ្ជីដីធ្លី និងការចេញប័ណ្ណកម្មសិទ្ធិមាននីតិវិធីពីរ គឺការចុះបញ្ជីតាមការស្នើសុំរបស់ម្ចាស់ដីដែលគេឲ្យឈ្មោះថាការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីមួយឃុំម្តងៗតាមការកំណត់របស់រដ្ឋាភិបាលដែលគេហៅថា ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ ក្រៅពីការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ និងលក្ខណៈដាច់ដោយដុំហើយ យើងក៏មានការចុះបញ្ជីដីបំពេញបន្ថែមទៀតផងដែរ

សម្រាប់អនុវត្តន៍ចំពោះក្បាលដីទាំងឡាយណាដែលមិនទាន់ទទួលបានការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ នៅក្នុងតំបន់ដែលខ្លួនស្ថិតនៅដោយសារមាន មូលហេតុផ្សេងៗណាមួយកើតឡើង។

### ២.២.១. ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវធ្វើទៅតាមការកំណត់របស់រាជរដ្ឋាភិបាលដែលត្រូវកំណត់យកតំបន់ណាមួយ ឬឃុំណាមួយជាតំបន់អាទិភាព។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវបានបង្កើតឡើងដោយផ្អែកលើបញ្ញត្តិគោលដែលមានចែងក្នុងមាត្រា២២៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ហើយត្រូវបានអនុវត្តនីតិវិធីចុះបញ្ជី គឺផ្អែកតាមអនុក្រឹត្យលេខ៤៦ អនក្រ/បក ចុះថ្ងៃ ទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធី និងការកសាង ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។ យោងតាមខ្លឹមសារ និងអត្ថបទនៃបទប្បញ្ញត្តិនេះ ការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ នឹងត្រូវអនុវត្តទៅលើគ្រប់ក្បាលដី (ទាំងរដ្ឋ និងឯកជន) ដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ បន្ទាប់ពីមានការឯកភាពពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អំពីការជ្រើសរើសទីតាំងរួចមកអភិបាលខេត្តក្រុង ត្រូវចេញសេចក្តីប្រកាសតំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យនោះ។

#### ២.២.១.១. សេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

ផ្អែកតាមសារាចរណែនាំលេខ០០១ ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ) ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវធ្វើឡើងជា៥ដំណាក់កាលគឺ ការត្រៀមរៀបចំ( ក ) កិច្ចប្រតិបត្តិការបច្ចេកទេស( ខ ) ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ( គ ) ការសម្រេចលើឯកសារ( ឃ ) និងការចេញប័ណ្ណ( ង )។

[១៨] ***ច្បាប់ភូមិបាល ឆ្នាំ២០០១*** ជំពូកទី១៥ អំពីរដ្ឋបាលសុរិយោដី មាត្រា២២៩។

### ក. ការត្រៀមរៀបចំ

នៅក្នុងដំណាក់កាលដំបូងនៃដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺបន្ទាប់ពីបានការពិភាក្សាឯកភាពគ្នាជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការជ្រើសរើសទីតាំងរួចមក អភិបាលខេត្តក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនី ឬតាមរបៀបពណ៌នា ឬតាមរបៀបទាំងពីរ[១៩]។ ដំណាក់កាលនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋរស់នៅក្នុងឃុំដែលត្រូវចុះបញ្ជីឲ្យបានជ្រាបអំពីការចុះបញ្ជីដីធ្លី ដើម្បីឲ្យពួកគាត់បានត្រៀមឯកសារពាក់ព័ន្ធ និងចូលរួមសហការ[២០]។ នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ[២១]។

យោងតាមមាត្រា៣ នៃអនុក្រឹត្យលេខ៤៦ គណៈកម្មការរដ្ឋបាលមានសមាសភាពដូចខាងក្រោម៖

**<u>តារាងទី១៖ សមាសភាពមន្ត្រីគណៈកម្មការរដ្ឋបាល[២៣]</u>**

| | |
|---|---|
| តំណាងអភិបាលខេត្តរាជធានី | ជាប្រធាន |
| មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី | ជាសមាជិក |
| មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី | ជាសមាជិក |
| អភិបាលក្រុង ស្រុក ខណ្ឌ ឬតំណាង | ជាសមាជិក |
| មេឃុំ ចៅសង្កាត់ ឬតំណាង | ជាសមាជិក |
| មេភូមិ ឬតំណាង | ជាសមាជិក |
| ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ២រូប | ជាសមាជិក |

ក្រោយពេលដែលគណៈកម្មការរដ្ឋបាលបានបង្កើតឡើងហើយ គណៈកម្មការនេះមានភារកិច្ច នឹងកាតព្វកិច្ចដូចជា[២៤] (១).បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដីមានជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីធ្លី (២).ទទួលរាល់បណ្តឹងតវ៉ា ស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង (៣).សន្និដ្ឋាន និង

[១៩] សារាចរណែនាំស្តីពី**ការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី**, លេខ០០១ ដនស/សជ, ១៩ សីហា ២០០២, ដំណាក់កាលទី១ ចំណុចទី១ (តទៅហៅថា សារាចរណែនាំលេខ០០១)។

[២០] **នីតិទ្រព្យសម្បត្តិ** សឿន សោភ័ណ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៨។

[២១] **អនុក្រឹត្យលេខ៤៦**, មាត្រា៣។

[២៣] **នីតិទ្រព្យសម្បត្តិ** បណ្ឌិត សឿន សោភ័ណ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

[២៤] **នីតិទ្រព្យសម្បត្តិ បណ្ឌិត សឿន សោភ័ណ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០១៨។

ផ្តល់យោបល់លើឯកសារវិនិច្ឆ័យ និង(៤).លើកសំណើរផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ កម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ។

### ខ. កិច្ចប្រតិបត្តិការបច្ចេកទេស

ក្នុងដំណាក់កាលនេះកិច្ចប្រតិបត្តិការបច្ចេកទេស ឬការងារវិនិច្ឆ័យត្រូវបានបែងចែកជា ២ផ្នែកគឺ ការងារវាល(ខ.១) និងការងារនៅការិយាល័យ (ខ.២)។

#### ខ.១. ការងារវាល

ការងារនេះស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ។ ការងារវាលត្រូវបានអនុវត្តន៍ដោយមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ដោយមានការសហការពីមន្ត្រីមូលដ្ឋាន ( មេភូមិ មេឃុំ ចៅសង្កាត់)។ ការកំណត់ព្រំដី មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់វិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលចាប់ផ្តើមនឹងធ្វើការវិនិច្ឆ័យឲ្យបានមុន៣(បី)ថ្ងៃយ៉ាង តិច។ នៅក្នុងដំណាក់កាលនេះ តម្រូវឲ្យភាគីអ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់នៃជនផងនេះ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធដទៃទៀត ចូលរួមសហការជាមួយមន្ត្រីការងារវាលទាំងបីខាងលើ ដោយផ្តល់នូវព័ត៌មានពិតដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬឯកសារផ្សេងទៀតដែលទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនឈរឈ្មោះជាតំណាង ឬក្បាលដីអ្នកជាប់ព្រំដល់មន្ត្រីជំនាញ។ ម្ចាស់ដី និងអ្នកជិតខាងជាអ្នកចង្អុលបង្ហាញព្រំដីរបស់ខ្លួនទៅមន្ត្រីបច្ចេកទេស ចំណែកមន្ត្រីបច្ចេកទេសជាអ្នកមានភារកិច្ចខាងកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យជូនអ្នកកាន់កាប់ដី[២៥]។

ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ មន្ត្រីកំណត់ព្រំដី ត្រូវគោរពគោលការណ៍ដូចជា៖ ត្រូវបានកំណត់យោងតាមការព្រមព្រៀងរវាង ម្ចាស់នៃក្បាលដីដែលជាប់ព្រំប្រទល់ បើការព្រមព្រៀងមិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំប្រទល់ណាមួយអវត្តមាននោះ ព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភ័ស្តុតាងជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនិងព្រំដី។ ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់ នឹងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់តាមការបកស្រាយខាងលើ។ វិវាទទាំងអស់អំពីព្រំប្រទល់ ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដីត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួល និងដោះស្រាយវិវាទក្រោមមាត្រា១២ នៃអនុក្រឹត្យនេះ[២៦]។ ការវាស់វែង បន្ទាប់ពីកំណត់ព្រំដីរួចមកមន្ត្រីវាស់វែង ត្រូវកំណត់ការងារវាស់វែងដែលជាតម្រូវការក្នុងការកសាងប្លង់

---

[២៥] ***នីតិទ្រព្យសម្បត្តិ បណ្ឌិត សឿន សោភ័ណ*** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០១៨។

[២៦] **អនុក្រឹត្យ** លេខ១២២ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩, មាត្រា៧។

សុរិយោដី និងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ[២៧]។

ក្នុងពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ ប្រជាពលរដ្ឋមានសិទ្ធិជំទាស់តវ៉ាប្រសិនបើខ្លួនយល់ថា ទិន្នន័យដែលមន្ត្រីបានកត់ត្រាចូលក្នុងទម្រង់បែបបទ នៃការប្រមូលទិន្នន័យមិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន។អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវបង្ករលក្ខណៈសម្បត្តិងាយស្រួលសហការបានល្អ និងផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការបច្ចេកទេសរដ្ឋបាលគតិយុត្ត ដើម្បីធ្វើអោយសម្រេចនូវការអនុវត្តនីតិវិធីដែលប្រព្រឹត្តិនៅក្នុងដែនដីដែលខ្លួនទទួលខុសត្រូវ។ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារដែលមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីក្នុងឃុំសង្កាត់ណាមួយឬតំណាងស្របច្បាប់របស់ខ្លួនត្រូវតាមកាលកំណត់ និងតម្រូវការជាក់ស្តែងនៃការងារ[២៨]។

ខ.២. ការងារនៅការិយាល័យ

នៅពេលដែលមន្ត្រីការងារវាល ធ្វើការវាស់វែងកំណត់ព្រំប្រទល់ក្បាលដីរួចមក មន្ត្រីការិយាល័យ នឹងធ្វើការប្រមូលទិន្នន័យបានពីមន្ត្រីជំនាញការងារវាល ដែលជាចាំបាច់ណាស់ត្រូវបញ្ចូលទិន្នន័យនោះទៅក្នុងកុំព្យូទ័រដើម្បីចាប់ផ្តើមកសាងប្លង់សុរិយោដី បញ្ជីឈ្មោះ និងសៀវភៅគោលបញ្ជីដីធ្លីព្រមទាំងរៀបចំចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិករនៃដី[២៩]។

**គ. ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

អភិបាលរាជធានី ខេត្ត ត្រូវធ្វើសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យដូចជា ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី តាមសំណើររបស់គណៈកម្មការរដ្ឋបាល។ ការជូនដំណឹងអាចធ្វើឡើងតាមគ្រប់មធ្យោបាយដូចជាតាមរយៈការប្រជុំ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន រូបភាព បិទផ្សាយឬតាមឧគ្ឃោសនសព្ទ។ ការបិទផ្សាយជាសាធារណៈមានរយៈពេលកំណត់ ១៥ថ្ងៃ ហើយត្រូវធ្វើនៅកន្លែងដែលងាយមើលឃើញក្នុងទីតាំងនៃតំបន់ធ្វើការវិនិច្ឆ័យដូចជា ទីវត្តអារាម ទីសាធារណៈ សាលាឃុំ សាសាសង្កាត់ សាលាស្រុក[៣០]។ សាមីអ្នកកាន់កាប់ដីឬអ្នកតំណាងស្របច្បាប់របស់ជននេះ ដែលមិនទាន់យល់ស្របតាមការសម្រេចបណ្តោះអាសន្នរបស់មន្ត្រីជំនាញនៅពេលប្រតិបត្តិកំណត់ព្រំដី ឬវិនិច្ឆ័យ មានសិទ្ធិប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅគណៈកម្មការរដ្ឋបាលនៅពេលបិទផ្សាយជាសាធារណៈនៃឯកសារនៃការវិនិច្ឆ័យ ដើម្បីឲ្យគណៈកម្មការនេះលើកយកដោះស្រាយឡើងវិញ។ ក្នុងករណីមិនមានការជំទាស់ ឬតវ៉ាក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ

[២៧] **អនុក្រឹត្យ** លេខ៤៦អនក្រ/បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០២, មាត្រា៨។

[២៨] **សារាចរណែនាំ**លេខ០០១ ដនស/សដ, ចុះថ្ងៃ១៩ ខែសីហា ឆ្នាំ២០០១, ដំណាក់កាល២។

[២៩] **សារាចរណែនាំ** លេខ០០១ ដនស/សដ, ចុះថ្ងៃ១៩ ខែសីហា ឆ្នាំ២០០១, ដំណាក់កាល២។

[៣០] **អនុក្រឹត្យ** លេខ១២២ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩,មាត្រា១១។

ទិន្នន័យដែលបានកត់ត្រានោះ ត្រូវបានទុកជាទិន្នន័យសុក្រឹត ដែលអាចកំណត់យកជាផ្លូវការតាមច្បាប់។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិកែប្រែតម្រូវចំពោះកំហុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ប្រយោជន៍អ្នកដទៃ។ ចំពោះការកែតម្រូវណាដែលនាំឲ្យជះឥទ្ធិពលដល់ប្រយោជន៍អ្នកដំទៃអាចធ្វើការកែសម្រួលបានលុះត្រាតែមានការយល់ព្រមពីជនដែលមានប្រយោជន៍ពាក់ព័ន្ធ។

### ឃ. ការសម្រេចលើឯកសារ

ក្រោយពីផុតរយៈពេលនៃការប្រកាសបិទផ្សាយជាសាធារណៈនូវរាល់ឯកសារវិនិច្ឆ័យ គណៈកម្មការរដ្ឋបាលត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលវិនិច្ឆ័យ តាមខ្លឹមសារដូចខាងក្រោម៖

+ លទ្ធផលសម្រេចបាន៖ (១)ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ (២)ចំនួនក្បាលដីដែលមិនត្រូវបានចេញប័ណ្ណជូនដោយការកាន់កាប់ដីរដ្ឋចាប់ផ្តើមក្រោយការចូលជាធរមាននៃច្បាប់ភូមិបាល (៣) ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវនិងគ្មានវិវាទ (៤)ចំនួនក្បាលដីមានវិវាទដែលគណៈកម្មការរដ្ឋបាលដោះស្រាយរួចតាមការព្រមព្រៀង(៥)ចំនួនក្បាលដីមានវិវាទត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដី និង (៦)ចំនួនក្បាលដីដែលកំពុងមានបណ្តឹងនៅតុលាការ[៣១]។
+ វាយតម្លៃ និងលើកសំណើរផ្តល់សិទ្ធិលើដី ឬអចលនវត្ថុ ៖ ការវាយតម្លៃ និងលើកសំណើរផ្តល់សិទ្ធិលើដី ឬអចលនវត្ថុនេះត្រូវយោងទៅលើច្បាប់ បទដ្ឋានគតិយុត្ត ឯកសារ និងភស្តុតាងដែលប្រមូលបានពីការសាកសួរផ្ទាល់មាត់ និងឯកសារដែលពាក់ព័ន្ធ។

### ង. ការចេញប័ណ្ណ

នៅពេលនីតិវិធីនៃការវិនិច្ឆ័យត្រូវបាលបានបញ្ចប់ជាស្ថាពរ ឯកសារនៃការវិនិច្ឆ័យ និងឯកសាររណបទាំងអស់ ត្រូវបានបញ្ជូនទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជីចេញប័ណ្ណ និងគ្រប់គ្រង។ គោលការណ៍នៃការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅប្រទេសកម្ពុជាមាន៖ ១. ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប័ណ្ណកម្មសិទ្ធិ)ចំពោះក្បាលដី ឬអចលនវត្ថុណាដែលមិនបានកាន់កាប់ដោយសន្តិវិធី និងមិនត្រូវមានការជំទាស់ចាប់ពី៥ឆ្នាំយ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់ភូមិបាល (មាត្រា១០ វាក្យខណ្ឌទី១ នៃច្បាប់ភូមិបាល)។ ២.ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ)ចំពោះក្បាលដី ឬអចលនវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធីនឹងមិនមានការជំទាស់ ហើយមានរយៈពេលតិចជាងប្រាំឆ្នាំមុនច្បាប់ភូមិបាលចូលជាធរមាន។ ចំពោះប័ណ្ណប្រភេទនេះអាចប្តូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនៅពេលដែលរយៈពេលនៃការកាន់កាប់ដី ប្រើប្រាស់ដី ឬអចលនវត្ថុ

---

[៣១] **សារាចរណែនាំលេខ០០១**, ដំណាក់កាលទី៤។

នោះបានគ្រប់៥ឆ្នាំឬលើស។ ៣.អាចចេញប័ណ្ណជូនចំពោះតែក្បាលដី ឬអចលនវត្ថុណាដែលគ្មានការពាក់ព័ន្ធនឹងវិវាទ។ ៤.ការប្រគល់ប័ណ្ណត្រូវមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នកប្រគល់និងកត់ឈ្មោះរួចផ្តិតមេដៃអ្នកទទួលទុកជាភ័ស្តុតាង។ ការប្រគល់ប័ណ្ណត្រូវ ប្រព្រឹត្តិទៅនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច។ មន្ត្រីសុរិយោដី មិនត្រូវបានអនុញ្ញាតឲ្យប្រគល់ប័ណ្ណ ជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដបានឡើយ លើកលែងតែម្ចាស់សិទ្ធិទទួលមរណៈភាព អវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាពដែល ច្បាប់ទទួលស្គាល់ពេលនោះអ្នកតំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស។ ករណីពិសេស និងចាំបាច់ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំប័ណ្ណបានតែត្រូវបញ្ជាក់ពីហេតុដែល មិនអាចមកទទួលប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឲ្យប្រគល់នៅគេហដ្ឋាន របស់កម្មសិទ្ធិករ ភោគីដោយមន្ត្រីសុរិយោដីយ៉ាងតិចពីរនាក់។ ៥.នៅពេលទទួលប័ណ្ណថ្មីម្ចាស់ដី ឬអចលនវត្ថុត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិលើដី ឬអចលនវត្ថុជូនមន្ត្រីសុរិយោដីប្រសិនបើមាន។ ៦.ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព មិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។ ចំពោះដីធ្លីសមូហភាពដូចជា ដីវត្តអារាមឬសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប័ណ្ណក៏ត្រូវមានការចុះឈ្មោះរបស់វត្ត ឬសហគមន៍ផងដែរ ដែលមិនអាចធ្វើការចុះឈ្មោះរបស់នរណាម្នាក់ឲ្យមកធ្វើជាអ្នកតំណាង ឬអ្នកទទួលបន្ទុកក្នុងការគ្រប់គ្រងនូវអចលនវត្ថុនោះបានឡើយ[៣២]។

ជារួមយោងតាមសេចក្តីណែនាំ លេខ២៧៣អសដក ស្តីពីការកែតម្រូវឯកសារផ្លូវការ និងឌីជីថល ( Digital )[៣៣] សម្រាប់នីតិវិធិនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដែលចេញដោយអគ្គនាយកដ្ឋាន និងភូមិសាស្ត្រ បានឲ្យដឹងថារយៈកាលកន្លងមកនេះ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅមានកំហុសផ្នែកបច្ចេកទេសក្នុងការកំណត់អត្តសញ្ញាណក្បាលដី ដោយព្រំប្រទល់រដ្ឋបាលមិនទាន់បានកំណត់ច្បាស់លាស់ ព្រំដីសាធារណៈមិនទាន់ត្រូវបានកំណត់ ម្ចាស់ដីខ្លះមិនបានចូលរួមពិនិត្យទិន្នន័យ ពេលបិទផ្សាយជាសាធារណៈ និងកង្វះការត្រួតពិនិត្យម៉ត់ចត់ពេលបញ្ចូលទិន្នន័យក្នុង កំព្យូទ័រ និងពេលបោះពុម្ពប័ណ្ណចេញមក បណ្តាលឲ្យក្បាលដីខ្លះខុសទីតាំងពិតប្រាកដ ក្បាលដីខ្លះត្រួតលើគ្នាទាំងមូល ឬចំណែកខ្លះ ក្បាលដីខុសទំហំ ក្បាលដីខ្លះត្រូវបានកត់ត្រាទំហំខុសគ្នាកក្នុងសៀវភៅគោលបញ្ជីដីធ្លី និងក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ករណីខ្លះទៀត វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានបាត់មុនពេលចែកជូនម្ចាស់ដី។ ជារឿយៗ ក្រោយពេលចែកប័ណ្ណរួច តែងតែមានការតវ៉ាពីសាមីម្ចាស់នៃក្បាលដីទាំងអស់នោះ ធ្វើឲ្យមន្ត្រីជំនាញស្មុគស្មាញក្នុងការដោះស្រាយជូនពួកគាត់។

---

[៣២] *សារាចរណែនាំលេខ០០១*, ដំណាក់កាលទី៥។

[៣៣] សេចក្តីណែនាំ លេខ២៧៣អសដក **ស្តីពីការកែតម្រូវឯកសារផ្លូវការ និងឌីជីថល** សម្រាប់នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដែលចេញដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ, ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧។

ដើម្បីដោះស្រាយកង្វះខាតដូចបានរៀបរាប់ខាងលើ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្របានធ្វើការណែនាំដល់មន្ត្រីអនុវត្តការងារដូចតទៅ៖

+ កំហុសទាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី ៖ មានន័យថា ការកំណត់ក្បាលដីមួយខុសពីទីតាំងពិតប្រាកដនៃក្បាលដីនោះ ដូច្នេះក្បាលដីមួយត្រូវបិតនៅលើទីតាំងនៃក្បាលដីមួយទៀត ឬក្បាលដីមួយត្រួតលើក្បាលដីមួយទៀត ឬក្បាលដីពីរមានមួយចំណែកត្រួតលើគ្នា។ ក្បាលដីទាំងនោះអាចមានទំហំស្មើគ្នា សណ្ឋានទ្រង់ទ្រាយដូចគ្នា ហើយក៏អាចមានទំហំខុសគ្នាដែរ ឬសណ្ឋានទ្រង់ទ្រាយមិនដូចគ្នា ដូច្នេះ ប្រសិនបើចង់កែតម្រូវក្បាលដីណាមួយ គឺត្រូវកែតម្រូវក្បាលដីដែលមានការពាក់ព័ន្ធគ្នាទាំងអស់ជាចាំបាច់។

+ ករណីបាត់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមុនពេលប្រគល់ ៖ នៅខេត្តក្រុង អនុវត្តន៍គម្រោងមួយចំនួនបានបោះពុម្ពវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួចហើយ ថែមទាំងបានថតចម្លងទុកជាឯកសារទៀតផង ប៉ុន្តែវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមួយចំនួនត្រូវបានបាត់ រកពុំឃើញហើយត្រូវម្ចាស់ដីស្នើសុំ។ ករណីនេះ តម្រូវឲ្យមន្ទីរដនសស. អនុវត្តនីតិវិធីនៃការផ្តល់ប័ណ្ណទុតិយតាដែលមានដំណាក់កាលបន្តបន្ទាប់ គឺការប្រកាសរកប័ណ្ណដែលបាត់ ការធ្វើការប្រកាសមោឃភាពប័ណ្ណដែលបាត់ហើយរកមិនឃើញ និងការចេញប័ណ្ណទុតិយតាជូនម្ចាស់ដី។ គួរកត់សម្គាល់ថា ប័ណ្ណដែលបោះពុម្ពលើកក្រោយមានទិន្នន័យដូចគ្នានឹងប័ណ្ណដែលបាត់ ប៉ុន្តែលេខទំព័រនៃប័ណ្ណមិនដូចគ្នាទេ។

ជាទូទៅ សម្រាប់ដំណើរការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺមានរយៈពេល៥ខែទៅ៧ខែ ឬ១០០ថ្ងៃទៅ១៤០ថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃចុះប្រមូលទិន្នន័យរហូតដល់ថ្ងៃប្រគល់ប័ណ្ណ។

### ២.២.២ ការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ

ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ បានចាប់ផ្តើមពីឆ្នាំ១៩៨៩ តាមរយៈការប្រកាសឲ្យដាក់ពាក្យសុំកាន់កាប់ដី នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩០[៣៤]។ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ គឺជាការចុះបញ្ជីនូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ដែលមិនទាន់ បានចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ជាមួយការស្នើសុំទៅកាន់ រដ្ឋបាលសុរិយោដី ស្រុក ខណ្ឌតាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីនោះស្ថិតនៅ។ បន្ទាប់ពីរដ្ឋបាលសុរិយោដីបានពិនិត្យលើពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្របតាមការកំណត់ហើយនោះរដ្ឋបាលសុរិយោដី ស្រុក ខណ្ឌ នឹងកត់ត្រាចូលក្នុងសៀវភៅទទួលពាក្យនិងកំណត់កាលបរិច្ឆេទចុះធ្វើការកំណត់ព្រំដីវាស់វែង និងវិនិច្ឆ័យ។

[៣៤] ***នីតិទ្រព្យសម្បត្តិ***, ហាប់ ផល្លី បង្រៀនថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៣ នៅសាកលលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### ២.២.២.១ សេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

ផ្អែកតាមសារាចរណែនាំលេខ១៤ ស្តីពីការអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ការចុះបញ្ជីដីធ្លីដាច់ដោយដុំ ត្រូវធ្វើឡើងជា៥ដំណាក់កាលគឺ (ក)ការដាក់ពាក្យស្នើរសុំ (ខ)កិច្ចប្រតិបត្តិការបច្ចេកទេស (គ)ការបិទផ្សាយជាសាធារណៈ (ឃ)ការសម្រេចលើឯកសារ (ង)និងការចេញប័ណ្ណ។

**ក. ការដាក់ពាក្យស្នើសុំ**

ដើម្បីធ្វើការស្នើសុំចុះបញ្ជីដីធ្លីរបស់ខ្លួន ប្រជាពលរដ្ឋគ្រប់រូបទាំងអស់ដែលជាម្ចាស់នៃដីធ្លី ត្រូវធ្វើការដាក់ពាក្យស្នើសុំចុះបញ្ជីដីធ្លីរបស់ខ្លួនតាមពេលវេលា និងជាដំណាក់កាលដូចខាងក្រោមៈ

ក.១. តាមរយៈមេឃុំ ចៅសង្កាត់

ការដាក់ពាក្យសុំចុះបញ្ជីដូចបានលើកឡើងខាងលើស្រាប់ម្ចាស់ដីជាអ្នកស្នើសុំធ្វើប្លង់កម្មសិទ្ធិនេះដោយផ្ទាល់។ សាមីអ្នកកាន់កាប់ដី ដែលមានបំណងចង់ដាក់ពាក្យស្នើសុំធ្វើការចុះបញ្ជីដីរបស់ខ្លួន ត្រូវតែបំពេញគំរូពាក្យតាមការចាត់ចែង និងរៀបចំដាក់ជូនរដ្ឋបាលសុរិយោដី ស្រុក ក្រុង ខណ្ឌ។ ក្នុងការដាក់ពាក្យម្ចាស់ដីត្រូវដាក់ពាក្យសុំទៅការិយាល័យសុរិយោដី ស្រុក/ខណ្ឌ ដែលដីនេះតាំងនៅ។ ប៉ុន្តែមុននឹងសុំដល់ថ្នាក់ស្រុក/ខណ្ឌ ម្ចាស់ដីត្រូវធ្វើលិខិតបញ្ជាក់ចេញពីមេឃុំ/ចៅសង្កាត់ ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណនៃការប្រើប្រាស់ដី និងការទទួលស្គាល់ពីថ្នាក់មូលដ្ឋានជាមុនសិន។ ពាក្យសុំត្រូវធ្វើជាពីរច្បាប់ និងអាចមានឯកសារដែលពាក់ព័ន្ធភ្ជាប់មួយចំនួនទៀតផងដែរ ដូចជាឯកសារ និងភ័ស្តុតាងដែលទាក់ទងនិងក្បាលដី ឬសិទ្ធិក្បាលដែលស្នើសុំធ្វើការចុះបញ្ជី[៣៥]។

ការដាក់ពាក្យស្នើសុំធ្វើការចុះបញ្ជីដីធ្លី ដែលបានដាក់ដោយសាមីអ្នកកាន់កាប់ដីមេឃុំ ឬចៅសង្កាត់ត្រូវមានភារកិច្ចក្នុងការត្រួតពិនិត្យ និងណែនាំដល់សាមីខ្លួនអ្នកកាន់កាប់ដីបំពេញឲ្យបានច្បាស់លាស់ និងត្រឹមត្រូវនៃខ្លឹមសារនៃពាក្យស្នើសុំនោះ ព្រមទាំងលក្ខណៈសមស្របតាមហេតុការណ៍ដែលបានកើតឡើងនោះ មានភាពជាក់ស្តែងដែរឬទេ។ ក្នុងនោះចំណុចដែលត្រូវយកចិត្តទុកដាក់ជាងគេគឺ លក្ខណៈសមស្រប នៃការកាន់កាប់ដីដែលបានប្រើហិង្សា ឬគ្មាន។ កាលបរិច្ឆេទនៃការចូលកាន់កាប់ដីពិតប្រាកដមានច្បាស់លាស់ដែរ ឬទេ? ទីតាំងរបស់ក្បាលដីមានការប៉ះពាល់ដល់ដីសាធារណៈដែរឬទេ? ក្បាលដីដែលកំពុងស្នើសុំចុះបញ្ជីនិងមានទំនាស់ដែរឬទេ? បន្ទាប់ពីពិនិត្យឃើញថា ឯកសារទាំងនោះមានលក្ខណៈគ្រប់គ្រាន់ហើយនោះ មេឃុំ ឬចៅសង្កាត់នោះត្រូវធ្វើការចរចារនៅលើពាក្យសុំនោះ រួចធ្វើការបញ្ជូនទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់ ស្រុក ក្រុង ខណ្ឌ នៃទីកន្លែងដែលប្រជាពលលរដ្ឋបានធ្វើការដាក់ពាក្យស្នើសុំចុះបញ្ជីដីធ្លីនោះ[៣៦]។

---

[៣៥] មាត្រា៧ នៃអនុក្រឹត្យ លេខ៤៨ និងសារាចរណែនាំលេខ១៤ ត្រង់ដំណាក់កាលទី១ កថាខណ្ឌ១។

[៣៦] សារាចរណែនាំលេខ ១៤ ត្រង់ដំណាក់កាលទី១ កថាខណ្ឌ២ និង៣។

ក.២. រដ្ឋបាលសុរិយោដី ស្រុក ក្រុង ខណ្ឌ

ជាគោលការណ៍ នៅពេលដែលទទួលបានពាក្យស្នើសុំចុះបញ្ជីរួចពីមេឃុំ ឬចៅសង្កាត់ រដ្ឋបាលសុរិយោដី ស្រុក ក្រុង ខណ្ឌ ត្រូវពិនិត្យពាក្យស្នើសុំចុះបញ្ជីដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់។ ផ្អែកលើគោលការណ៍នេះយើងនឹងសង្កេតឃើញមានរូបភាពពីរយ៉ាង ដែលនិងកើតឡើងក្រោយពីការពិនិត្យយ៉ាងហ្មត់ចត់របស់រដ្ឋបាលសុរិយោដីគឺ ករណីដែលពាក្យស្នើសុំចុះបញ្ជីមានលក្ខណៈត្រឹមត្រូវ សមស្រប និងករណីពាក្យសុំចុះបញ្ជីមានលក្ខណៈមិនត្រឹមត្រូវ ឬមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ។

+ **ករណីដែលពាក្យស្នើសុំចុះបញ្ជីមានលក្ខណៈត្រឹមត្រូវ ឬសមស្រប៖** រដ្ឋបាលសុរិយោដី ស្រុក ក្រុង ខណ្ឌ ត្រូវកត់ត្រាពាក្យស្នើសុំទាំងអស់នោះចូលក្នុងសៀវភៅទទួលពាក្យ ចុះលេខ រួចចារលើពាក្យនោះកំណត់កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវអនុវត្តកំណត់ព្រំប្រទល់ ការវាស់វែង និងការវិនិច្ឆ័យហើយត្រូវប្រគល់ពាក្យនោះមួយច្បាប់ជូនទៅអ្នកធ្វើការដាក់ពាក្យស្នើសុំចុះបញ្ជីនោះ។ការប្រមូលពាក្យស្នើសុំចុះបញ្ជីក្បាលដីទាំងនោះ ត្រូវបានអនុញ្ញាតតាមលទ្ធភាពក្នុងការអនុវត្តការងារ ដែលក្រុមការងារវាលអាចអនុវត្តបានក្នុងមួយថ្ងៃ ដើម្បីបង្កើតបញ្ជីឈ្មោះរបស់អ្នកស្នើសុំចុះបញ្ជីដី និងធ្វើសេចក្ដីជូនដំណឹងតែមួយដាក់ជូនទៅអភិបាលស្រុក ក្រុង ខណ្ឌ លើកសំណើរដើម្បីកំណត់ជាផ្លូវការនូវកាលបរិច្ឆេទ និងទីកន្លែងដើម្បីត្រូវអនុវត្ត។ សេចក្ដីជូនដំណឹងនេះ ត្រូវប្រគល់ជូនអ្នកដាក់ពាក្យស្នើសុំ និងធ្វើការបិទផ្សាយជាសាធារណៈយ៉ាងតិច១៤ថ្ងៃ មុនកាលបរិច្ឆេទនៃការចុះកំណត់ព្រំដីនៅតាមសាលាស្រុក ក្រុង ខណ្ឌ សាលាឃុំ សង្កាត់ និងទីកន្លែងដែលអាចមើលឃើញច្បាស់ នៅក្នុងតំបន់ដែលម្ចាស់ក្បាលដីបានដាក់ពាក្យស្នើសុំចុះបញ្ជីនោះស្ថិតនៅ[៣៧]។

+ **ករណីដែលពាក្យស្នើសុំចុះបញ្ជីមានលក្ខណៈមិនត្រឹមត្រូវ៖** ក្នុងករណីដែលរដ្ឋបាលសុរិយោដី ស្រុក ក្រុង ខណ្ឌពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈមិនសមស្រប រដ្ឋបាលសុរិយោដីស្រុក ក្រុង ខណ្ឌ ត្រូវតែចរចារលើពាក្យដោយបញ្ជាក់ពីមូលហេតុដែលមិនអាចអនុវត្តន៍ចំពោះការចុះបញ្ជីដីធ្លីបាន។ ការពិនិត្យលើពាក្យសុំត្រូវអនុវត្តន៍តាមរូបភាពប្លែកៗពីគ្នា អាចកើតមានឡើងដូចក្នុងករណីខាងក្រោម៖ (១).កាលបរិច្ឆេទនៃការចូលកាន់កាប់ដីក្រោយថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ រដ្ឋបាលសុរិយោដីស្រុក ក្រុង ខណ្ឌ ត្រូវចារលើពាក្យស្នើសុំឲ្យបានច្បាស់លាស់ភាពខុសច្បាប់នៃការចូលកាន់កាប់ដីហើយប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំចុះបញ្ជីវិញ។ (២).ការកាន់កាប់ដីដែលមានលក្ខណៈមិនសមស្របពោល គឺការចូលកាន់កាប់ដោយប្រើប្រាស់អំពើទុច្ចរិត (បោកបញ្ឆោត លួងលោម...) រដ្ឋបាលសុរិយោដីស្រុក ក្រុង ខណ្ឌ ត្រូវចារលើពាក្យស្នើសុំឲ្យបានច្បាស់លាស់ពីមូលហេតុហើយប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំចុះបញ្ជីវិញ។ (៣).ដីដែលធ្វើការស្នើសុំចុះបញ្ជីនោះជាដី

[៣៧] មាត្រា៨ កថាខណ្ឌ ១-២ និងមាត្រា៩ ***នៃអនុក្រឹត្យលេខ ៤៨*** និង ***សារាចរណែនាំ លេខ១៤*** ត្រង់ដំណាក់កាលទី១កថាខណ្ឌ៤។

សាធារណៈរបស់រដ្ឋបាលសុរិយោដីស្រុក ក្រុង ខណ្ឌ ត្រូវចារលើពាក្យស្នើសុំឲ្យបានច្បាស់លាស់ អំពីមូលហេតុដែលមិនអាចធ្វើដំណើរការប្រព្រឹត្តទៅបាននៃនីតិវិធីហើយប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំចុះបញ្ជីវិញ។

(៤).មានវិវាទដែលពាក់ព័ន្ធនិងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក ក្រុង ខណ្ឌត្រូវបញ្ជូនសំណុំរឿងនោះទៅកាន់គណៈកម្មការសុរិយោដីដើម្បីធ្វើការដោះស្រាយទៅតាមនីតិវិធីរបស់គណៈកម្មការ[៣៨]។

គ្រប់ករណីដែលរដ្ឋបាលសុរិយោដីស្រុក ក្រុង ខណ្ឌបដិសេធមិនព្រមអនុវត្តនីតិវិធីនៃការចុះបញ្ជីដីតាមការស្នើសុំរបស់សាមីអ្នកកាន់កាប់ដី ឬតំណាងស្របច្បាប់នោះ មានសិទ្ធិក្នុងការដាក់ពាក្យប្តឹងតវ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានីខេត្ត។ អ្នកដាក់ពាក្យស្នើសុំត្រូវបង់សោហ៊ុយសេវាសុរិយោដីតាមការកំណត់របស់រដ្ឋ[៣៩]។

ដើម្បីអនុវត្តន៍ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំនេះជាដំបូងគឺ ត្រូវមានការដាក់ពាក្យស្នើរសុំពីអ្នកកាន់កាប់ដីធ្លីនោះ។ សាមីខ្លួនជាអ្នកកាន់កាប់ដីធ្លី ដែលស្នើសុំចុះបញ្ជីត្រូវដាក់ពាក្យស្នើរសុំចុះបញ្ជីដែលបានកំណត់មករដ្ឋបាលសុរិយោដីស្រុកខណ្ឌតាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីស្នើរសុំចុះបញ្ជីនោះស្ថិតនៅ[៤០]។ មេឃុំ ចៅសង្កាត់ត្រូវពិនិត្យមើលពាក្យស្នើសុំ ណែនាំឲ្យសាមីអ្នកកាន់កាប់ដីបំពេញបាន គ្រប់គ្រាន់តាមខ្លឹមសារដែលបានរៀបចំ ថាតើសេចក្តីដែលសាមីអ្នកស្នើសុំបានបំពេញនោះ ស្របតាមហេតុការណ៍ដែលបានកើតឡើងជាក់ស្តែងដែរឬទេ? បន្ទាប់ពិនិត្យឃើញថាពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ហើយ មេឃុំ ចៅសង្កាត់នោះត្រូវពិនិត្យលើពាក្យស្នើសុំទាំងនោះមករដ្ឋបាលសុរិយោដី ខណ្ឌ ក្រុង[៤១] ។ អភិបាលក្រុង ស្រុក ខណ្ឌត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការ កំណត់ព្រំដីទៅអ្នកដាក្យពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈស្ថិតក្នុងកន្លែងដែលអាចមើលឃើញ និងងាយស្រួលស្វែងរកក្នុងរយៈពេលប្រាំពីរថ្ងៃ (០៧ថ្ងៃ) យ៉ាងតិចមុនកាលបរិច្ឆេទ នៃការកំណត់ព្រំដីនៅសាលាក្រុង ស្រុក ឬសាលាសង្កាត់ដែលភាគីអ្នកពាក់ព័ន្ធស្ថិតនៅក្នុងតំបន់ដែលធ្វើការចុះបញ្ជី[៤២]។

---

[៣៨] **នីតិវិធីក្នុងការដោះស្រាយវិវាទនៅគណៈកម្មការសុរិយោដីនឹងត្រូវអនុវត្ត** តាមអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

[៣៩] ប្រកាសអន្តរក្រសួងលេខ ៣៧៧ សហវ **ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី** ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២។

[៤០] អនុក្រឹត្យលេខ៤៨ អនក្រប,មាត្រា៧ **ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ**, ចុះថ្ងៃទី៣១ ឧសភា ២០០២, (តទៅហៅថា អនុក្រឹត្យលេខ៤៨)។

[៤១] សារាចរណែនាំស្តីពី**ការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ**, លេខ១៤ដនស/សរណន, ៣០ កញ្ញា ២០០៩, ដំណាក់កាលទី១ កថាខណ្ឌទី២ ( តទៅហៅថាសារាចរណែនាំលេខ១៤)។

[៤២] អនុក្រឹត្យលេខ៤៨,មាត្រា៨ **ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ**, ចុះថ្ងៃទី ៣១ ឧសភា ២០០២។

### ខ. កិច្ចប្រតិបត្តិការបច្ចេកទេស

នៅក្នុងដំណាក់កាលនេះត្រូវអនុវត្តជាពីរដំណាក់កាលគឺ ជំហានទី១ការអនុវត្តដោយមន្ត្រីជំនាញដោយសហការជាមួយអាជ្ញាធរមូលដ្ឋាននូវក្បាលដីដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី ហៅថាការងារវាល។ ជំហានទី២ការយកទិន្នន័យដែលបានមកពីជំហានទី១ទៅចងក្រង បញ្ចូលទៅក្នុងកុំព្យូទ័រហៅថាការងារការិយាល័យ។

ខ.១. ការងារវាល

ការងារបច្ចេកទេស ជាភារកិច្ចរបស់មន្ត្រីរដ្ឋបាលសុរិយោដី ដោយមានការណែនាំពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងថ្នាក់ដឹកនាំរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ព្រមទាំងមានអាជ្ញាធរមូលដ្ឋាន ( មេភូមិ និងមេឃុំ ចៅសង្កាត់ ) ជួយជ្រោមជ្រែងផងដែរ។ មន្ត្រីជំនាញដែលចាត់តាំងឲ្យទទួលបន្ទុកការងារវាលមានភារកិច្ចទទួលខុសត្រូវលើការងារកំណត់ព្រំដី វាស់វែង និងបំពេញទម្រង់បែបបទប្រមូលទិន្នន័យដើម្បីវិនិច្ឆ័យឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់។ មន្ត្រីទទួលបន្ទុកកំណត់ព្រំដីមានសិទ្ធិចូលក្នុងបរិវេណដី ដើម្បីកំណត់ព្រំ និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឲ្យផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឯកសារ និងបទបង្ហាញភ័ស្តុតាងផ្សេងៗទាក់ទងនឹងព្រំដីនោះ[៤៣]។ នៅក្នុងកិច្ចកំណត់ព្រំដី មន្ត្រីអនុវត្តន៍ទទួលបន្ទុកកំណត់ព្រំដី ត្រូវអនុវត្តតាមគោលការណ៍ដូចជា៖ ១.កំណត់ព្រំដីដោយផ្អែកលើការព្រមព្រៀងរវាងភាគីដែលជាប់ព្រំដីគ្នា ២.ករណីអវត្តមានភាគី ការកំណត់ត្រូវផ្អែកលើភស្តុតាង ដែលជាលក្ខណៈរូបជាលាយលក្ខណ៍អក្សរ និងភស្តុតាងផ្ទាល់មាត់ដែលទាក់ទងនឹងព្រំដី ៣.ករណីដីដែលស្នើសុំចុះបញ្ជីស្ថិតនៅជាប់នឹងដីសាធារណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវកំណត់តាមពីរចំណុចខាងលើ។ ម្ចាស់ដី និងអ្នកជិតខាងជាអ្នកចង្អុលបង្ហាញព្រំដីរបស់ខ្លួនទៅមន្ត្រីបច្ចេកទេស ( មន្ត្រីការងារវាល ) ចំណែកមន្ត្រីបច្ចេកទេសជាអ្នកមានភារៈខាងកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យជូនអ្នកកាន់កាប់ដី។

ខ.២. ការងារការិយាល័យ

រាល់បណ្តាសំណៅឯកសារទាំងឡាយណា ដែលទទួលបានពីការងារវាលត្រូវបានយកមកបញ្ចូលនៅក្នុងប្រព័ន្ធកុំព្យូទ័រដើម្បីធ្វើការគ្រប់គ្រងទិន្នន័យ និងកសាងផែនទីដោយមានបញ្ជីឈ្មោះម្ចាស់ដី ត្រៀមរៀបចំចុះក្នុងសៀវភៅគោលបញ្ជីរួចធ្វើប្លង់សុរិយោដីដើម្បីធ្វើចែកជូនប្រជាពលរដ្ឋ។

### គ. ការបិទផ្សាយជាសាធារណៈ

ការបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យ ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ នៅសាលាក្រុង ស្រុក ខណ្ឌដែលក្បាលដីនោះស្ថិតនៅ។ សេចក្តីចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយនៅសាលាឃុំ សង្កាត់ ដែល

[៤៣] សូមមើល **សារាចរណែនាំលេខ១៤**, ដំណាក់កាលទី២។

ក្បាលដីស្នើសុំចុះបញ្ជីស្ថិតនៅ។ ឯកសារវិនិច្ឆ័យដែលត្រូវបិទផ្សាយរួមមាន៖[៤៤] ផែនទីក្បាលដី គំនូសបង្ហាញទីតាំងក្បាលដី និងបញ្ជីឈ្មោះម្ចាស់ដីធ្លី។ អភិបាលក្រុង ស្រុក ខណ្ឌមានតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយឯកសារក្នុងការវិនិច្ឆ័យដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី។ សេចក្តីជូនដំណឹងនេះត្រូវធ្វើឡើងយ៉ាងតិច៣ (បី)ថ្ងៃមុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលអាចមើលឃើញនៅក្នុងភូមិ នៅសាលាឃុំ សង្កាត់ និងនៅសាលាក្រុង ស្រុក ខណ្ឌ[៤៥]។ អំឡុងពេលដែលបិទផ្សាយនេះ អ្នកកាន់កាប់ដី និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងក្បាលដីស្នើសុំចុះបញ្ជីអាចជូនដំណឹងពីការជំទាស់របស់ខ្លួនបាន ឬធ្វើបណ្តឹងជំទាស់បាន។ ប៉ុន្តែក្នុងករណីដែលមិនមានការជំទាស់ ឬតវ៉ាក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនេះទេ ទិន្នន័យដែលបានកត់ត្រាទុកក្នុងឯកសារដែលបានបិទផ្សាយនោះ ត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹត្យដែលអាចកំណត់យកជាផ្លូវការបាន។

### ឃ. ការសម្រេចលើឯកសារ

ក្រោយពីផុតរយៈពេលនៃកាលបរិច្ឆេទបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យរបស់មន្ត្រីជំនាញទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាមខ្លឹមសារដូចជា៖ លទ្ធផលនៃសម្រេចបាន មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើការវាយតម្លៃលើកសំណើរផ្តល់សិទ្ធិលើដីធ្លីជូនអ្នកកាន់កាប់ដែលបានស្នើសុំ និងត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវនឹងគ្មានទំនាស់ចូលក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ[៤៦]។មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវវាយតម្លៃនិងលើកសំណើរផ្តល់សិទ្ធិលើដី ឬអចលនវត្ថុជូនអ្នកកាន់កាប់ដីដែលបានស្នើសុំ។ អាជ្ញាធរទទួលខុសត្រូវលើការគ្រប់គ្រងតាមប្រភេទនីមួយៗមាន ភោគៈ សម្បទាន មិនត្រូវផ្តល់ប័ណ្ណជាលក្ខណៈឯកជន ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋដោយយោងតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ មន្ត្រីជំនាញទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវនិង គ្មានទំនាស់ចូលក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ។

ក្រោយពីផែនទីក្បាលដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីត្រូវបានកែតម្រូវរួចរាល់ហើយ មន្ត្រីជំនាញការងារវិនិច្ឆ័យត្រូវរៀបចំឯកសារដាក់ជូនរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌដើម្បីពិនិត្យ និងចុះហត្ថលេខាបញ្ជូនសំណុំរឿងទាំងមូលនេះ ទៅអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងធ្វើការបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត។ សំណុំឯកសារចាំបាច់ទាំងនោះរួមមាន៖ ពាក្យស្នើសុំចុះបញ្ជីដីធ្លី ឯកសារនៃការវិនិច្ឆ័យ (ឯកសារកំណត់ព្រំដី

---

[៤៤] **នីតិទ្រព្យសម្បត្តិ បណ្ឌិត សឿន សោភ័ណ** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០១៨។

[៤៥] **អនុក្រឹត្យលេខ១២១**, មាត្រា១៣។

[៤៦] **សារាចរណែនាំលេខ០១៤**, ដំណាក់កាលទី៤ ចំណុចទី១។

វាស់វែងដី ទម្រង់បែបបទប្រមូលទិន្នន័យក្បាលដីនិងផែនទីក្បាលដី ) និងសេចក្ដីជូនដំណឹងស្ដីអំពីកាលបរិច្ឆេទនៃការកំណត់វាស់វែងព្រំដី[៤៧]។ នៅពេលដែលអគ្គនាយដ្ឋានសុរិយោដី និងភូមិសាស្ត្រ ឬរដ្ឋបាលសុរិយោដីខេត្តក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកត់ត្រារួចក្នុងសៀវភៅគោលបញ្ជីដីធ្លី នោះក្បាលដីស្នើសុំនឹងត្រូវបានចុះបញ្ជី។

### ង. ការចេញប័ណ្ណ

ការចេញប័ណ្ណត្រូវអនុវត្តន៍ទៅតាមគោលការណ៍កំណត់ដូចខាងក្រោម៖

សិទ្ធិសម្រេចលើទម្រង់ឯកសារបែបបទនៃទិន្នន័យក្បាលដី និងការចេញប័ណ្ណជាសមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដីរាជធានី ខេត្ត។ រីឯសមត្ថកិច្ចវាស់វែង អាស្រ័យលើសមត្ថភាពបច្ចេកទេសរបស់មន្ត្រីមូលដ្ឋាន និងឧបករណ៍ប្រើប្រាស់ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(ប័ណ្ណកម្មសិទ្ធិ) ជូនម្ចាស់ដីដែលបានចូលកាន់កាប់មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ឬបានកាន់កាប់បន្តពីភាគីដើមមានលក្ខណៈត្រឹមត្រូវតាមច្បាប់ មិនមានការជំទាស់ មានរយៈពេលយ៉ាងតិចប្រាំឆ្នាំ(គិតដល់ថ្ងៃចូលកាន់កាប់ដល់ថ្ងៃចេញប័ណ្ណ)និងចំណុចព្រំក្បាលដីបានកសាងផែនទីក្បាលដីដែលមាននិយាមការច្បាស់លាស់។

ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ(ប័ណ្ណភោគៈ) ជូនម្ចាស់ដីដែលបានចូលកាន់កាប់មុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០១ ឬកាន់កាប់បន្តពីភាគីដើមមានលក្ខណៈត្រឹមត្រូវតាមច្បាប់មិនមានការជំទាស់ មានរយៈពេលតិចជាងប្រាំឆ្នាំ ( ០៥ឆ្នាំ ) ឬបានកាន់កាប់ចាប់ពី០៥ឆ្នាំឡើងតែចំណុចព្រំក្បាលដីមិនទាន់បានកសាងផែនទីក្បាលដីដែលមាននិយាមការច្បាស់លាស់។

សរុបមក ការចុះបញ្ជីដីធ្លីមានមានលក្ខណៈដាច់ដោយដុំ គឺជាដំណើរការនៃការចុះបញ្ជីដីធ្លីមួយប្រភេទដែលរដ្ឋផ្ដល់អាទិភាពដល់ប្រជាពលរដ្ឋ ឬកម្មសិទ្ធិករដែលជាម្ចាស់នៃដីស្របច្បាប់ដែលបានកាន់កាប់មុនពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ចូលជាធរមាន មានសិទ្ធិក្នុងការស្នើសុំការចុះបញ្ជីដីធ្លីរបស់ខ្លួនដើម្បីឲ្យច្បាប់ទទួលស្គាល់ និងការពារនូវដីធ្លីរបស់ពួកគាត់។ ថ្វីត្បិតតែរដ្ឋលើកកម្ពស់ និងផ្ដល់អាទិភាពដល់អ្នកដែលស្នើសុំចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំមែន ក៏មិនបានន័យថារដ្ឋជួយគ្រប់បែបគ្រប់យ៉ាងដែរទៅលើការចំណាយក្នុងការវាស់វែងដីធ្លីរបស់ប្រជាពលរដ្ឋ ពោលគឺកម្មសិទ្ធិករម្ចាស់នៃដីជាអ្នកបង់ថ្លៃសេវានៃការចុះបញ្ជីដីរបស់ខ្លួន។ គួយ៉ាងចំពោះការស្នើសុំចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ចំពោះដីធ្លីដែលមានទីតាំងឆ្ងាយលើសពី៥០គីឡូម៉ែត្រពីអង្គភាពសុរិយោដី ម្ចាស់នៃដីត្រូវទទួលបន្ទុកបន្ថែមលើ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ការហូបចុករបស់មន្ត្រីជំនាញ ថ្លៃបង្គោល និងការដាំបង្គោលព្រំ។ ប្រសិនបើតំបន់ព្រៃភ្នំ សោហ៊ុយនៃសេវាសុរិយោដីត្រូវគិត

[៤៧] សារាចរណែនាំលេខ ១៤ ដនស/សរណន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ***ស្ដីពីនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។***

បន្ថែម២០%លើសោហ៊ុយសេវាវាស់វែងសរុប[៤៤]។ ជាទូទៅ សម្រាប់ដំណើរការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ គឺមានរយៈពេល២ខែទៅ៣ខែ ឬ៤០ថ្ងៃទៅ៦០ថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃចុះប្រមូលទិន្នន័យរហូតដល់ថ្ងៃប្រគល់ប័ណ្ណ។

## ២.៣. សកម្មភាពចុះបញ្ជីដីបំពេញបន្ថែម

ដោយពិនិត្យឃើញថាក្រោយពីបានបញ្ចប់នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក្នុងតំបន់មួយចំនួនរួចមក នៅមានក្បាលដីខ្លះស្ថិតនៅក្នុងតំបន់នៃការវិនិច្ឆ័យ ប៉ុន្តែម្ចាស់កម្មសិទ្ធិករដីទាំងនោះមិនបានមកចូលរួមបំពេញបែបបទ ដើម្បីទទួលបានសិទ្ធិពេញលេញតាមការកំណត់។ ក្បាលដីទាំងនេះមានស្ថានភាពខុសៗគ្នាដោយមួយចំនួនត្រូវបានផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់តាមនីតិវិធីចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំឯមួយចំនួនទៀតត្រូវបានកាន់កាប់ត្រឹមត្រូវប៉ុន្តែមិនទាន់ត្រូវបានផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ឡើយ។ ទោះក្នុងករណីណាក៏ដោយ ការកាន់កាប់ស្របច្បាប់ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនេះ ត្រូវបានសម្រួលចូលក្នុងសៀវភៅគោលបញ្ជីដីធ្លីដើម្បីធានាសិទ្ធិពេញលេញតាមផ្លូវច្បាប់[៤៥]។ ដោយមានស្ថានភាពនៃក្បាលដីខ្លះស្ថិតនៅតំបន់វិនិច្ឆ័យ ម្ចាស់ដីបានចូលរួមសហការចុះបញ្ជីដីធ្លី ដើម្បីទទួលបានសិទ្ធិពេញលេញតាមការកំណត់ ការចុះបញ្ជីបំពេញបន្ថែមត្រូវបានបង្កើតឡើង ដើម្បីឲ្យម្ចាស់ក្បាលដីនៅតំបន់វិនិច្ឆ័យដែលបានចូលរួមនោះអាចដាក់ពាក្យស្នើសុំចុះបញ្ជីបំពេញបន្ថែមទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់។

ការចុះបញ្ជីបំពេញបន្ថែម ត្រូវបានបង្កើតឡើងដោយ សារាចរណែនាំលេខ០៦ សណន ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម(បន្ទាប់ពីនេះហៅថាសារាចរណែនាំលេខ០៦) យោងតាមខ្លឹមសារនៃសារាចរណែនាំនេះ ការចុះបញ្ជីដីធ្លីបំពេញបន្ថែមបានបែងចែក នឹងញែកចេញនូវលក្ខខណ្ឌ ដំណាក់កាលនឹងគោលការណ៍មួយចំនួនដូចជា៖ (២.៣.១)ការចុះបញ្ជីដីបំពេញបន្ថែមធ្វើឡើងក្នុងគោលបំណង និងភាពចាំបាច់មួយចំនួន (២.៣.២)លក្ខខណ្ឌដែលតម្រូវឲ្យមានការចុះបញ្ជីដីធ្លីបំពេញបន្ថែម (២.៣.៣)និងព្រមទាំងនីតិវិធីដំណើរការនៃការចុះបញ្ជីនេះផងដែរ។

ដើម្បីឲ្យមានភាពងាយស្រួលនឹងកាន់តែច្បាស់លាស់ ក៏ដូចជាស្វែងយល់ឲ្យកាន់តែមានភាពស៊ីជម្រៅទៅលើគោលបំណង ភាពចាំបាច់ លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីបំពេញបន្ថែមនេះ យើងខ្ញុំនឹងធ្វើការបកស្រាយក៏ដូចជាធ្វើការសិក្សាទៅលើចំណុចគោលការណ៍ទាំងបីខាងលើនេះ ដើម្បីធ្វើឲ្យមានភាពប្រសើរឡើងនូវក្នុងអត្ថបទសារណាមួយនេះដូចតទៅ។

[៤៤] សេចក្តីសម្រេចលេខ៥១សសរ, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦, ស្តីពីសេវាសុរិយោដី, ប្រការ២ កថាខណ្ឌ២។
[៤៥] សារាចរណែនាំលេខ ០៦ សណន **ស្តីពី គោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។

### ២.៣.១. គោលបំណង និងភាពចាំបាច់

ដោយពិនិត្យមើលឃើញពីការគ្រប់គ្រង និងការកាន់កាប់ឯកសារនៅមិនទាន់មានការឯកភាពគ្នានៅឡើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី បានចេញនូវសារាចរណែនាំស្តីពីការ ចុះបញ្ជីដីបំពេញបន្ថែម ក្នុងគោលបំណងពង្រឹងនូវការកាន់កាប់ឯកសារទាំងនេះឲ្យកាន់តែមានភាពសុក្រឹត្យថែមទៀត។ ការចុះបញ្ជីដីបំពេញបន្ថែម ជាការចុះបញ្ជីដីធ្លីមួយប្រភេទដែលត្រូវបានបង្កើតឡើងដើម្បីបំពេញនូវភាពខ្វះចន្លោះដែលក្រោយពីបានបញ្ចប់នីតិវិធីចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំម្ចាស់នៃក្បាលដីមួយចំនួនដែលមិនទាន់ចូលរួមមកបំពេញបែបបទតាមការកំណត់ និងក្បាលដីមួយចំនួនបានកាន់កាប់ត្រឹមត្រូវតែមិនទាន់ត្រូវបានផ្តល់ប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិនៅឡើយ[៥០]។ ការចុះបញ្ជីដីធ្លីបំពេញបន្ថែមបានបង្ករជាភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិករនៃដី ដើម្បីធ្វើការស្នើសុំការចុះបញ្ជីដីធ្លីរបស់ខ្លួនស្របច្បាប់ និងអាចការពារបាននូវកម្មសិទ្ធិដីធ្លីរបស់តាមការកំណត់របស់ច្បាប់។

### ២.៣.២. លក្ខខណ្ឌដែលតម្រូវឲ្យមានការចុះបញ្ជីដីធ្លីបំពេញបន្ថែម

ដោយមានស្ថានភាពនៃក្បាលដីខ្លះ ស្ថិតនៅតំបន់នៃការវិនិច្ឆ័យ ម្ចាស់ដីបានចូលរួមសហការចុះបញ្ជីដីធ្លីដើម្បីទទួលបានសិទ្ធិពេញលេញតាមការកំណត់ ការចុះបញ្ជីដីធ្លីបំពេញបន្ថែមត្រូវបានបង្កើតឡើងដើម្បីឲ្យម្ចាស់ក្បាលដីនៅតំបន់វិនិច្ឆ័យ ដែលអាចចូលរួមដាក់ពាក្យស្នើសុំចុះបញ្ជីបំពេញបន្ថែមទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់។ដើម្បីឲ្យការចុះបញ្ជីដីបំពេញបន្ថែមអាចដំណើរការ ឬប្រព្រឹត្តិទៅបាននោះតម្រូវឲ្យបុគ្គលជាម្ចាស់នៃអចលនវត្ថុ ឬដីធ្លី ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា[៥១]៖

**ក. ប្រភេទក្បាលដី ៖** ក្បាលដីដែលអាចអនុញ្ញាតឲ្យមានការចុះបញ្ជីបំពេញបន្ថែមបាន គឺជាក្បាលដីដែលស្ថិតនៅក្នុងតំបន់នៃការវិនិច្ឆ័យ ដែលភាគីម្ចាស់នៃក្បាលដីមិនបានចូលរួមក្នុងពេលនៃការអនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) ឬកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) ដោយសារអវត្តមាន ឬមានការអាក់ខានដោយសារមូលហេតុសំខាន់ផ្សេងៗ ដែលជាហេតុធ្វើឲ្យមិនបានចូលរួមក្នុងការចុះបញ្ជីដីធ្លីរបស់ខ្លួនខណៈពេលដែលការចុះបញ្ជីជាប្រព័ន្ធកំពុងតែអនុវត្តន៍ស្ថិតនៅក្នុងតំបន់ដែលខ្លួនរស់នៅ។

**ខ. ការដាក់ពាក្យ ៖** ម្ចាស់អចលនវត្ថុដែលមិនបានចូលរួមបំពេញបែបបទតាមការកំណត់ក្នុងពេលមានការប្រកាសតំបន់វិនិច្ឆ័យ និងកិច្ចដំណើរការអនុវត្តនីតិវិធីមានលក្ខណៈជាប្រព័ន្ធ ដោយសារមានមូលហេតុសមស្រប ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជី មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល តាមរយៈមេឃុំ ចៅសង្កាត់ នៃឃុំ សង្កាត់ដែលជាទីតាំងនៃដីស្ថិតនៅ។

---

[៥០] **ហាប់ ផល្លី** កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដីធ្លី ( ភ្នំពេញ ២០១០ )៨២៥។

[៥១] សារាចរណែនាំលេខ ០៦ សណន **ស្តីពី គោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។

### ២.៣.៣. សេវានៃការចុះបញ្ជីដីបំពេញបន្ថែម

នៅក្នុងនីតិវិធីនៃការចុះបញ្ជីដីបំពេញបន្ថែមនេះ គឺដូចគ្នាទៅនឹងការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំដែរ គឺម្ចាស់ដីត្រូវដាក់ពាក្យស្នើសុំទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលតាម រយៈមេឃុំ ចៅសង្កាត់ដែលទីតាំងដីនោះស្ថិតនៅ។ បន្ទាប់មកការិយាល័យជំនាញចុះត្រួតពិនិត្យបច្ចេកទេស និងការកំណត់ព្រំវាស់វែង កសាងនិងប្រមូលទិន្នន័យ រួចធ្វើការបិទផ្សាយជាសាធារណៈនូវទិន្នន័យនៃការវិនិច្ឆ័យដែលប្រមូលបាននៅឃុំ សង្កាត់ និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ។ យើងនឹងធ្វើការសិក្សាបន្ថែមលើនីតិវិធី និងតួនាទីភារកិច្ចរបស់អ្នកដែលពាក់ព័ន្ធនីមួយៗដូចខាងក្រោម៖

**ក. ការដាក់ពាក្យស្នើសុំ៖** ដូចបានលើកឡើងខាងលើស្រាប់ ម្ចាស់ដីជាអ្នកស្នើសុំធ្វើប្លង់កម្មសិទ្ធិនេះដោយផ្ទាល់។ ក្នុងការដាក់ពាក្យម្ចាស់ដីត្រូវដាក់ពាក្យសុំទៅការិយាល័យសុរិយោដីស្រុក ខណ្ឌដែលទីតាំងនោះស្ថិតនៅ។ ប៉ុន្តែមុនស្នើសុំដល់ថ្នាក់ស្រុក ខណ្ឌ ម្ចាស់ដីត្រូវធ្វើលិខិតបញ្ជាក់ចេញពីមេឃុំ ចៅសង្កាត់ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណនៃការប្រើប្រាស់ដី និងការទទួលស្គាល់ពីថ្នាក់មូលដ្ឋានជាមុនសិន។ ពេលដែលមានការដាក់ពាក្យស្នើសុំធ្វើការចុះបញ្ជី មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យលក្ខណៈសមស្រប និងផ្តល់យោបល់ ( អនុវត្តដូចគ្នាទៅនឹងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ) រួចបញ្ជូនសំណុំរឿងទៅកាន់រដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ[៥២]។

**ខ. កិច្ចការបច្ចេកទេស៖** ក្រោយពេលទទួលបានការដាក់ពាក្យស្នើសុំចុះបញ្ជីបំពេញបន្ថែមពីមេឃុំ ចៅសង្កាត់រួច រដ្ឋបាលសុរិយោដីស្រុកក្រុងខណ្ឌ ត្រូវចាត់ការត្រួតពិនិត្យលក្ខណៈសមស្រប ក្នុងករណីដែលពាក្យសុំមានលក្ខណៈគ្រប់គ្រាន់ ឬសមស្របហើយរដ្ឋបាលសុរិយោដី ត្រូវរាយការណ៍ជូនអភិបាលស្រុក ខណ្ឌដើម្បីផ្តល់ជាយោបល់ និងសហការចុះត្រួតពិនិត្យទិដ្ឋភាពបច្ចេកទេសហើយកំណត់ព្រំដីវាស់វែងនឹងកសាងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីដែលបានស្នើសុំ[៥៣]។ ទោះបីជាយ៉ាងណា ការវាស់វែងអាចធ្វើទៅបានប្រសិនបើមិនមានការជំទាស់តវ៉ាពីម្ចាស់ដីដែលមានព្រំប្រទល់ជាប់គ្នា។ ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងសងខាងអាចដោះស្រាយគ្នាបាននៅត្រឹមថ្នាក់មូលដ្ឋានដោយមានគណៈកម្មការឃុំ សង្កាត់ ជាអ្នកសម្របសម្រួល។

**គ. ការបិទផ្សាយជាសាធារណៈ ៖** ក្រោយពីរៀបចំសំណុំឯកសារគ្រប់គ្រាន់ហើយ ត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវទិន្នន័យដែលប្រមូលបានក្នុងរយៈពេល៣០ថ្ងៃ នៅសាលាសង្កាត់ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុកខណ្ឌ។ រាល់អ្នកដែលមានប្រយោជន៍ទាក់ទងនឹងដីធ្លីអាចធ្វើការ

[៥២] ប្រកាសអន្តរក្រសួងលេខ២១៥ ប្រក/ដនស/មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី មាត្រា៣ ដលមាត្រា៦ ។

[៥៣] សារាចរណែនាំលេខ០៦ សណន ស្តីពី គោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦,កថាខណ្ឌ ១,ចំណុច៤ ។

ជំទាស់ ឬតវ៉ាបាននៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុក ខណ្ឌ។ ក្នុងករណីដែលមានកំហុសខុសឆ្គងរបស់មន្ត្រីជំនាញ ការកែតម្រូវត្រូវអនុវត្តន៍តាមសមត្ថកិច្ច និងគោលការណ៍ដែលមានចែងនឹងកំណត់ដោយអនុក្រឹត្យផ្សេងៗដែលពាក់ព័ន្ធ[៥៤]។

**ឃ. ការសម្រេចលើឯកសារ ៖** ក្រោយពីទទួលបានការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ត្រូវធ្វើរបាយការណ៍បូកសរុបផ្តល់យោបល់ នឹងបញ្ជូនសំណុំរឿងមកអភិបាលស្រុក ខណ្ឌដើម្បីសុំយោបល់ ហើយបញ្ជូនបន្តមកមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្ត ក្រុង ដើម្បីពិនិត្យបន្ថែមលើលក្ខណៈបច្ចេកទេសរួចទើបបញ្ជូនទៅអាជ្ញាធររាជធានី ខេត្ត វិញដើម្បីធ្វើការសុំយោបល់សម្រេច ហើយបញ្ជូនត្រឡប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលវិញដើម្បីធ្វើការចុះបញ្ជី និងចេញប័ណ្ណសម្គាល់កម្មសិទ្ធិជូនអ្នកស្នើសុំ។

**ង. ការចុះបញ្ជី និងការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ៖** ការចុះបញ្ជី និងការផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ គឺជាសមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដោយអនុវត្តតាមគោលការណ៍ដែលបានកំណត់ (អនុវត្តន៍ដូចគ្នានឹងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ) ហើយធ្វើការបោះពុម្ពផ្តល់ប័ណ្ណសម្គាល់សិទ្ធកាន់កាប់ជូនម្ចាស់ក្បាលដីដែលបានដាក់ពាក្យស្នើសុំនោះ។ ចំពោះដំណើរការនៃការចុះបញ្ជីដីធ្លីបំពេញបន្ថែម ត្រូវអនុវត្តដោយមានការសហការគ្នារវាងមន្ត្រីរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ និងមន្ត្រីគ្រប់គ្រងទិន្នន័យឌីជីថលរាជធានី ខេត្ត ព្រោះថារាល់ឯកសារមួយចំនួនត្រូវស្រង់ចេញពីលទ្ធផលនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធលើកមុនដើម្បីធ្វើការកំណត់ព្រំហើយក៏ត្រូវប្រមូលទិន្នន័យក្បាលដីថ្មីដែលស្នើសុំនោះ ដើម្បីធ្វើការចុះបញ្ជីដីធ្លី និងចេញប័ណ្ណផងដែរ។

## ២.៤ ប្រភេទនៃវិវាទដីធ្លី

បញ្ហានៃវិវាទដីធ្លី គឺជារបៀបវារៈមួយដែលមានការយកចិត្តទុកដាក់បំផុតចំពោះប្រទេសដែលកំពុងអភិវឌ្ឍន៍ ដើម្បីជៀសវាងនូវវិបត្តិឬវិវាទដីធ្លីដែលកើតមានឡើង។ការគិតគូរពីបញ្ហានេះយោងទៅតាមប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី ច្បាប់ និងប្រព័ន្ធនយោបាយផ្សេងៗគ្នា។ វិវាទដែលកើតឡើងក្នុងកំឡុងពេលអនុវត្តការងារចុះបញ្ជី គឺជាបញ្ហាស្នូលមួយដែលបង្ករជាភាពរាំងស្ទះក្នុងដំណើរការវាស់វែងដីធ្លី។

វិវាទធ្វើឲ្យមានការខាតបង់ទាំងពេលវេលា ទំនុកចិត្តលើគ្នាទៅវិញទៅមក ប្រាក់កាសរបស់ប្រជាពលរដ្ឋក៏ដូចជារដ្ឋាភិបាលដែរសម្រាប់ដោះស្រាយជូនប្រជាពលរដ្ឋ។ វិវាទដីធ្លីជាធម្មតាកើតឡើងបណ្តាលមកពីការមិនយោគយល់គ្នា មិនស្មោះត្រង់ មិនទុកចិត្តមន្ត្រីជំនាញក្នុងការទទួលបន្ទុកចុះបញ្ជីដីធ្លី។ នៅក្នុងចំណុចខាងក្រោម

[៥៤] អនុក្រឹត្យលេខ៤៦ ***ស្តីពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី*** ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥, មាត្រា១១ កថាខណ្ឌ៣ ។

នេះ យើងនឹងធ្វើការសិក្សាទៅលើប្រភេទនៃវិវាទដីធ្លី ដែលជារឿយៗតែងតែកើតមានឡើងក្នុងពេលដែលរដ្ឋាភិបាល ប្រកាសឲ្យមានការចុះបញ្ជីដីធ្លីម្តងៗនៅកម្ពុជា។

### ២.៤.១. សភាពនៃវិវាទដីធ្លី

ក្រោមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ភូមិបាលឆ្នាំ២០០១ រដ្ឋទទួលខុសត្រូវលើការការពារ សិទ្ធិកម្មសិទ្ធិឯកជន។ បុគ្គលម្នាក់អាចនឹងត្រូវដកហូតសិទ្ធិកម្មសិទ្ធិ លុះត្រាណាតែការដកហូតនោះត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៍សាធារណៈ និងបន្ទាប់ពីការទទួលសំណងដោយសមរម្យ និងយុត្តិធម៌។ ភស្តុតាងជាក់ស្តែងបំភុតនៃកម្មសិទ្ធិ គឺប័ណ្ណកម្មសិទ្ធិដីធ្លី ប៉ុន្តែប្រជាជនកម្ពុជាជាច្រើនជាម្ចាស់ដី នៅតែមិនមានប័ណ្ណកម្មសិទ្ធិផ្លូវការ និងពឹងផ្អែកលើប្លង់ទន់ជំនួសវិញ។ នៅពេលគ្មានប័ណ្ណកម្មសិទ្ធិផ្លូវការ ម្ចាស់ដីប្រឈមនឹងហានិភ័យជាច្រើនបានពាក់ព័ន្ធក្នុងវិវាទដីធ្លី។ ខាងក្រោមនេះ យើងនឹងធ្វើការសិក្សាទៅលើប្រភេទនៃវិវាទដីធ្លីដែលតែងតែកើតមានឡើងនៅពេលទទួលសេវា ឬស្នើសុំសេវាចុះបញ្ជីដីធ្លី។

### ២.៤.២. វិវាទក្នុងកំឡុងពេលវាស់វែង

ជាការពិតណាស់ នៅក្នុងដំណើរការនីតិវិធីដំណាក់កាលបច្ចេកទេសក្នុងការចុះបញ្ជីដីធ្លី គឺជាឧបសគ្គមួយផងដែរ ដែលបង្កជាការរាំងស្ទះយ៉ាងខ្លាំងក្នុងការអនុវត្តការងាររបស់រដ្ឋបាលសុរិយោដីអាជ្ញាធរមូលដ្ឋាន មន្ត្រីជំនាញដែលពាក់ព័ន្ធ និងក្បាលដីដែលត្រូវកំណត់នោះ។ នៅក្នុងដំណាក់កាលបច្ចេកទេសនេះ គឺតម្រូវឲ្យភាគីពាក់ព័ន្ធទាំងអស់ ចូលរួមសហការគ្នាក្នុងប្រតិបត្តិការជាមួយមន្ត្រីជំនាញ និងមន្ត្រីនៅតាមមូលដ្ឋាន ដែលត្រូវបែងចែកជាពីរទៀតគឺ មន្ត្រីការងារវាល និងមន្ត្រីការងាការិយាល័យ។ នៅក្នុងការអនុវត្តការងារនីមួយៗ សុទ្ធតែជួបប្រទះនូវបញ្ហា ឬឧបសគ្គណាមួយជាក់ជាមិនខានឡើយ។ ក្នុងនោះយើងសង្កេតឃើញថា វិវាទជារឿយៗ តែងតែកើតមានឡើងក្នុងពេលកំពុងតែបំពេញភារកិច្ចរបស់មន្ត្រីជំនាញ ដែលអាចកើតមានឡើងរវាងម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិ ឬរវាងម្ចាស់កម្មសិទ្ធិជាមួយនិងមន្ត្រីជំនាញផងដែរ ក្នុងករណីដែលម្ចាស់កម្មសិទ្ធិមិនយល់ស្របចំពោះការសម្រេច ឬទទួលស្គាល់នូវលទ្ធផលដែលបានកំណត់ដោយមន្ត្រីជំនាញ ឬមន្ត្រីសុរិយោដីក្នុងការវាស់វែងក្បាលដីរបស់ខ្លួននោះ។ លើសពីនេះទៅទៀត វិវាទដីធ្លីនេះគឺកើតឡើងដោយសារតែក្បាលដីនោះគឺបានមានវិវាទជាយូរមកហើយឬកំពុងតែមានវិវាទហើយដែលមិនទាន់បានដោះស្រាយរួចរាល់ហើយដាច់ស្រេច ជាហេតុធ្វើឲ្យភាគីម្ចាស់កម្មសិទ្ធិទាំងសងខាងមិនពេញចិត្ត មិនព្រមព្រៀងតាមការសម្រុះសម្រួល និងតាមការសម្រេចរបស់មន្ត្រីជំនាញ។

ជារួមមក ការងាររបស់មន្ត្រីវាលបានជួបប្រទះនូវបញ្ហាជាច្រើនដែលអាចនឹងកើតមានឡើង ដែលវាជាឧបសគ្គក្នុងការរាំងស្ទះដំណើរការនៃការអនុវត្តនីតិវិធីចុះបញ្ជីដីធ្លីឯកជននៅកម្ពុជា។ វិវាទដីធ្លីក្នុងកំឡុងពេលចុះកំណត់ព្រំដីនេះ គឺកើតមានឡើងភ្លាមៗ ហើយធ្វើការតវ៉ាភ្លាមៗផងដែរក្នុងពេលកំពុងប្រតិបត្តិការ ដែលយើងដឹង

ហើយថាវិវាទនេះ គឺកើតឡើងដោយសារការមិនយល់ស្របគ្នារវាងម្ចាស់ភាគីកាន់កាប់ដីទាំងសងខាង។ ប្រសិនបើមិនអាចធ្វើការដោះស្រាយបាន និងសម្រុះសម្រួលបានទេ មន្ត្រីការងារវាលនឹងបញ្ជូនសំណុំឯកសារដែលពាក់ព័ន្ធនឹងវិវាទនោះទៅកាន់គណៈកម្មការរដ្ឋបាលធ្វើការសម្រុះសម្រួល និងដោះស្រាយនៅពេលប្រកាសបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យ[៥៥]។

### ២.៤.៣. វិវាទទាក់ទងនិងទិន្នន័យនៃការវិនិច្ឆ័យ

បើយើងលើកឡើងពីវិវាទដែលមានការទាក់ទងនិងលទ្ធផល ច្បាស់ណាស់ប្រាកដជាទិន្នន័យ ក៏ដូចជាលទ្ធផលដែលបានស្រង់បានពីមន្ត្រីការងារវាល នៅក្នុងដំណាក់កាលបច្ចេកទេសជាក់ជាមិនខានឡើយ។ លទ្ធផលនៃការវិនិច្ឆ័យ គឺជាការងារមួយដែលស្ថិតនៅក្នុងការងារការិយាល័យ ដែលតម្រូវឲ្យមន្ត្រីជំនាញ ស្រង់ទិន្នន័យដែលទទួលបានមកពីការវិនិច្ឆ័យ ការកំណត់ព្រំប្រទល់នៃក្បាលដី និងទិន្នន័យដែលបានមកពីការវាស់វែងរបស់មន្ត្រីការងារវាល។ នៅក្នុងដំណាក់កាលនៃការប្រកាសបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការវិនិច្ឆ័យ វាគឺជាដំណាក់កាលមួយដែលអាចនាំឲ្យវិវាទដីធ្លីកើតឡើងភ្លាមៗ ទោះបីជាមានការវាស់វែង ការកំណត់ព្រំដី និងការវិនិច្ឆ័យរួចរាល់ហើយក្តី។ វិវាទនេះ គឺអាចកើតឡើងក្នុងកំឡុងពេល នៃការអនុវត្តការងាររបស់មន្ត្រីជំនាញ ឬមន្ត្រីការងារវាលក្នុងដំណាក់កាលបច្ចេកទេសដែលបណ្តាលមកពីការភ័ន្តច្រឡំ ការធ្វេសប្រហែស ក៏ដូចជាស្ថានភាពនៃដីដែលជាហេតុធ្វើឲ្យមានការបាត់បង់ប្រវែងក្បាលដីបន្តិចបន្តួចជាហេតុធ្វើឲ្យមានការតវ៉ាសុំឲ្យកែតម្រូវនូវបញ្ហានេះទៅកាន់គណៈកម្មការសុរិយោដី ក៏ដូចជារដ្ឋបាលសុរិយោដី បានបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងធ្វើការផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យដែលមានកំហុសឆ្គង និងទិន្នន័យដែលមានការបាត់បង់។ ដូចនេះ ម្ចាស់កម្មសិទ្ធិអាចធ្វើការប្តឹងតវ៉ាដើម្បីឲ្យមានការកែតម្រូវឡើងវិញ ប្រសិនបើមានភ័ស្តុតាងនិងឯកសាររបស់ម្ចាស់កម្មសិទ្ធិមានគ្រប់គ្រាន់ និងអាចយកជាផ្លូវការក្នុងការកែតម្រូវទិន្នន័យនោះ។

## ២.៥. យន្តការដោះស្រាយវិវាទដីធ្លី

អនុលោមតាមស្មារតីប្រកាសអន្តរក្រសួងលេខ ០២ ប្រកច.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លី បានបែងចែកជាវិវាទដីធ្លីជា ០២ (ពីរ) ប្រភេទគឺ ១៖ វិវាទដីធ្លីដែលបានចុះបញ្ជីរួចហើយ គឺដីធ្លីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិ ( ប័ណ្ណដីធ្លី ) កាន់កាប់គ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការ និង២៖វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី គឺដីធ្លីដែលពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិ កាន់កាប់គ្រប់ប្រភេទដែលចេញដោយរដ្ឋ

[៥៥] អនុក្រឹត្យលេខ៤៦, មាត្រា៧ថ្មី, កថាខណ្ឌ៦ និងសារាចរលេខ០០១ ដនស/សជ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ **ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ។**

បាលសុរិយោដី ត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីជាអ្នកធ្វើការសម្រុះសម្រួលនឹងដោះស្រាយវិវាទនេះ។

### ២.៥.១. ការដោះស្រាយដោយគណៈកម្មការសុរិយោដីចំពោះដីមិនទាន់ចុះបញ្ជី

ការដោះស្រាយទំនាស់ដីធ្លី គឺអាស្រ័យថាតើដីនោះបានចុះបញ្ជី ឬមិនទាន់បានចុះបញ្ជី។ តើយើងប្រើយន្តការបែបណាខ្លះដើម្បីការពារនិងធានាសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ? ផ្អែកតាមច្បាប់ភូមិបាល និងអនុក្រឹត្យលេខ៤៦ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី(២០០២) និងអនុក្រត្យលេខ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មានយន្តការសម្រាប់ដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ រួមមានប្រាំថ្នាក់ដែលយើងនឹងធ្វើការសិក្សានិងបកស្រាយដូចមានខាងក្រោម៖

#### ២.៥.១.១. ក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងករណី មានទំនាស់កើតឡើងក្នុងតំបន់របស់លោកអ្នក ដំបូងគឺអ្នកអាចដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានតួនាទីជាអ្នកសម្រុះសម្រួលនៅថ្នាក់មូលដ្ឋានមុនពេលករណីវិវាទនោះបញ្ជូនបន្តទៅថ្នាក់លើ ( ដូចជាគណៈកម្មការសុរិយោដីជាដើម )។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកប្រមូលគំនិតយោបល់ផ្សេងៗរបស់ប្រជាពលរដ្ឋក្នុងឃុំសង្កាត់ ប៉ុន្តែគ្មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចនោះទេ។ នៅពេលគ្មានសេចក្តីសម្រេចជាមុនតាមការអនុវត្តជាក់ស្តែង ករណីភាគច្រើនគ្រាន់តែធ្វើសវនកម្មនៅមុខក្រុមប្រឹក្សាឃុំ សង្កាត់ មុនពេលបញ្ជូនបន្តទៅថ្នាក់លើ។

#### ២.៥.១.២. គណៈកម្មការរដ្ឋបាល

គណៈកម្មការរដ្ឋបាលត្រូវបានបង្កើតឡើង សម្រាប់គ្រប់ផ្នែកទាំងអស់ដែលស្ថិតនៅក្រោមកម្មវិធីចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធ ហើយគណៈកម្មការនេះគឺជាកន្លែងដោះស្រាយជម្លោះដំបូងសម្រាប់ជម្លោះទាំងឡាយណា ដែលកើតឡើងកំឡុងពេលដំណើរការចុះបញ្ជីដី។ គណៈកម្មការរដ្ឋបាល ធ្វើប្រតិបត្តិការនៅគ្រប់តំបន់នានា ហើយករណីដំបូងដែលកើតឡើងនៅក្នុងកំឡុងពេលយុទ្ធនាការចុះបញ្ជីដីធ្លីឧបត្ថម្ភដោយរដ្ឋាភិបាល[៥៦]។ គណៈកម្មការរដ្ឋបាល មិនមានអំណាចក្នុងការចេញសេចក្តីសម្រេចទេ គឺគ្រាន់តែអាចផ្តល់ជាជំនួយដល់ភាគីវិវាទទាំងសងខាងក្នុងការចូលរួមដោះស្រាយជម្លោះតែប៉ុណ្ណោះ[៥៧]។ ក្នុងករណីដែលគណៈកម្មការរដ្ឋបាលមិនអាចធ្វើការសម្រុះសម្រួល ឬដោះស្រាយជម្លោះបានទេ គណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនសំណុំរឿងនេះទៅកាន់គណៈកម្មការសុរិយោដីដើម្បីធ្វើការដោះស្រាយ និងសម្រុះសម្រួលជាបន្តទៀត។ បើទោះបីជាគណៈកម្មការរដ្ឋបាល ពុំមាន

[៥៦] **យន្តការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា** រក្សាសិទ្ធិដោយ វិទ្យាស្ថានសភាកម្ពុជា ។

[៥៧] សមាសភាព និងតួនាទីភារកិច្ចនៃគណៈកម្មការរដ្ឋបាល មានចែងនៅក្នុងអនុក្រឹត្យលេខ ៤៦ ស្តីពី **និតិវិធីនៃសាងសង់ប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី** ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២។

សិទ្ធិអំណាចចេញសេចក្តីសម្រេចចងកាតព្វកិច្ចក្តី ក៏អាចជួយភាគីមានជម្លោះក្នុងការដោះស្រាយទំនាស់នោះបានផងដែរ។ តាមច្បាប់ភូមិបាលឆ្នាំ២០០១ តម្រូវឲ្យភាគីវិវាទលើបញ្ហាដីធ្លី ដែលមិនទាន់បានចុះបញ្ជី ត្រូវដាក់ទៅគណៈកម្មការសុរិយោដី ដើម្បីធ្វើការស៊ើបអង្កេត និងដោះស្រាយ ក៏ប៉ុន្តែ ប្រសិនបើភាគីជម្លោះនៅតែមិនពេញចិត្ត គេអាចដាក់ពាក្យបណ្តឹងទៅតុលាការបានផងដែរ[៥៨]។

### ២.៥.១.៣. គណៈកម្មការសុរិយោដី

យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ បញ្ជាក់ថាវិវាទទាំងឡាយណាដែលពាក់ព័ន្ធនឹងដីមិនទាន់ចុះបញ្ជីគប្បីបញ្ជូនទៅគណៈកម្មការសុរិយោដីដែលជាស្ថាប័នដោះស្រាយវិវាទដែលត្រូវបង្កើតឡើង ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការសុរិយោដី មានភារកិច្ចទទួលខុសត្រូវក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹងដីធ្លីដែលមិនទាន់ចុះបញ្ជីដែលកើតឡើងនៅក្រៅតំបន់នៃការវិនិច្ឆ័យ ក៏ដូចជា វិវាទទាំងឡាយណាដែលកើតឡើងនៅក្នុងអំឡុងពេលដំណើរការនៃការវិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល និងមិនមែនជាវិវាទដីធ្លីដែលពាក់ព័ន្ធនឹង បណ្តឹងទាមទារបែងចែកមរតក ឬវិវាទអំពីកិច្ចសន្យាទិញលក់ ជួល ឬបញ្ចាំជាដើម។ គណៈកម្មការរដ្ឋបាលសុរិយោដីគ្មានយុត្តាធិការលើវិវាទដីធ្លីពាក់ព័ន្ធនឹងដីចុះបញ្ជីទេ ហើយវិវាទបែបនោះត្រូវតែជំនុំជម្រះដោយតុលាការ។ គណៈកម្មការសុរិយោដីធ្វើការដោះស្រាយវិវាទដីធ្លីនីមួយៗដោយចាប់ផ្តើមពីថ្នាក់ស្រុក ខណ្ឌ ឡើងទៅថ្នាក់រាជធានី ខេត្ត និងចុងក្រោយទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ គណៈកម្មការសុរិយោដី បែងចែកចេញជាបីថ្នាក់ (៣) គឺគណៈកម្មការសុរិយោដីថ្នាក់ក្រុងស្រុកខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្ត និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ[៥៩]។

### ក. ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

ការទទួលពាក្យបណ្តឹង និងឆ្លើយតបពាក្យបណ្តឹង៖ បុគ្គលគ្រប់រូបដែលមានវិវាទពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីមានសិទ្ធិ ដាក់ពាក្យបណ្តឹងដោយផ្ទាល់ ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ។ បន្ទាប់មកគណៈកម្មការនឹងជូនដំណឹងអំពីបណ្តឹងទៅភាគីចុងបណ្តឹង ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធនឹងដីវិវាទដើម្បីឆ្លើយតបក្នុងរយៈពេល៣០ ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹង។

ការស៊ើបអង្កេតបន្ទាប់ពីទទួលពាក្យបណ្តឹង៖ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងចាត់មន្ត្រីឱ្យចុះស៊ើបអង្កេត ដើម្បីជួបជាមួយគូភាគីវិវាទ សាក្សី អាជ្ញាធរមូលដ្ឋាន និងធ្វើការវាស់វែងកំណត់ទំហំដី និងព្រំប្រទល់ដីវិវាទឱ្យបានច្បាស់លាស់។ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតគណៈកម្មការសុរិយោដីនឹងពិនិត្យមើលថា តើ

---

[៥៨] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៤៧។

[៥៩] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពី ***ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី*** ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, មាត្រា៤, ទំព័រទី ២។

ករណីវិវាទនោះស្ថិតក្នុងសមត្ថកិច្ចដោះស្រាយរបស់ខ្លួនឬទេ? ករណីមិនស្ថិតក្នុងសមត្ថកិច្ចបណ្តឹងនោះត្រូវបានច្រានចោល ហើយត្រូវជូនដំណឹងដល់ភាគីវិវាទជាលាយលក្ខណ៍អក្សរ។ ករណីភាគីវិវាទមិនពេញចិត្តចំពោះការច្រានចោលនោះ ភាគីវិវាទនោះអាចប្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់លើ បន្ទាប់ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីភាគីទទួលបានសេចក្តីជូនដំណឹង ឬទម្រង់បែបបទច្រានចោលពាក្យបណ្តឹងនោះ។

**អំពីកិច្ចប្រជុំរដ្ឋបាល៖** គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញគូភាគីវិវាទចូលរួមប្រជុំរដ្ឋបាលដើម្បីណែនាំអំពីដំណើរការ និងនីតិវិធីនៃការដោះស្រាយវិវាទ។ ភាគីត្រូវធ្វើការជ្រើសរើសអ្នកសម្រុះសម្រួល ៣រូប និងទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើស បុគ្គលណាម្នាក់ដែលភាគីជឿជាក់ថាអាចជួយខ្លួនបានក្នុងនាមជាជំនួយការភាគី។ គូភាគីត្រូវកំណត់ពេលវេលាទីកន្លែងដោះស្រាយជាមួយអ្នកសម្រុះសម្រួល ឬគូភាគីអាចជូនដំណឹងអំពីការសុំជំទាស់ពីវិវាទផលប្រយោជន៍រវាងភាគីណាមួយជាមួយគណៈកម្មការសុរិយោដី។

**ការសម្រុះសម្រួល៖** ក្រោយពេលបញ្ចប់ការស៊ើបអង្កេតយ៉ាងតិច ៣០ ថ្ងៃ គិតចាប់ពីថ្ងៃបិទផ្សាយបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបើកកិច្ចប្រជុំដើម្បីសម្រេចលើ ដំណើរការសម្រុះសម្រួលវិវាទ ហើយកិច្ចប្រជុំត្រូវធ្វើឡើងនៅទីតាំងវិវាទ ឬនៅកន្លែងដែលជិតនឹងទីតាំងវិវាទនោះ។ ការសម្រុះសម្រួល ឬការសម្រេចរបស់គណៈកម្មការសុរិយោដីធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ គ្មានការគំរាមកំហែង មានន័យថាជាការដោះស្រាយមួយដោយ យកការសម្រុះសម្រួលជាមូលដ្ឋាន ពោលគឺយកឆន្ទៈរបស់គូភាគីវិវាទដែលសុខចិត្តចែករំលែកផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ក្រោមការខិតខំប្រឹងប្រែងរកវិធីដោះស្រាយពីអ្នកសម្រុះសម្រួល។ ភាគីវិវាទ និងអ្នកជំនួយការភាគីត្រូវចូលរួមក្នុងកិច្ចប្រជុំសម្រុះសម្រួលនេះ ហើយដំណើរការប្រជុំសម្រុះសម្រួល ត្រូវស្ថិតក្រោមវិធាននៃការសម្រុះសម្រួលមួយ។ ប្រសិនបើការដោះស្រាយទទួលបានជោគជ័យ ភាគីទាំងពីរត្រូវផ្តិតមេដៃលើទម្រង់បែបបទបញ្ចប់វិវាទតាមខ្លឹមសារដែលបានព្រមព្រៀង។ ប្រសិនបើករណីវិវាទ មិនអាចធ្វើការដោះស្រាយដោយការសម្រុះសម្រួលបានទេនោះ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងបញ្ជូនករណីវិវាទនោះទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ដើម្បីធ្វើការដោះស្រាយបន្ត។

**ការវាស់វែងត្រៀមចេញប័ណ្ណ៖** ក្រោយពេលវិវាទត្រូវបានដោះស្រាយបញ្ចប់ដោយជោគជ័យ ទាំងការសម្រុះសម្រួល ឬសម្រេចគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹងចុះធ្វើការវាស់វែងកំណត់ទំហំដី និងព្រំប្រទល់តាមការព្រមព្រៀងរបស់គូភាគី ឬតាមសេចក្តីសម្រេចចូលជាស្ថាពរ។ បន្ទាប់មកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងស្រុក ខណ្ឌនឹងចាប់ផ្តើមនីតិវិធីចុះបញ្ជីក្បាលដីតាមការស្នើសុំរបស់ភាគីវិវាទ ។

### ខ. ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីរាជធានី ខេត្ត

បន្ទាប់ពីទទួលបានការបញ្ជូនត្រឡប់មកវិញករណីវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌគណៈកម្មការសុរិយោដីថ្នាក់រាជធានីខេត្ត នឹងព្យាយាមធ្វើការសម្រុះសម្រួលបន្តទៀតតាមនីតិវិធីដែលនកំណត់។ ក្នុង

រយៈពេល ៦០ ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទ គណៈកម្មការសុរិយោដីរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីខេត្តក្រុងនិងភាគីវិវាទ។ បើធ្វើការសម្រុះសម្រួលមិនអាចទទួលបានជោគជ័យទេនោះ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវធ្វើនីតិវិធីដោយឡែកផ្សេងទៀត គឺការធ្វើសេចក្តីសម្រេច។ បើភាគីណាមួយមិនសុខចិត្ត ចំពោះសេចក្តីសម្រេចរបស់ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេច ឬទទួលបានព័ត៌មានអំពីសេចក្តីសម្រេច ភាគីវិវាទនោះមានសិទ្ធិប្តឹងសុំឲ្យ គណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើសវនាការជាថ្មីបាន។

## គ. អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ឬគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០០៦[៦០]។ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី គឺជាយន្តការថ្នាក់ជាតិបំពេញមុខងារបន្ថែមដល់គណៈកម្មការសុរិយោដី។ អាជ្ញាធរនេះផ្តល់សិទ្ធិត្រួតពិនិត្យ និងមានភារៈកិច្ចនឹងសម្រេចវិវាទទាំងឡាយណាដែលស្ថិតនៅក្រៅតំបន់នៃការវិនិច្ឆ័យហើយដែលមិនអាចធ្វើការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងដីធ្លីទាំងឡាយ ដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ក្រុង ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់ដែលមិនអាចដោះស្រាយដោយគណៈកម្មការរដ្ឋបាល។លើកលែងតែស្ថិតក្នុងករណីបន្ទាន់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មការរដ្ឋបាលត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ នូវករណីវិវាទរួចអមជាមួយនូវកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួលដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ និងគណៈកម្មការសុរិយោដីខេត្ត ក្រុង ឬនៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង[៦១]។ ក្នុងករណីវិវាទដែលតម្រូវឲ្យមានការសម្រេច ឬដំណើរការដោះស្រាយជាបន្ទាន់ ដូចជាក្នុងករណីមានការគំរាមគំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គីភ័យ ការប្រើកម្លាំង ឬការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ឲ្យចាត់វិធានការបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ។ ក្នុងស្ថានភាពនេះ ភាគីអាចប្តឹងដោយផ្ទាល់

---

[៦០] ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី **ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** កំណត់សមាសភាពនៃអាជ្ញាធរនេះដូចជា តំណាងនាយករដ្ឋមន្ត្រីជាប្រធាន រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអនុប្រធានទី១ ដែលមានសមាជិកមកពីក្រសួងធំៗផ្សេងទៀត និងតំណាងម្ចីនគរបាល និងកំលាំងប្រដាប់អាវុធ។

[៦១] ប្រកាសលេខ ១១២ ដនស/ប្រក ស្តីពី **គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី** , មាត្រា៣៧, កថាខណ្ឌទី២, ទំព័រទី១៧ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០២ ។

ទៅអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លីឲ្យចេញសេចក្តីសម្រេច ជាបណ្តោះអាសន្នដើម្បីធ្វើឲ្យស្ថានការណ៍មានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និងសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ[៦២]។ ក្នុងករណីដែលភាគីវិវាទមិនពេញចិត្តនឹងលទ្ធផលនោះទេភាគីវិវាទអាចធ្វើការប្តឹងទៅតុលាការក្នុងរយៈពេល៣០ថ្ងៃក្រោយពីបានទទួលសេចក្តីសម្រេចនេះ[៦៣]។ ដូចបានរៀបរាប់ខាងលើនេះថា ក្នុងកំឡុងពេលនៃដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បណ្តាវិវាទទាំងឡាយណាដែលកើតឡើងក្នុងកំឡុងពេលនៃការវិនិច្ឆ័យ ឬអំឡុងពេលនៃការបិទផ្សាយជាសាធារណៈត្រូវបញ្ជូនទៅគណៈកម្មការរដ្ឋបាលដើម្បីធ្វើការផ្សះផ្សារ។ គណៈកម្មការសុរិយោដី មានសិទ្ធិត្រឹមតែជួយធ្វើការសម្រុះសម្រួលហើយចំពោះករណីដែលមិនទាន់មានការយល់ព្រម ឬសម្រុះសម្រួលគ្នាទេករណីនោះនឹងត្រូវបញ្ជូនបន្តទៅគណៈកម្មការថ្នាក់ខេត្ត។

ប្រសិនបើក្នុងករណីដែលមិនអាចដោះស្រាយបាននៅថ្នាក់ខេត្តទៀត ករណីនោះនឹងត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិដែលមានអំណាចចេញសេចក្តីសម្រេច[៦៤]។ គណៈកម្មការសុរិយោដី ពុំមានយុត្តាធិការលើជម្លោះដីធ្លីដែលពាក់ព័ន្ធនឹងដីដែលបានចុះបញ្ជីរួចហើយនោះទេព្រោះក្នុងករណីនេះ គឺជាសមត្ថកិច្ចរបស់ស្ថាប័នតុលាការដែលត្រូវដោះស្រាយ។ រាល់ជម្លោះពាក់ព័ន្ធនឹងកិច្ចសន្យា ឬជាមរតកត្រូវតែបញ្ជូនទៅតុលាការដោយមិនគិតថាដីនោះបានចុះបញ្ជី ឬក៏មិនទាន់បានចុះបញ្ជីនោះទេ។ ប្រសិនបើការសម្រុះសម្រួលរបស់គណៈកម្មការ អាចសម្រេចបានជោគជ័យគណៈកម្មការសុរិយោដីគ្រប់លំដាប់ថ្នាក់ ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលដើម្បីចាប់ផ្តើមដំណើការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយវិវាទរួច។

**តារាងទី៣៖ ករណីវិវាទដែលត្រូវបានដាក់ជូនគណៈកម្មការសុរិយោដី [៦៥]**

**( ខែមេសា ឆ្នាំ២០០៣ ដល់ ខែកញ្ញា ឆ្នាំ២០១១ )**

| លទ្ធផលដំណោះស្រាយវិវាទដីធ្លី | ចំនួនរឿងក្តី | ភាគរយ |
|---|---|---|
| បានដោះស្រាយតាមរយៈការផ្សះផ្សារ ឬការសម្រេចចិត្ត | ២,២២៣ | ៣៩% |
| លើកបណ្តឹង( មិនដោះស្រាយ ) | ១,៧៥០ | ៣១% |
| ដកបណ្តឹងវិញដោយដើមបណ្តឹង | ៤៧៤ | ៨% |
| រឿងក្តីរងចាំការដោះស្រាយ | ១.២៦៨ | ២២% |
| **សរុប** | **៥,៧១៥** | **១០០%** |

[៦៣] អនុក្រឹត្យលេខ ៤៧ ស្តីពី **ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី** , មាត្រា ២ និង ៣។

[៦៤] អនុក្រឹត្យលេខ៤៩ ឆ្នាំ២០០២ ស្តីពី **ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី** , មាត្រា ១៩ ។

[៦៥] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ឯកសារ ***ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា*** ចុះខែវិច្ឆិកា ឆ្នាំ២០១២។

យោងទៅតាមការតួលេខខាងលើនេះ បង្ហាញថារឿងក្តីជិត៧៨%នៃរឿងក្តីទាំងអស់ដែលគណៈកម្មការសុរិយោដីបានទទួលត្រូវបានដំណើរការដោះស្រាយ និងត្រូវបានដោះស្រាយក៏មាន ត្រូវបានទាត់ចោលក៏មាន ឬដកវិញដោយដើមបណ្តឹងក៏មាន។ មានតែ២២% ឬ១ក្នុងចំណោម ៥ករណីប៉ុណ្ណោះដែលរងចាំការដោះស្រាយនៅក្នុងដំណាក់កាលផ្សេងៗនៃដំណើរការដោះស្រាយវិវាទ។ ការថយចុះជាលំដាប់នៃរឿងក្តីដែលកំពុងរងចាំការដោះស្រាយនេះ ត្រូវបានកត់សម្គាល់ថាមានភាពល្អប្រសើរជាង ប្រៀបធៀបទៅនឹងការវាយតម្លៃមុនៗ។

ផ្ទុយទៅវិញតាមការសិក្សាមួយនៅឆ្នាំ២០០៦ ដែលត្រូវបានបោះពុម្ពផ្សាយដោយធនាគារពិភពលោក និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់បានរកឃើញថា ក្នុងចំណោមរឿងក្តីទាំងអស់ដែលទទួលបានដំណើរការដោះស្រាយទាំងស្រុង (២៩%ត្រូវបានដោះស្រាយ ២០% ត្រូវបានទាត់ចោល និង២%ត្រូវបានដកទៅវិញ )ហើយ៤៩% រងចាំការដោះស្រាយ។

**តារាងទី៤៖ ដំណោះស្រាយវិវាទដីធ្លីដោយគណៈកម្មការសុរិយោដី** [៦៦]

**(តួលេខកំណើនបូកបន្ថែមសម្រាប់ចន្លោះខែ មេសា ឆ្នាំ២០០៤ និងខែ កញ្ញា ឆ្នាំ២០១១ )**

| លទ្ធផលដំណោះស្រាយវិវាទដីធ្លី | រហូតដល់ខែមេសា ឆ្នាំ ២០០៦ | | រហូតដល់ខែធ្នូ ឆ្នាំ ២០០៨ | | រហូតដល់ខែកញ្ញា ឆ្នាំ ២០១១ | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| **រឿងក្តីបានផ្សះផ្សារ ឬបានសម្រេច** | ១,១៤៦ | ២៩% | ១,៦៥៣ | ៣៣% | ២,២២៣ | ៣៩% |
| **រឿងក្តីបានទាត់ចោល** | ៧៧៣ | ២០% | ១,២១១ | ២៤% | ១,៧៥០ | ៣១% |
| **រឿងក្តីបានដកទៅវិញ** | ៧០ | ២% | ២២០ | ៤% | ៤៧៤ | ៨% |
| **រឿងក្តីកំពុងរងចាំការដោះស្រាយ** | ១,៩៦០ | ៤៩% | ១,៩៧៥ | ៣៩% | ១,២៦៨ | ២២% |
| **រឿងក្តីបានទទួលសរុប** | ៣,៩៤៩ | ១០០% | ៥,០៥៩ | ១០០% | ៥,៧១៥ | ១០០% |

### ២.៥.២. ការដោះស្រាយដោយស្ថាប័នតុលាការ ចំពោះដីចុះបញ្ជីរួច

មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវការដោះស្រាយដោយតុលាការជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយដែលរំលោភសិទ្ធិសំខាន់ៗរបស់ខ្លួនដែលមានចែងនៅក្នុង ក្រមរដ្ឋធម្មនុញ្ញនិងមានចែងនៅក្នុងច្បាប់ ។តុលាការមានសមត្ថកិច្ចដោះស្រាយលើទំទាស់ដីធ្លីណាដែលបានចុះបញ្ជី និងដីដែលបានផ្តល់ប័ណ្ណកម្មសិទ្ធិរួចរាល់ហើយ បើយោងតាមប្រកាសរួមលេខ ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងយុត្តិធម៌

[៦៦] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ឯកសារ ***ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា*** ចុះខែវិច្ឆិកា ឆ្នាំ២០១២។

និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ តុលាការក៏មានសមត្ថកិច្ចផងដែរ ចំពោះបណ្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសុរិយោដីថ្នាក់ជាតិ។ ចំពោះវិវាទដីធ្លី គឺជាប្រភេទរឿងក្តីរដ្ឋប្បវេណី ដូចនេះភាគី និងតុលាការត្រូវអនុវត្តន៍តាមគោលការណ៍នៃនីតិវិធីផ្នែករដ្ឋប្បវេណីចំពោះបណ្តឹងពាក់ព័ន្ធនឹងដីធ្លី[៦៧]។

[៦៧] ឯកសារ យល់ដឹងផ្នែកច្បាប់ ***យន្តការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា*** រៀបរៀងដោយ លោកមេធាវី ថន យូសៀង និងលោក វ៉ាត់ ចាន់ធី ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, ហ្វេសបុកផេក ***ក្រុមមេធាវីកម្ពុជា សហប្រតិបត្តិការអន្តរជាតិ*** / Cambodia International Cooperation Law Group។

# ជំពូក ៣

# លទ្ធភាព និងការវិភាគ

# ជំពូក ៣

# លទ្ធភាព និងការវិភាគ

## ៣.១. លទ្ធផលនៃការពិភាក្សាការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ

ការចុះបញ្ជីដីធ្លីនេះ គឺធ្វើឡើងក្នុងគោលបំណងបំបាត់ភាពមិនច្បាស់លាស់ជាកម្មសិទ្ធិលើដី ដែលបានបង្កឲ្យមានទំនាស់ឥតឈប់ឈរ និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុប័ណ្ណកម្មសិទ្ធិ ( ប័ណ្ណកម្មសិទ្ធិ ) ជូនប្រជាពលរដ្ឋ។ តាមរយៈការចុះបញ្ជីដីធ្លីនេះ រដ្ឋាភិបាលបានធ្វើឲ្យមានការរីកចម្រើនក្នុងការផ្តល់កម្មសិទ្ធិដីធ្លី និងដោះស្រាយវិវាទដីធ្លីមួយចំនួន។ ចាប់ផ្តើមពីការកកើតកម្មវិធីកម្មសិទ្ធិដីធ្លីរហូតដល់ចុងឆ្នាំ២០១៩ក្នុងនោះ ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធសម្រេចបាន ៤ ៥៧៥ ៤៨០ ប័ណ្ណ និងចែកប័ណ្ណជូនដល់ប្រជាពលរដ្ឋចំនួន ៤ ៣២៣ ៤៩៦ប័ណ្ណ។ យន្តការបណ្តោះអាសន្នជាច្រើនក្នុងការដោះស្រាយវិវាទដីធ្លីដែលនៅសល់ ត្រូវបានបង្កើតឡើង ទោះបីជាវិវាទសកម្មមួយចំនួននៅតែបន្តមានភាពមិនច្បាស់លាស់ក៏ដោយ។ ស្របទៅតាមគោលនយោបាយដីធ្លីដែលដាក់ចេញក្នុងឆ្នាំ ២០១៥ ដែលឆ្លើយតបទៅនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកំណែទម្រង់ដីធ្លីដើម្បីគាំទ្រដល់ជីវភាពរបស់ប្រជាជន។

នៅក្នុងដំណើរការចុះបញ្ជីដីនេះប្រសិនបើកើតមានវិវាទណាមួយកើតឡើងជាទូទៅ វិវាទបែបនេះនឹងត្រូវដោះស្រាយបានជាមួយគណៈកម្មការ ដែលបានចាត់តាំងដោយភាគីជម្លោះអាចស្នើសុំឲ្យអាជ្ញាធរពាក់ព័ន្ធនេះជួយដោះស្រាយ ដោយមិនចាំបាច់ប្តឹងផ្តល់គ្នាទៅតុលាការនោះទេ។ ដោយឡែកយើងដឹងហើយថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវធ្វើទៅតាមតំបន់វិនិច្ឆ័យដែលនៅតាមរាជធានី ខេត្ត ដែលធ្វើឲ្យការចុះបញ្ជីដីធ្លីរបៀបនេះ មានលក្ខណៈយឺតយ៉ាវ ពីព្រោះដើម្បីចុះបញ្ជីដីធ្លីបាន ប្រជាពលរដ្ឋត្រូវរង់ចាំទាល់តែមានការប្រកាសពីតំបន់វិនិច្ឆ័យនៅទីតាំងដីធ្លីរបស់ខ្លួន។ មួយវិញទៀតការចុះបញ្ជីដីធ្លីនេះ ជាប្រតិបត្តិការកើតឡើងថវិការបស់រដ្ឋរួមជាមួយនឹងអ្នកកាន់កាប់ដីនោះ មានការកំណត់នូវនីតិវិធីសមស្របមួយដែលអាចធ្វើឲ្យប្រជាពលរដ្ឋមានភាពងាយស្រួល រួមជាមួយនឹងការយកចិត្តទុកដាក់ តែទោះជាយ៉ាងណាក្តីបញ្ហាប្រឈមនៅតែកើតចេញពីការមិនអនុវត្តមុខងារ ឲ្យស្របទៅតាមគោលការណ៍ច្បាស់លាស់រួមមួយ ជាមួយនឹងការខ្វះខាតនូវបច្ចេកទេស និងជំនាញរបស់មន្ត្រីជាកត្តាមួយធ្វើឲ្យកកស្ទះនូវដំណើរការចុះបញ្ជីនេះ។ រំលឹកផងដែរថានៅពេលបច្ចុប្បន្ននេះក្រសួងបានប្រកាសផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិអចលនវត្ថុថ្មី និងបន្ថែម QR កូដនៅលើសន្លឹកវិញ្ញាបនបត្រម្ចាស់អចលនវត្ថុ ដែលអាចចូលទៅមើលព័ត៌មានទាំងស្រុងនៃអចលនវត្ថុបានពោលគឺព័ត៌មានដែលទាក់ទងនឹងម្ចាស់ដីក្បាលដី ផែនទីនៃដី និងអត្តសញ្ញាណនៃម្ចាស់អចលនវត្ថុនោះ។

## ៣.២. លទ្ធផលនៃការពិភាក្សាការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ

ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ជាយន្តការមួយដែលចុះបញ្ជីដោយគ្មានកំណត់ពេល គឺធ្វើឡើង តាមសំណើររបស់ម្ចាស់កម្មសិទ្ធិ ឬសាមីអ្នកកាន់កាប់ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន តាមគំរូដែលបាន កំណត់ មករដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិត នៅ។ ការចុះបញ្ជីអាចអនុវត្តបានចំពោះក្បាលដីណាដែលស្ថិតក្រៅតំបន់វិនិច្ឆ័យ ( គឺជាតំបន់ដែលមានការចុះ បញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមិនទាន់បានចូលទៅដល់ )។ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងមិន ធ្វើការចុះបញ្ជីទាំងស្រុងនូវក្បាលដី ទាំងអស់នៅតំបន់ណាមួយជាក់លាក់នោះឡើយ។ ចាប់តាំងពីពេលដែល អនុញ្ញាតឲ្យមានការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ រហូតមកដល់ខែមេសា ឆ្នាំ២០១៩ ការចុះបញ្ជីដីមានលក្ខ ណៈដាច់ដោយដុំសម្រេចបាន ៦១៦ ៣៧០ ប័ណ្ណ ( ដីរដ្ឋបាន ១ ៧៧៧ ប័ណ្ណ ទំហំ៧៣៦ ៥៦៥ហិកតា ដីឯក ជនបាន ៦១៣ ៩០៩ ប័ណ្ណ )។

ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ មានប្រាំដំណាក់កាល ដូចទៅនឹងដំណើរការនៃ ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដែរ គឺទី១៖ ការដាក់ពាក្យស្នើសុំចុះបញ្ជីដី ទី២៖ ការងារបច្ចេកទេស ទី៣៖ ការផ្សព្វផ្សាយ ទី៤៖ ការសម្រេចលើឯកសារ ទី៥៖ អំពីការចែកប័ណ្ណ។ ទាក់ទងនឹងការចុះបញ្ជីដាច់ដោយដុំ យើងឃើញថាការអនុវត្តដែលទាក់ទងនឹងបទប្បញ្ញត្តិមានការបញ្ញត្តិនូវនីតិវិធីបានយ៉ាងមុតស្រួច និងមានការ កំណត់លក្ខណៈច្បាស់លាស់នូវនីតិវិធីនីមួយៗរហូតដល់ការចេញប័ណ្ណ។ ប៉ុន្តែស្ថិតនៅក្នុងដំណាក់កាលមួយ ចំនួននៃការចុះបញ្ជីដីធ្លីនៅមានភាពខ្វះខាតនូវឡើយ ទាក់ទងនឹងវិធានការផ្សព្វផ្សាយនូវច្បាប់ជាមុនៗនឹងធ្វើការ អនុវត្តនូវបទប្បញ្ញត្តិនៃការចុះបញ្ជីប្រភេទនេះ។ ការទាមទារប្រភេទនេះដោយហេតុថា នៅក្នុងស្ថានភាពជាក់ ស្តែង មន្ត្រីទទួលលបន្ទុកខ្វះខាតនូវសមត្ថភាពនៅក្នុងការបំពេញការងារ និងការយល់ដឹងនូវចំណុចខ្លះនៅក្នុង ការចូលរួមពីសំណាក់ប្រជាពលរដ្ឋ។ តួយ៉ាង ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ជាការចុះបញ្ជីតាម រយៈ ការស្ម័គ្រចិត្តរបស់អ្នកកាន់កាប់ដី គឺមានន័យថាអាស្រ័យលើការសម្រេចចិត្តរបស់ប្រជាពលរដ្ឋ គ្មានការបង្ខិតបង្ខំ ដូច្នេះហើយត្រូវទទួលបន្ទុកការចំណាយលើសោហ៊ុយដោយខ្លួនឯង។ ពាក់ព័ន្ធនឹងការចំណាយនេះយើងបាន មើលឃើញពីការអនុវត្តខុសគ្នាទៅនឹងការបញ្ញត្តិរបស់ច្បាប់ក្នុងការចំណាយទៅលើការចុះបញ្ជី។ តាមភាពជាក់ ស្តែងនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំត្រូវមានការចំណាយយ៉ាងច្រើនថែមទៀតផង។ កត្តានេះជា ហេតុមួយដែលធ្វើឲ្យការចុះបញ្ជីដីធ្លីដាច់ដោយដុំមានការធ្លាក់ចុះ។ បញ្ហាមួយទៀត ដែលមានការកើតឡើងរួច មកហើយនោះ គឺចុះបញ្ជីប្រភេទនេះមិនទាន់ទទួលបាននូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ គឺបានទទួល ត្រឹមតែប័ណ្ណសម្គាល់កាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ) ប៉ុណ្ណោះ។

## ៣.៣. ចំណុចខ្លាំង និងចំណុចខ្សោយនៃការចុះបញ្ជីដីធ្លី

ទាក់ទងនឹងការអនុវត្តការងារចុះបញ្ជីដីធ្លីនៅកម្ពុជា យើងអាចយល់ដឹងបាននូវភាពវិជ្ជមាន និងភាពអវិជ្ជមានរបស់វា តាមរយៈការសម្ភាសន៍ផ្ទាល់ជាមួយអាជ្ញាធរទទួលបន្ទុកការងារចុះបញ្ជី និងប្រជាពលរដ្ឋដែលជាអ្នកទទួលសេវានេះផងដែរ។ ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដីធ្លីបំពេញបន្ថែមក្តី សុទ្ធតែជាការចុះបញ្ជីមួយដែលអាចរក្សាការពារនូវភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់នៃការកាន់កាប់ដីធ្លី។ ការចុះបញ្ជីដីធ្លី បង្កើតឲ្យមានអានុភាពយ៉ាងខ្លាំងក្លាមួយ ដែលម្ចាស់កម្មសិទ្ធិដីធ្លីអាចប្រើប្រាស់នូវអានុភាពនោះ សម្រាប់បម្រើផលប្រយោជន៍នានាដល់ខ្លួនឯងបាន។ ទោះបីជាវាមានអានុភាពខ្លាំងក៏ពិតមែន ប៉ុន្តែច្បាប់នៅនឹងរឹតបន្តឹង ទៅលើអានុភាពនោះជាហេតុធ្វើឲ្យវាមានភាពលំបាក ភាពអសកម្ម និងចំណុចខ្សោយមួយចំនួនក្នុងការប្រើប្រាស់វា សម្រាប់បម្រើផលប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិស្របច្បាប់។ នៅខាងក្រោមនេះ យើងនឹងធ្វើការពិភាក្សាទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃការចុះបញ្ជីដីធ្លីនៅកម្ពុជា។

### ៣.៣.១. ចំណុចខ្លាំង

ការចុះបញ្ជីដីធ្លី មានបំណងតែមួយគត់គឺបង្កើតឲ្យមានប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ដែលអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់វិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុតាមលក្ខណៈនៃប្រភេទចុះបញ្ជីនីមួយៗទាំងមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈជាប្រព័ន្ធ។ យើងដឹងហើយថាការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធជាទំនួល ខុសត្រូវទាំងស្រុងរបស់រាជរដ្ឋាភិបាល រីឯការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំជាការទំនួល ខុសត្រូវរបស់ប្រជាពលរដ្ឋ(សោហ៊ុយ) និងមានការចូលរួមពីសំណាក់អាជ្ញាធរពាក់ព័ន្ធផងដែរ។ ការលើកឡើងពីការចុះបញ្ជីទាំងពីរប្រភេទនេះគឺជាការសបញ្ជាក់ ពីគោលគំនិតនៃការចុះបញ្ជីដីធ្លីដែលជាចេតនាមួយចង់ស្តែងឲ្យឃើញថា រដ្ឋាភិបាលបាននឹងកំពុងប្រឹងប្រែងយ៉ាង សកម្ម ក្នុងការរៀបចំប្រព័ន្ធចុះបញ្ជីដីធ្លីនេះឡើងនៅទូទាំងប្រទេស។ ពិតណាស់ដោយរាជរដ្ឋាភិបាលបានមើលឃើញពីផលប្រយោជន៍ជាច្រើនដល់សង្គមកម្ពុជាផ្ទាល់ ជាពិសេសនោះគឺ ពលរដ្ឋកម្ពុជាតែម្តង ក្នុងនោះមានដូចជា៖

#### ក. ផលប្រយោជន៍ចំពោះរដ្ឋ

រដ្ឋាភិបាលកម្ពុជា រួមជាមួយដៃគូផ្តល់ជំនួយនានាទទួលស្គាល់ថា សុវត្ថិភាពនៃការកាន់កាប់ដីធ្លីតាមរយៈការចុះបញ្ជីទាំងនៅជនបទ និងតំបន់ទីក្រុង ទីប្រជុំជន គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការសម្រេចបាននូវការជម្រុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកិច្ច ដែលក្នុងនោះការចុះបញ្ជីដីធ្លីជាជំហានដំបូងនៃការរៀបចំគ្រប់គ្រងដីធ្លីនៅទូទាំងប្រទេសដែលនឹងផ្តល់ ផលប្រយោជន៍ទាំងនៅពេលបច្ចុប្បន្ន ព្រមទាំងនាអនាគតដល់សង្គមជាតិទាំងមូលនៅក្នុង រូបភាពច្រើនបែបច្រើនសណ្ឋាន។

+ ពន្ធ និងសោហ៊ុយសុរិយោដីផ្សេងៗ៖ ពន្ធលើអចលនវត្ថុ និងសោហ៊ុយដីផ្សេងៗ គឺជាប្រភពប្រាក់ចំណូលជាតិយ៉ាងសំខាន់សម្រាប់ការទប់ទល់ការចំណាយរបស់ជាតិ។ រដ្ឋអាចធ្វើការប្រមូលពន្ធពីប្រជាពលរដ្ឋតាមរូបភាពជាការបង់ពន្ធលើដីធ្លីដែលបានចុះបញ្ជីរួច ពន្ធលើប្រាក់ចំណេញនៃការលក់ដីធ្លី ឬអចលចនវត្ថុផ្សេងៗដែលទាំងនេះសុទ្ធសឹងតែជាប្រភពចំណូលដ៏ធំរបស់រដ្ឋ ដែលអាចប្រមូលយកមកបានសម្រាប់ទប់ខ្ទង់ចំណាយនានា បម្រើការឲ្យប្រជាពលរដ្ឋ។

+ ប្រសិទ្ធភាពចំពោះការគ្រប់គ្រងដីធ្លីរបស់រាជរដ្ឋាភិបាលៈ តាមរយៈការចុះបញ្ជីដីធ្លីរាជរដ្ឋាភិបាលមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការសម្រួលដល់ការបង្កើតប្រព័ន្ធវាយតម្លៃដីធ្លីដែលបានចុះបញ្ជីរួច បង្កើតឲ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានអំពីដីធ្លីបែបទំនើបកម្ម និងងាយស្រួលក្នុងការកំណត់ប្រភេទដីធ្លីនៅក្នុងតំបន់។

+ ការវិនិយោគ និងផលិតកម្ម៖ ការវិនិយោគលើដីធ្លី គឺជាកត្តាយ៉ាងសំខាន់ក្នុងការបង្កើនល្បឿនសេដ្ឋកិច្ចជាតិ ដែលវាជាកាតាលីករមួយជួយជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រក្នុងដំណើរផលិតកម្មរបស់ប្រជាជន។

### ខ. ផលប្រយោជន៍ចំពោះកម្មសិទ្ធិករ

ការចុះបញ្ជីដីធ្លីគឺក្នុងគោលបំណងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋតាមរយៈការចេញប័ណ្ណនេះម្ចាស់កម្មសិទ្ធិអាចយកប័ណ្ណនេះទៅប្រើប្រាស់តាមមធ្យោបាយជាច្រើនយ៉ាង តាមតម្រូវការដែលមានដូចខាងក្រោមនេះ៖

+ ឥណទាន៖ ប្រើប្រាស់សេវាឥណទាននៅតាមបណ្តាធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា គឺជាទំនើបកម្មថ្មីមួយនៃសេវាកម្មខ្ចីប្រាក់សម្រាប់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ននេះក្នុង ការបង្កបង្កើនអាជីវកម្មរបស់ខ្លួនក្នុងនោះប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិលើអចលនវត្ថុគឺជាឯកសារចាំបាច់ក្នុងការស្នើកម្ចីផងដែរ។ ប្រជាពលរដ្ឋអាចយកប័ណ្ណសម្គាល់សិទ្ធិកាន់កាប់នោះបង្កើតជាហ៊ីប៉ូតែកថែមទៀតផង។

+ ការប្រើប្រាស់ប្រាតិភោគផ្សេងៗទៀត៖ អចលនវត្ថុដែលមានប័ណ្ណកម្មសិទ្ធិ កម្មសិទ្ធិករអាចយកប្រើប្រាស់បានក្នុងការប្រាតិភោគអចលនវត្ថុ (ហ៊ីប៉ូតែក ការធានា ការដាក់បញ្ចាំ) ។

+ ភស្តុតាង៖ ប័ណ្ណកម្មសិទ្ធិគឺជាភ័ស្តុតាងយ៉ាងពេញលេញមួយដែលបញ្ជាក់ពីភាពស្របនូវអត្តសញ្ញាណក្បាលដី អត្តសញ្ញាណម្ចាស់ដែលមានសិទ្ធិលើក្បាលដី ដូចនេះប័ណ្ណកម្មសិទ្ធិធានាយ៉ាងគ្រប់គ្រាន់នូវសុវត្ថិភាពកាន់កាប់ដីធ្លីរបស់ម្ចាស់ដីទប់ស្កាត់ការរំលោភបំពានដីធ្លី និងកាត់បន្ថយទំនាស់ដីធ្លី។

ជារួមក្រោយពីបានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិ ( ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ) កម្មសិទ្ធិករអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការចាត់ចែង ប្រើប្រាស់ និងអាស្រ័យផលទៅលើដីធ្លី ដូចជាធ្វើជាអំណោយ ជួល

ជាអចិន្ត្រៃយ៍ លក់ដូរ មរតកសាសន៍គ្រប់បែបយ៉ាងទៅលើដីធ្លីនោះ តាមការសម្រេចចិត្តរបស់ខ្លួនដោយគ្មានការរារាំង ឬបង្ខិតបង្ខំឡើយ។

### ៣.៣.២. ចំណុចខ្សោយ

ជាការពិតណាស់នៅក្នុងកិច្ចដំណើរការ ក៏ដូចជាកិច្ចប្រតិបត្តិការចុះបញ្ជីដីធ្លីទាំងមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំផ្ទាល់ប្រាកដជាមិនអាចជៀសផុតបានឡើយនូវ បញ្ហាប្រឈមក៏ដូចជាចំណុចខ្វះខាតផ្សេងៗ ដែលកើតមានក្នុងអំឡុងពេលដំណើរការប្រតិបត្តិការនីតិវិធីចុះបញ្ជីដីធ្លីនោះជាក់ជាពុំខានឡើយ។ យ៉ាងណាមិញបញ្ហាប្រឈម ក៏ដូចជាចំណុចខ្វះខាតទាំងអស់នោះ គឺជាឧបសគ្គដ៏ចម្បងមួយដែលត្រូវរកឲ្យឃើញដើម្បីស្វែងរកដំណោះស្រាយ និងជម្នះឲ្យបានក្នុងការរៀបចំនូវរាល់នីតិវិធីក៏ដូចជាដំណើរការចុះបញ្ជីដីធ្លីទៅតាមប្រភេទនីមួយៗ ដែលត្រូវអនុវត្តតាមដំណាក់កាលជាបន្តបន្ទាប់។ ជាក់ស្តែងយើងបានមើលឃើញពីភាពក្មេងខ្ចីដែលជាចំណុចខ្វះចន្លោះនៅក្នុងការអនុវត្តដំណើរការចុះបញ្ជីដីធ្លីកន្លងមកមានដូចជា៖

#### ក. ចំពោះស្ថាប័នរដ្ឋ

\+ ប្រព័ន្ធផ្សព្វផ្សាយនៅមានកម្រិត៖ ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង វិស័យដីធ្លី ជាពិសេសទាក់ទងនឹងការអនុវត្តនីតិវិធីមិនទាន់បានទូលំទូលាយ ដែលធ្វើឲ្យប្រជាពលរដ្ឋមិនទាន់យល់ពីនីតិវិធីនៃការចុះបញ្ជីដី និងច្បាប់មួយចំនួនដែលពាក់ព័ន្ធនឹងការចុះបញ្ជីដីធ្លី និងការអនុវត្តផ្សេងៗដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ព្រោះកន្លងពុំសូវឃើញមានសកម្មភាពចុះទៅពន្យល់ណែនាំអំពី ច្បាប់ បទបញ្ញត្តិ និងគោលការណ៍នានាដែលពាក់ព័ន្ធនឹងការ ទទួលបានកម្មសិទ្ធិដីធ្លីគ្រប់ជ្រុងជ្រោយនៅឡើយ។

\+ កង្វះខាតមន្ត្រីជំនាញ៖ មន្ត្រីជំនាញដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការនៃការចុះបញ្ជីដីធ្លីទាំងមូល ជាក់ស្តែងភាពខ្វះចន្លោះនៅក្នុងដំណើរការចុះបញ្ជីដីធ្លីគឺពាក់ព័ន្ធនឹងការអនុវត្តការងាររបស់មន្ត្រីជំនាញសុរិយោដីមួយផ្នែកធំ ដូច្នេះរាជរដ្ឋាភិបាលត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែម ក្នុងការពង្រឹងបណ្តុះបណ្តាលមន្ត្រីជំនាញពាក់ព័ន្ធការងារបច្ចេកទេសវាស់វែងដីធ្លី កំណត់ព្រំដី ការកំណត់អត្តសញ្ញាណនៃដី និងជាពិសេសជំនាញក្នុងការដោះស្រាយវិវាទដីធ្លី ការសម្របសម្រួលជាដើម ព្រមទាំងការបង្កើនការឧបត្ថម្ភបង្កើនកញ្ចប់ថវិកា ឧបករណ៍ប្រើប្រាស់ក្នុងការអនុវត្តការងារ និងមធ្យោបាយធ្វើដំណើរផ្សេងៗជាដើមសុទ្ធសឹងជាកត្តាចម្បងដែលចូលរួមក្នុងការបង្កើនសមត្ថភាពការងារមន្ត្រីជំនាញ។

\+ ការបញ្ចេញមតិមិនមានលក្ខណៈទូលំទូលាយ៖ យើងសង្កេតឃើញថាប្រជាពលរដ្ឋពុំសូវទទួលបានការបញ្ចេញមតិយោបល់ទៅលើបញ្ហានៃការប្រើប្រាស់សេវាចុះបញ្ជីដីធ្លីរបស់ពួកគេនោះទេ មិនថាការអនុវត្តការងារ

របស់មន្ត្រីជំនាញ បញ្ហាអំពើពុករលួយ ព្រមទាំងបញ្ហាប្រឈមនានានៅក្នុងដំណើរការនៃការចុះបញ្ជីដីធ្លីនេះតែម្តង។ ការបំភិតបំភ័យប្រជាពលរដ្ឋ គំរាមគំហែង ប្រើឋានៈយសស័ក្តិលើប្រជាពលរដ្ឋ ក៏ជាកត្តាមួយដែលធ្វើឲ្យប្រជាពលរដ្ឋពុំហ៊ានធ្វើការបញ្ចេញមតិ រិះគន់ចំៗទៅលើមន្ត្រីជំនាញ អំពីការអនុវត្តការងារ និងបញ្ហាខ្មៅងងឹតដែលមាននៅក្នុងដំណើរការអនុវត្តនេះ។

\+ ភាពយឺតយ៉ាវក្នុងការដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋ៖ ភាពយឺតយ៉ាវខ្លះដែរចំពោះការបញ្ជូនឯកសារមួយចំនួនដូចជា ការផ្ទេរលិខិតទាំងលិខិតអញ្ជើញ លិខិតស្នើសុំ សេចក្តីសម្រេច សេចក្តីជូនដំណឹងផងដែរ គឺត្រូវប្រើពេលវេលារង់ចាំច្រើនថ្ងៃទើបទទួលបានហត្ថលេខាដើម្បីយកទៅអនុវត្តន៍បន្ត។ លើសពីនេះទៅទៀតរបាយការណ៍ចុះត្រួតពិនិត្យគុណភាពក្បាលដីក៏មានលក្ខណៈយឺតយ៉ាវថែមទៀត ដោយសារបញ្ហាខ្វះឯកសារផ្សេងៗ និងការចូលរួមរបស់ភាគីម្ចាស់ដីដែលបណ្តាលឲ្យការស្រង់ព័ត៌មានការយឺតយ៉ាវ។ ការអនុវត្តការងាររបស់អាជ្ញាធររដ្ឋបាលក្នុងការដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋនៅក្នុងតំបន់ណាមួយដែលមានការចុះ បញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ វិវាទដែលកើតមានក្នុងអំឡុងពេលនោះ គឺត្រូវពន្យាពេលដែលធ្វើឲ្យមានការយឺតយ៉ាវរាំងស្ទះជាហេតុធ្វើឲ្យប្រជាពលរដ្ឋមិនពេញចិត្តទៅលើការអនុវត្តការងាររបស់រាជរដ្ឋាភិបាល ហើយលែងទុកចិត្តលើ រដ្ឋាភិបាលទៀត។

\+ ភាពទន់ខ្សោយរវាងវិធានច្បាប់ និងការអនុវត្ត៖ ភាពធូររលុងនៃវិធានច្បាប់ធ្វើឲ្យមានការអនុវត្តការងារមួយចំនួនរបស់មន្ត្រីជំនាញផ្ទុយ ឬលើសពីដែនសមត្ថកិច្ចរបស់ខ្លួនដែលខុសពីការកំណត់របស់រាជរដ្ឋាភិបាល។ ពេលណាដែលច្បាប់មានការធូររលុង ការអនុវត្តការងារក៏ពុំមានការល្អឥតខ្ចោះដែរ។

### ខ. ចំពោះកម្មសិទ្ធិករ

\+ សោហ៊ុយក្នុងការចុះបញ្ជីដីធ្លី៖ យើងដឹងហើយថា ការចុះបញ្ជីដីធ្លីគឺជាយន្តការមួយដែលរាជរដ្ឋាភិបាលបង្កើតឡើង ដើម្បីធ្វើការចុះបញ្ជីដីជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដីធ្លីស្របច្បាប់ និងមាននិយាមការច្បាស់លាស់។ ការចុះបញ្ជីដីធ្លី គឺត្រូវមានការបង់ជាសោហ៊ុយសម្រាប់ការវាស់វែងដែលបានកំណត់ដោយរដ្ឋ។ ចំពោះការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺមានការចំណាយលើសោហ៊ុយនៃការវាស់វែងចំនួនតិចតួចប៉ុណ្ណោះផ្ទុយទៅវិញចំពោះការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ គឺតម្រូវឲ្យកម្មសិទ្ធិករត្រូវចេញសោហ៊ុយច្រើន ក្នុងដំណើរការចុះបញ្ជីដីធ្លីដោយខ្លួនឯង ដែលប្រជាជនភាគច្រើនមិនមានលទ្ធភាពក្នុងការទៅសុំចុះបញ្ជីសម្គាល់ភាពជាម្ចាស់នៃដីធ្លីរបស់ខ្លួនឡើយពោល គឺត្រូវរង់ចាំរហូតទាល់តែមានការប្រកាសពីរដ្ឋាភិបាលដើម្បីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធវិញ។

\+ កាតព្វកិច្ចក្នុងការបង់ពន្ធ៖ ការបង់ពន្ធប្រថាប់ត្រាចំនួន៤% ត្រូវបានអនុវត្តចំពោះការស្នើសុំចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ។ ហើយពន្ធ៤%នេះ ត្រូវបានអនុវត្តរាល់ប្រតិបត្តិការផ្ទេរកម្មសិទ្ធិពីម្ចាស់មួយទៅម្ចាស់មួយ

ទៀត។ ទោះជាយ៉ាងណា ជាក់ស្តែងគេមើលឃើញថា ការទិញលក់មួយចំនួនត្រូវធ្វើឡើងត្រឹមថ្នាក់មូលដ្ឋាន ហើយម្ចាស់ដីមួយចំនួនមិនទាន់ចុះបញ្ជីដីនៅឡើយ។ តាមច្បាប់រាល់ការទិញលក់ច្រើនដង ហើយមិនមានការបង់ពន្ធប្រថាប់ត្រា នោះម្ចាស់ចុងក្រោយជាអ្នកទទួលខុសត្រូវបង់ពន្ធទាំងអស់។ ប៉ុន្តែដោយពិនិត្យឃើញថា ប្រជាពលរដ្ឋ ដែលជាអ្នកទទួលសិទ្ធិកាន់កាប់អចលនទ្រព្យចុងក្រោយ ( អ្នកទិញ ) ដែលតម្រូវឲ្យមានការបង់ពន្ធប្រថាប់ត្រាច្រើនតំណនៅមានចំនួនច្រើននៅឡើយ។ ដូចនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសម្រេចបន្តអនុវត្តន៍គោលការណ៍បង់ពន្ធប្រថាប់ត្រាចំនួនមួយដង នៅក្នុងឆ្នាំ២០១៩ ចំពោះការផ្ទេរកម្មសិទ្ធិ ឬកម្មសិទ្ធិកាន់កាប់អចលនវត្ថុពុំបានចុះបញ្ជី ( គ្មានប័ណ្ណកម្មសិទ្ធិ ) និងកម្មសិទ្ធិបានចុះបញ្ជី ( មានប័ណ្ណកម្មសិទ្ធិ )។ ហេតុនេះប្រជាពលលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិដីធ្លីត្រូវធ្វើការបង់ពន្ធជូនរដ្ឋ តាមការកំណត់របស់រដ្ឋ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

នៅដើមឆ្នាំ ២០០២ ដោយមានការគាំទ្រពីម្ចាស់ជំនួយផងនោះ រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីក្បាលដីទាំងអស់ជាលក្ខណៈប្រព័ន្ធ យោងតាមប្រភេទដែលមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១។ ដំណើរការចុះបញ្ជីដីនេះ មានគោលបំណងបំបាត់ភាពមិនប្រាកដប្រជានៃភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លី ដែលបានបង្កឲ្យមានទំនាស់ និងអសន្តិសុខនៃការកាន់កាប់។ គណៈកម្មការសុរិយោដី ត្រូវបានបង្កើតឡើងដើម្បីជួយដោះស្រាយបញ្ហាជម្លោះនានាដែលកើតឡើងអំឡុងពេលនៃការចុះបញ្ជីដីធ្លី។ យុទ្ធសាស្ត្រចតុកោណសម្រាប់ កំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព នៅក្នុងប្រទេសកម្ពុជាត្រូវបានរួម បញ្ចូលទាំងការប្តេជ្ញាចិត្តដើម្បីបង្កើនការបែងចែកដីសម្រាប់ប្រជាជនក្រីក្រ និងផ្តល់ការចុះបញ្ជីក្បាលដីដើម្បីធានាភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់ដល់ពួកគេ។

ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជានៅកម្ពុជា ពិតជាមានសារៈសំខាន់ណាស់សម្រាប់ ប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់ដីពិតប្រាកដ ដែលបានកាន់កាប់ដីតាំងពីយូរណាស់មកហើយ។ តាមរយៈការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ( ប័ណ្ណកម្មសិទ្ធិ )ទៅលើដីធ្លី ប្រជាពលរដ្ឋខ្មែរទាំងអស់អាចប្រើប្រាស់នូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចនលវត្ថុនោះ សម្រាប់តម្រូវការផ្សេងៗ ដូចជាសេវាឥណទាន នៅតាមធនាគារ និងមីក្រូហិរញ្ញវត្ថុនានា ដាក់បញ្ចាំ ហ៊ីប៉ូតែក លក់ ដើម្បីបានប្រាក់សម្រាប់បម្រើឲ្យអាជីវកម្មរបស់ខ្លួន។ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ( ប័ណ្ណកម្មសិទ្ធិ ) គឺជាតឹកតាងមួយដែលអាចបញ្ជាក់យ៉ាងច្បាស់លាស់ពីភាពស្របច្បាប់នូវអត្តសញ្ញាណរបស់ក្បាលដីដែលម្ចាស់កម្មសិទ្ធិបានកាន់កាប់ស្របច្បាប់។ ដូចនេះវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ គឺធានាយ៉ាងម៉ឺងម៉ាត់នូវសុវត្ថិភាពក្នុងការកាន់កាប់ និងប្រើប្រាស់ដីរបស់ម្ចាស់នៃក្បាលដី។

ការចុះបញ្ជីដីធ្លីឯកជននៅកម្ពុជា ត្រូវបានគេបែងចែកជាពីរគឺ ការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ។ ការចុះបញ្ជីដីធ្លីទាំងពីរប្រភេទនេះ គឺមាននីតិវិធីប្រហាក់ប្រហែគ្នា និងដំណាក់កាលដូចគ្នាសម្រាប់ការអនុវត្តការងារ។ ប៉ុន្តែយើងអាចធ្វើការសម្គាល់ការចុះបញ្ជីដីធ្លីទាំងពីរប្រភេទនេះបានត្រង់ថាការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺជាយន្តការមួយដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ធ្វើការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋមានលក្ខណៈធំដុំ គឺអាចនិយាយបានថាចុះបញ្ជីដីធ្លីមួយឃុំ ឬមួយភូមិម្តង តាមការសម្រេចរបស់រាជរដ្ឋាភិបាល។ ចំណែកឯការចុះបញ្ជដីធ្លីមានលក្ខណៈដាច់ដោយដុំវិញ គឺជាយន្តការមួយដែលធ្វើការចុះបញ្ជីដីធ្លី តាមការស្នើរសុំរបស់ប្រជាពលរដ្ឋទាំងអស់ដែលមានបំណងចង់ចុះបញ្ជីដីធ្លីខ្លួន ដើម្បីធានាឲ្យមាននូវការការពារស្របច្បាប់ក្នុងនាមជាម្ចាស់នៃដីពិតប្រាកដ។

ការចុះបញ្ជីដីធ្លីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវលទ្ធផលវិជ្ជមានដោយបានផ្តល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ( ប័ណ្ណកម្មសិទ្ធិដីធ្លី ) ជូនប្រជាពលរដ្ឋតាមតម្រូវការរបស់ពួកគាត់។ ពី

មួយឆ្នាំទៅមួយឆ្នាំយើងសង្កេតឃើញថា ការស្នើសុំចុះបញ្ជីដីធ្លីរបស់ប្រជាពលរដ្ឋគឺ មានការកើនឡើងគួរឲ្យកត់សម្គាល់ ដែលនេះបានបង្ហាញឲ្យឃើញពីការយល់ដឹងរបស់ប្រជាពលរដ្ឋដែលជាម្ចាស់នៃដីធ្លី ទាក់ទងនឹងការការពារនូវដីធ្លីរបស់ពួកគេតាមរយៈការចុះបញ្ជីដី ដែលទិន្នន័យពាក់ព័ន្ធត្រូវបានគេរក្សាទុកនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីធានាសុវត្ថិភាព និងផលប្រយោជន៍ជូនម្ចាស់នៃកម្មសិទ្ធិ។ ចាប់តាំងពីរាជរដ្ឋាភិបាលកម្ពុជា អនុញ្ញាតឲ្យមានការចុះបញ្ជីដីធ្លីសម្គាល់ភាពជាម្ចាស់នៃដីធ្លី ជូនប្រជាពលរដ្ឋកម្ពុជាតាម រយៈទិន្នន័យដែលបានទទួលពីក្រសួងរៀបចំដែនដីនរគរូបនីយកម្ម និងសំណង់ បានឲ្យដឹងថា ចាប់ពីពេលផ្តើមអនុវត្តដល់ខែមេសា ឆ្នាំ២០១៩ ក្រសួងចេញប័ណ្ណកម្មសិទ្ធិដីធ្លីបានចំនួន ៥ ១៩១ ៨៥០ ប័ណ្ណ ស្មើនឹង ៧៤,១៧% នៃក្បាលដីប៉ាន់ស្មាន ៧លានក្បាលដី ក្នុងនោះការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធសម្រេចបាន ៤ ៥៧៥ ៤៨០ ប័ណ្ណ និងចែកប័ណ្ណជូនប្រជាពលរដ្ឋចំនួន ៤ ៣២៣ ៤៩៦ ប័ណ្ណ និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ៦១៦ ៣៧០ ប័ណ្ណ ( ដីរដ្ឋបាន ១ ៧៧៧ ប័ណ្ណ ទំហំ ៧៣៦ ៥៦៥ហិកតា ដីឯកជនបាន ៦១៣ ៩០៩ ប័ណ្ណ )។

ទោះបីជាដំណើរការនៃការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា អនុវត្តន៍ដោយរលូនទៅមុខយ៉ាងណាក្តី ក៏នូវតែមាននូវបញ្ហាមួយចំនួនដែលធ្វើឲ្យមាន ការរាំងស្ទះដល់ដំណើរការនៃការងារចុះបញ្ជីដីធ្លីនេះដែរ ដូចជាបញ្ហាភូមិសាស្ត្រ ធនធានមនុស្ស ហិរញ្ញវត្ថុ និងឧបករណ៍សម្រាប់ការវាស់វែងជាដើម។ ទោះបីជាការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា នៅមានបញ្ហាជាឧបសគ្គមួយចំនួនក៏ពិតមែន ប៉ុន្តែការចុះបញ្ជីដីធ្លីទាំងពីរប្រព័ន្ធ នៅតែអាចបន្តអនុវត្តន៍ទៅមុខបានយ៉ាងល្អ ហើយវាបានដើរតួរយ៉ាងសំខាន់ក្នុងវិស័យដីធ្លី ដែលជាផ្នែកមួយចូលរួមចំណែកនៅក្នុងការកំណត់ម្ចាស់កម្មសិទ្ធិស្របច្បាប់ប្រកបដោយភាពសុក្រឹត្យ ត្រឹមត្រូវ និងកាត់បន្ថយនូវវិវាទដីធ្លីដែលកើតមានឡើង។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការស្រាវជ្រាវ និងបទបង្ហាញស្តីពី ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីរីករាយ រំភើប ដោយបានសិក្សាស្វែងយល់ចំណុចនីមួយៗ នៃប្រធានបទខាងលើ ហើយយើងខ្ញុំសង្កេតឃើញថា ការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជា ថ្វីត្បិតតែមានដំណើរការអនុវត្តការងារទៅមុខក៏ពិតមែន ប៉ុន្តែនៅមានភាពចន្លោះប្រហោងនូវឡើយ ដែលតម្រូវឲ្យមានការកែសម្រួល និងយកចិត្តទុកដាក់ជាចាំបាច់ដើម្បីឲ្យការងារមួយនេះប្រព្រឹត្តទៅបានជោគជ័យ។

យើងខ្ញុំទាំងពីរនាក់មាននូវគំនិតដ៏តូចមួយ ក្នុងការចូលរួមចំណែកដើម្បីឲ្យដំណើរការអនុវត្តការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯជននៅកម្ពុជា មានភាពប្រសើរឡើងគឺៈ

+ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គួរតែបង្កើននូវប្រព័ន្ធផ្សព្វផ្សាយនានាឲ្យបានច្រើនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលត្រូវធ្វើការវិនិច្ឆ័យវាស់វែងដីធ្លី ឲ្យបានទាន់ពេលវេលា និងឆាប់រហ័សមុនពេលចាប់ផ្តើមអនុវត្តការងារចុះបញ្ជីដីធ្លី ដើម្បីឲ្យប្រជាពលរដ្ឋទទួលបាន ចំណេះដឹងទាក់ទងនឹងការចុះបញ្ជីដី ឬសារៈសំខាន់នៃការចុះបញ្ជីដីធ្លីរបស់ពួកគាត់ ហើយធ្វើឲ្យពួកគាត់មានសកម្មភាពចូលរួម និងបង្កភាពងាយស្រួលដល់មន្ត្រីក្នុងការវាស់វែង រៀបចំកែប្រែ ពន្លឿននីតិវិធីកុំឲ្យមានភាពស្មុគ្រស្មាញ ហើយការចុះបញ្ជីដីធ្លីមានរយៈពេលខ្លី និងឆាប់រហ័ស។

+ រាជរដ្ឋាភិបាល គួរតែបង្កើនការបណ្តុះបណ្តាលដល់មន្ត្រីជំនាញបន្ថែមទៀត ទៅលើនីតិវិធីនៃការចុះបញ្ជីដីធ្លី ដើម្បីបង្កើនសមត្ថភាពរបស់គាត់ឆ្លើយតបទៅនឹងទំហំនៃការងារដែលទទួលបន្ទុកជាក់ស្តែង និងបង្កើនទំហំកញ្ចប់ថវិកា បង្កើនឧបករណ៍ប្រើប្រាស់សម្រាប់ការវាស់វែងដែលមានលក្ខណៈទំនើបៗ ព្រមទាំងមានមធ្យោបាយគ្រប់គ្រាន់សម្រាប់ការធ្វើដំណើរ ដើម្បីបង្កលក្ខណៈងាយស្រួលដល់មន្ត្រីជំនាញពេលទទួលបន្ទុកការងារវាស់វែងដីធ្លី។ បង្កើតឲ្យមានវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសនៃការវាស់វែងការកំណត់ព្រំដី ការកំណត់អត្តសញ្ញាណនៃដី និងជាពិសេសការសម្របសម្រួល ដោះស្រាយបញ្ហាវិវាទដីធ្លីដែលកើតមានឡើងក្នុងកំឡុងពេលនៃការចុះបញ្ជី ដើម្បីឲ្យមន្ត្រីទាំងអស់មានសមត្ថភាពពិតប្រាកដក្នុងការអនុវត្តការងារឲ្យមានប្រសិទ្ធិភាព។

+ រាជរដ្ឋាភិបាល គួរតែបង្កើតឲ្យមាននូវវេទិកាបញ្ចេញមតិ ( ផ្ទាល់មាត់ ឬទូរសារ ) ពីប្រជាពលរដ្ឋដែលជាអ្នកទទួល និងស្នើសុំសេវាចុះបញ្ជីដីធ្លី ដើម្បីឲ្យដឹងពីការអនុវត្តការងាររបស់មន្ត្រីជំនាញ ថាតើមន្ត្រីជំនាញអនុវត្តការងារបានកម្រិតណា? ដល់កម្រិតណាហើយ? មានផលវិបាកអ្វីខ្លះ? មានការគំរាមគំហែងប្រជាពលរដ្ឋដែរឬទេ? មានអំពើពុករលួយដែរឬទេ? ហើយធ្វើការកែលម្អស្ថានភាពអវិជ្ជមានឡើងវិញ ដើម្បីឲ្យប្រជាពលរដ្ឋទុកចិត្តលើរដ្ឋាភិបាល និងផ្តល់ក្តីសង្ឃឹមយ៉ាងខ្លាំងក្លាដល់ប្រជាពលរដ្ឋពីការអនុវត្តការងាររបស់ស្ថាប័នរដ្ឋ។

+ រដ្ឋគួរតែឃ្លាំមើល និងត្រួតពិនិត្យមើលការអនុវត្តការងាររបស់អាជ្ញាធររដ្ឋបាល ក្នុងការដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋដោយហេតុថារាល់ពេលដែលរាជរដ្ឋាភិបាលប្រកាសឲ្យមានការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធនៅតំបន់ណាមួយហើយ វិវាទដែលកើតឡើងក្នុងកំឡុងពេលអនុវត្តន៍ការងារ គឺត្រូវបានពន្យាពេលសម្រាប់ការដោះស្រាយជូនប្រជាពលរដ្ឋ ដែលពេលវេលានៃការដោះស្រាយមានរយៈពេលយឺតយ៉ាវ ជាហេតុធ្វើឲ្យប្រជាពលរដ្ឋលែងមានទំនុកចិត្តលើការអនុវត្តការងាររបស់រដ្ឋាភិបាល ក្នុងការដោះស្រាយវិវាទនឹងការចុះបញ្ជីដីធ្លីរបស់ពួកគាត់។ លើសពីនេះទៅទៀតរាជរដ្ឋាភិបាល គួរតែរឹតបន្តឹងវិធានការផ្នែកខាងផ្លូវច្បាប់ឲ្យកាន់តែធ្ងន់ធ្ងរចំពោះមន្ត្រីទាំងឡាយណា ដែលបានអនុវត្តការងារផ្ទុយ ឬលើសដែនសមត្ថកិច្ចរបស់ខ្លួន ខុសពីការកំណត់របស់រាជរដ្ឋាភិបាល។ ការអនុវត្តការងារការចុះបញ្ជីដីធ្លីកម្មសិទ្ធិឯកជននៅកម្ពុជាកាន់តែមានសប្រសិទ្ធិភាព និងឆាប់រហ័សនៅពេលដែលប្រទេសកម្ពុជាមានច្បាប់រឹតបន្តឹងកាន់តែខ្លាំង ហើយការអនុវត្តការងាររបស់មន្ត្រី មានភាពរហ័សរហួន មានតម្លាភាព គ្មានអំពើពុករលួយ និងភាពអយុត្តិធម៌។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

+ សម្តេចសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ព.ស ២៥១១ គ.ស ១៩៦៧។
+ ក្រមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣។
+ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពី ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។
+ ច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/០៨០១/១៤, ៣០ សីហា ឆ្នាំ២០០១។
+ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ៨ ធ្នូ ឆ្នាំ២០០៧។
+ អនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។
+ អនុក្រឹត្យលេខ៤៦ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ស្តីពី តួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំសង្កាត់ក្នុងការចុះបញ្ជីដីធ្លី ។
+ អនុក្រឹត្យ លេខ៤៧ អនក្រ/បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។
+ អនុក្រឹត្យលេខ១២១ អនក្រ/បក, ចុះថ្ងៃទី៩ ខែមិថុនា ២០១៦ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ/បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។
+ អនុក្រឹត្យ លេខ ១២២ អនក្រ.បក, ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦, ស្តីពី ការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។
+ អនុក្រឹត្យ លេខ ១២៣ អនក្រ.តត, ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៤, ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ។
+ គោលនយោបាយដីធ្លី សៀវភៅសដីធ្លី ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៥។
+ ប្រកាស លេខ១១២ ដនស/បក, ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី។
+ ប្រកាសអន្តរក្រសួងលេខ២១៥ ប្រក/ដនស/មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី។

+ សារាចរណែនាំ លេខ០០១ ដនស/សជ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩, ស្តីពី ការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី នឹងសៀវភៅគោលបញ្ជីដីធ្លី។
+ សារាចរណែនាំ លេខ១៤ ដន/សសរណេន, ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។
+ សេចក្តីណែនាំ លេខ០៣សណន,ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពីការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី។
+ សេចក្តីណែនាំលេខ២៧៣អសដក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីវិធីកែតម្រូវឯកសារផ្លូវការ និងឪជីថល ( សម្រាប់នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។
+ នីតិទ្រព្យសម្បត្តិ បណ្ឌិត សឿន សោភ័ណ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៨។
+ ហាប់ ផល្លី,នីតិទ្រព្យសម្បត្តិ, បង្រៀនថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈឆ្នាំទី៣ នៅសាកលលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
+ សមាគមន៍សាលាត្រាជូរ ឯកសាជំនួយស្មារតី ការចុះបញ្ជីដីដាច់ដោយដុំ រៀបរៀងដោយ ជា អៀកងួន ថ្ងៃ០៧ មិថុនា ឆ្នាំ២០១៨។
+ វេទិការ នៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ឯកសារ ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា ចុះខែវិច្ឆិកា ឆ្នាំ២០១២។
+ យន្តការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា រក្សាសិទ្ធិដោយ វិទ្យាស្ថានសភាកម្ពុជា ខែកុម្ភៈ ២០១៦។
+ សៀវភៅសិក្សា និងស្រាវជ្រាវច្បាប់ភូមិបាលកម្ពុជា រៀបរៀងដោយ: East-West Management Institute Inc. (កែសម្រួលក្នុងឆ្នាំ ២០០៥) ទំព័រ២៥៥-២៥៦។
+ ឯកសារ យល់ដឹងផ្នែកច្បាប់ យន្តការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា រៀបរៀងដោយ លោកមេធាវី ថន យូសៀង និងលោក វ៉ាត់ ចាន់ធី ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ,ហ្វេសបុកផេក ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ Cambodia International Cooperation Law Group។
+ បទសម្ភាសន៍ជាមួយនឹងលោក សៀង ជៀវ អតីតប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីរាជធានីភ្នំពេញ បច្ចុប្បន្នជាមន្ត្រីជាប់កិច្ចសន្យាធ្វើការនៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីរាជធានីភ្នំពេញ ( ទទួលបន្ទុកការដោះស្រាយវិវាទដីធ្លី ), បទសម្ភាសន៍ផ្ទាល់ (២៨ ឧសភា ២០២០ )។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៨៦ អនក្រ.បក

ក្រសួង ទ.ដ.ន.ស.
លិខិតចូល
លេខ 2223
ចុះថ្ងៃទី 5-6-2002-09/15
បញ្ជូន

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៦៩៩/ ០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យ

ប្រើច្បាប់ភូមិបាល

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាព ពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

# ស ំ រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០០០ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ត្រូវបានចាត់ទុកជានិរាករណ៍ ហើយត្រូវបានជំនួសដោយអនុក្រឹត្យនេះ ដែលកំណត់នីតិវិធី នៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីតាមរយៈការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធ នៅក្នុងតំបន់ដែលបានប្រកាសថាជាទីតាំងធ្វើការវិនិច្ឆ័យដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២ .-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ និងណែនាំបច្ចេកទេសជំនាញ និងទំរង់បែបបទនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

អភិបាលខេត្ត ក្រុងត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

## ជំពូកទី ២

## សមត្ថកិច្ច និង តួនាទី

**មាត្រា ៣ .-**

នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យ ត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសំរាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ ។

សមាសភាពនៃគណៈកម្មការរដ្ឋបាលមាន :

-តំណាងអភិបាលខេត្ត ក្រុង ជាប្រធាន

-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក

-មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក

-អភិបាលស្រុក ខណ្ឌ ឬតំណាង ជាសមាជិក

-មេឃុំ ចៅសង្កាត់ ឬតំណាង ជាសមាជិក

-មេភូមិ ឬតំណាង ជាសមាជិក

-ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប ជាសមាជិក ។

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមាន :

-បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី

-ទទួលពាក្យបណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង

-ធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ

-លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ ។

មាត្រា ៥ .-

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យព្រមទាំងមន្ត្រីចាំបាច់មួយចំនួនទៀតរួមមាន : មន្ត្រីកំណត់ព្រំដី មន្ត្រីវិនិច្ឆ័យ និងមន្ត្រីវាស់វែង ដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដែលបានទទួលសេចក្តីណែនាំពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិដឹកនាំចេញសេចក្តីណែនាំចាំបាច់ដល់មន្ត្រីជំនាញ ដែលបានតែងតាំងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៤ នៃអនុក្រឹត្យនេះ ។

មន្ត្រីកំណត់ព្រំដី និងមន្ត្រីវាស់វែងមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដើម្បីកំណត់ព្រំ និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹងព្រំនៃក្បាលដីណាមួយ ។

មន្ត្រីវិនិច្ឆ័យ មានសិទ្ធិសាកសួរយកពត៌មានចាំបាច់សំរាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹងការវិនិច្ឆ័យ ។

## មាត្រា ៥ .-

ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ជនដែលមានការពាក់ព័ន្ធ មានភាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី និងការវិនិច្ឆ័យ ដោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ឯកសារ ឬភស្តុតាងផ្សេងៗដល់មន្ត្រីជំនាញ ដើម្បីអនុវត្តការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារ នៃការវិនិច្ឆ័យ និងមានសិទ្ធិសុំឱ្យមន្ត្រីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារ នៃទិន្នន័យដែលពាក់ព័ន្ធនឹងតំបន់ធ្វើការវិនិច្ឆ័យ ។

## មាត្រា ៦ .-

អភិបាលខេត្ត ក្រុង ត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងហោចណាស់ ១៥(ដប់ប្រាំ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ។

អភិបាលខេត្ត ក្រុង ត្រូវជូនដំណឹងជាសាធារណៈ អំពីពេលវេលា និងទីកន្លែង នៃកិច្ចប្រជុំផ្សព្វផ្សាយ ។ សេចក្តីជូនដំណឹងត្រូវបិទឱ្យសាធារណៈជនដឹងយ៉ាងហោច ៧(ប្រាំពីរ) ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយ ក្នុងកន្លែងដែលងាយឃើញនៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់ ។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាល ត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ញាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យ ដែលបានលើកឡើង ។

កិច្ចប្រជុំបន្ថែមសំរាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូល-ដ្ឋាន ចាត់ទុកថាជាការចាំបាច់ ។

## មាត្រា ៧ .-

មន្ត្រីកំណត់ព្រំដី ត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន ៧(ប្រាំពីរ) ថ្ងៃ យ៉ាងតិច។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមក ចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង ។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី ។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដី ត្រូវគោរពគោលការណ៍ ដូចខាងក្រោម :

ក- បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀង លើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង ។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច(ក) នៃមាត្រានេះ មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដី តាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬចំលើយផ្ទាល់មាត់ ទាក់ទងនឹងព្រំដី ។

គ-ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដី ត្រូវកំណត់ដោយអនុលោមទៅតាមចំណុច(ក) ឬ(ខ) នៃវាក្យខ័ណ្ឌទី ២ មាត្រា ៧ នៃអនុក្រឹត្យនេះ ។

ឃ-វិវាទទាំងអស់ អំពីព្រំប្រទល់ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសំរុះសំរួល និងដោះស្រាយវិវាទក្រោមមាត្រា ១២ នៃអនុក្រឹត្យនេះ។

**មាត្រា ៨ .-**

មន្ត្រីវាស់វែងដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអនុវត្តការងារវាស់វែង ដែលជាតម្រូវការក្នុងការប្រតិបត្តិនីតិវិធីវិនិច្ឆ័យ និងរៀបចំប្លង់សុរិយោដី ។

## ជំពូកទី ៣
## នីតិវិធីនៃការវិនិច្ឆ័យ

**មាត្រា ៩ .-**

មន្ត្រីវិនិច្ឆ័យដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអង្កេតរាល់ឯកសារ ភស្តុតាង និងពត៌មានផ្សេងៗជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗ ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនេះ ចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

**មាត្រា ១០ .-**

ការរៀបចំឯកសារនៃការវិនិច្ឆ័យមានន័យដូចខាងក្រោម :

១- ឯកសារនៃការវិនិច្ឆ័យត្រូវមាន :

-ប្លង់សុរិយោដី

-បញ្ជីឈ្មោះម្ចាស់ដី

-ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។ ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីនីមួយៗ ត្រូវបង្ហាញ :

ក- អត្តសញ្ញាណក្បាលដី

ខ- អត្តសញ្ញាណម្ចាស់ដី

គ- កាលបរិច្ឆេទនៃការវិនិច្ឆ័យ ។

២- ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវផ្តិតមេដៃយល់ព្រមពីម្ចាស់ដី ព្រមទាំងអ្នកជាប់ព្រំ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីវិនិច្ឆ័យ ។

៣- នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបំពេញចប់សព្វគ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវចុះហត្ថលេខាលើឯកសារទាំងនេះ ។

## មាត្រា ១១ .-

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ត្រូវមានរយៈវេលា ៣០(សាមសិប)ថ្ងៃ នៅកន្លែងដែលងាយមើលឃើញ សំរាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

អាជ្ញាធរខេត្ត ក្រុង ត្រូវផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ តាមសំណើរបស់គណៈកម្មការរដ្ឋបាល ។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ អាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណា ដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់ នៃជនណាមួយ ។ ការកែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបាន ដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

## មាត្រា ១២ .-

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយ ដែលបានចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញ អាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន ។

ក្រោយពីផ្តល់នូវការកត់សំគាល់ដ៏សមហេតុផល ដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និងបន្ទាប់ពីពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់ គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង ។

៥

ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ស្របតាមនីតិវិធី ដែលនឹងកំណត់ដោយអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

មាត្រា ១៣ .-

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ គណៈកម្មការរដ្ឋបាល ត្រូវផ្ដល់ការយល់ព្រមលើឯកសារនៃការវិនិច្ឆ័យចំពោះក្បាលដីទាំងឡាយណាដែលមិនមានទំនាស់ ។

បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខា ហើយបញ្ជូនទៅអភិបាលខេត្ត ក្រុងចុះហត្ថលេខា ។

មាត្រា ១៤ .-

ក្រោយពីអភិបាលខេត្ត ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាហើយ ឯកសារនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដីដែលមិនមានទំនាស់ ។ ចំពោះឯកសារនៃការវិនិច្ឆ័យ ដែលនៅពាក់ព័ន្ធនឹងវិវាទ នឹងត្រូវបញ្ចប់ជាស្ថាពរ នៅពេលមានការដោះស្រាយចប់សព្វគ្រប់ដោយគណៈកម្មការសុរិយោដី ឬដោយតុលាការ ។

នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរយោងតាមវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ឯកសារនៃការវិនិច្ឆ័យព្រមទាំងឯកសារទាំងអស់ ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដី ដើម្បី ចុះបញ្ជី ។

ក្រោយពេលក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យ ត្រូវបានចុះបញ្ជីហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លើគ្រប់ក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យនេះ ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិអោយខេត្ត ក្រុងណាដែលមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យនៃខេត្ត ក្រុងរបស់ខ្លួន ។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសារលេខបង្វែង១ នឹងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ១៦
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

# ស ំ រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ..**

អនុក្រឹត្យនេះ មានគោលដៅកំណត់ចេនាសម្ព័ន្ធ បេសកកម្ម និង មុខងារ របស់គណៈកម្មការសុរិយោដី។

**មាត្រា ២ ..**

អនុក្រឹត្យនេះអនុវត្តចំពោះវិវាទ ដែលទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី។ ក្នុងករណីនេះ គណៈកម្មការសុរិយោដីមានសិទ្ធិសំរេចមុនគេក្នុងការទទួលស្គាល់ភោគីស្របច្បាប់។

## ជំពូកទី ២
## ចេនាសម្ព័ន្ធ និង បេសកកម្ម

**មាត្រា ៣ ..**

គណៈកម្មការសុរិយោដី ត្រូវមានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី ដូចតទៅ :

១.-វិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ

២.-វិវាទ ដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ និងដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល។

**មាត្រា ៤ ..**

គណៈកម្មការសុរិយោដី មានចេនាសម្ព័ន្ធដូចតទៅ :

១.-គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានអក្សរកាត់ថា គ.ស.ស.ខ មានទីតាំងនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

២.-គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានអក្សរកាត់ថា គ.ស.ខ.ក មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

៣.-គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានអក្សរកាត់ថា គ.ស.ជ មានទីតាំងនៅក្នុងទីស្តីការក្រសួង

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋាន ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។

## ជំពូកទី ៣

## គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៥ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ហើយត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិក។

ប្រធានគណៈកម្មការនេះ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និង ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក។

**មាត្រា ៦ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានភារកិច្ចសម្រុះសម្រួលវិវាទ ដែលកើតមានឡើងនៅក្រៅតំបន់វិនិច្ឆ័យ។ ការសម្រុះសម្រួលវិវាទ ត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី។

## ជំពូកទី ៤

## ការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ

**មាត្រា ៧ ..**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទំរង់បែបបទនៃពាក្យបណ្តឹង។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចុះបញ្ជី និងបើកសំណុំរឿងនៃពាក្យបណ្តឹងដែលបានទទួល។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ និងសាកសួរថាតើភាគីវិវាទយល់ព្រមធ្វើការដោះស្រាយសម្រុះសម្រួលតាមនីតិវិធីនេះឬទេ ។

**មាត្រា ៨ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើវិវាទ ។ ការស៊ើបអង្កេតរួមមាន ការបញ្ជាក់អំពីទីតាំងនៃក្បាលដី ដែលមានវិវាទ និងភាគីពាក់ព័ន្ធ និងអំពីកម្មវត្ថុនៃវិវាទ និងការប្រមូលឯកសារ ដែលមានចម្លើយរបស់សាក្សី និងពតិមានទាក់ទងនឹងក្បាលដីមានវិវាទ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះ សំរាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកសាង និង បញ្ចូលឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ។

**មាត្រា ៩ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវសម្រុះសម្រួលវិវាទក្រៅពីករណី ដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

ការសម្រុះសម្រួលត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ១០ ..**

បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធមិនៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាង ចំពោះករណីដូចតទៅ :

(១) ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភោគីតូចតាចមួយចំនួនដែរ ។

(២) ភាគីម្ខាងនៃវិវាទ គឺជាអាជ្ញាធរមានឋានៈខ្ពស់ ។

(៣) ករណីមានវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

(៤) វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

**មាត្រា ១១ ..**

ប្រសិនបើការដោះស្រាយអាចសំរេចបានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ហើយត្រូវចម្លងជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌមួយច្បាប់ ដើម្បីចាប់ផ្តើមដំណើរការ

អនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។

## ជំពូកទី ៥
## គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

**មាត្រា ១២ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម :

-អភិបាល ឬ អភិបាលរងខេត្ត ក្រុង ជាប្រធាន

-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង អាចអញ្ជើញតំណាងស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្ត ក្រុង ដែលពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាដហុក ។

**មាត្រា ១៣ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានភារកិច្ចសម្រុះសម្រួលវិវាទដូចមានចែងក្នុងមាត្រា ១០ និង មាត្រា ១១ វាក្យខ័ណ្ឌទី ២ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**មាត្រា ១៤ ..**

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានមុខងារ ភារកិច្ចដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង រាល់ពាក្យបណ្ដឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផល នៃការសម្រុះសម្រួល

-បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះ ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ ក្នុងករណីការសម្រុះសម្រួលបានសំរេច ត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ

-រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៦
## ការសម្រុះសម្រួលនៅថ្នាក់ខេត្ត ក្រុង

### មាត្រា ១៥ ..

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ពុំមានសិទ្ធិសំរេចលើករណីវិវាទណាមួយទេ ប៉ុន្តែអាចបញ្ចប់វិវាទបាន ក្នុងករណីភាគីវិវាទទាំងអស់ព្រមព្រៀងគ្នាជាឯកច្ឆន្ទ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង សំណុំរឿងវិវាទនេះ ត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

### មាត្រា ១៦ ..

ប្រសិនបើការសម្រុះសម្រួលអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីចាប់ផ្តើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្រុះសម្រួល ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## ជំពូកទី ៧
## គណៈកម្មការសុរិយោដីថ្នាក់ជាតិ

**មាត្រា ១៧ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមាសភាពដូចខាងក្រោម :

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន
- រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ជាសមាជិក
- រដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ឱ្យមកចូលរួមជាសមាជិកអាដហុក ។

**មាត្រា ១៨ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្ដីសំរេចលើវិវាទដីភោគៈ ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាលពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា ១៦ និងវិវាទដែលមានចែងក្នុងចំណុចទី ២ នៃមាត្រា ៣ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**មាត្រា ១៩ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។ លេខាធិការដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលត្រូវ

តែងតាំងដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានតួនាទីដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើកំណត់ហេតុអំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយ

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ

-រៀបចំ និងតំកល់ទុកឯកសារ ។

## ជំពូកទី ៨
## ការដោះស្រាយនៅថ្នាក់ជាតិ

**មាត្រា ២០ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្តីសំរេចទទួលស្គាល់ភោគីឬកម្មសិទ្ធិករស្របច្បាប់ ។

ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្តឹងទៅតុលាការ ដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ២១ ..**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ដែលទាក់ទងនឹងវិវាទ ហើយប្រសិនបើយល់ឃើញថាចាំបាច់ អាចបញ្ជាឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងរៀបចំបើកសវនាការមុនពេលធ្វើសេចក្តីសំរេចលើវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យដើម្បីបើកសវនាការអំពីវិវាទ តាមការស្នើសុំរបស់ភាគីណាមួយ ។

ក្នុងករណីដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការពិគ្រោះយោបល់ជាមួយភាគីណាមួយ នោះភាគីផ្សេងៗទៀត មានសិទ្ធិទទួលបានការជូនដំណឹងជាមុន អំពីការពិគ្រោះយោបល់នេះ ដើម្បីមានវត្តមាននៅក្នុងការពិគ្រោះយោបល់ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិយល់ឃើញថាចាំបាច់ ។

## មាត្រា ២២ ..

សេចក្តីសំរេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសេចក្តីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្តីសំរេច ។

## មាត្រា ២៣ ..

ភាគីវិវាទ មានសិទ្ធិស្នើឱ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់ លើការសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្តឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសំរេច ។

ប្រសិនបើតុលាការបញ្ជូនរឿងក្តីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទអំពីផលប្រយោជន៍ ឬដោយមិនបានផ្តល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដី ត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

ភាគីដែលស្នើសុំការពិនិត្យឡើងវិញផ្នែកច្បាប់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹង ទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ លេខាធិការដ្ឋាន ត្រូវធានាការពារសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីចំពោះតុលាការ ។

តុលាការ ត្រូវផ្ញើច្បាប់ចម្លងនៃសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរ មកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីចាត់ចែងដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីដី ។

ប្រសិនបើគ្មានបណ្តឹងក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រានេះ នោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចាត់ទុកជាស្ថាពរ ។

## ជំពូកទី ៩
## ការចុះបញ្ជី

**មាត្រា ២៤ ..**

បន្ទាប់ពីសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសុពលភាពអាចអនុវត្តបាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្ដីសំរេចនោះ ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់ ។

## ជំពូកទី ១០
## បទប្បញ្ញត្តិវដ្ឋបាល

**មាត្រា ២៥ ..**

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះ ត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ ។

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ។ ប្រសិនបើចាំបាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យធ្វើជាប្រធានអាដហុក ដើម្បីដោះស្រាយករណីវិវាទនេះ ។

**មាត្រា ២៦ ..**

ជនដែលត្រូវបានបញ្ជាក់ថាជាកម្មសិទ្ធិករ ឬភោគីស្របច្បាប់ នៃក្បាលដី ដែលមានវិវាទក្រោមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវានៃការចុះបញ្ជីក្បាលដី អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល ។

**មាត្រា ២៧ ..**

ភាគីវិវាទ ត្រូវបានជូនដំណឹងជាមុនក្នុងរយៈពេលមួយសមហេតុផល អំពីការប្រជុំដើម្បីសម្រុះសម្រួល ឬសំរេចលើវិវាទក្រោមអនុក្រឹត្យនេះ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីជួយខ្លួន ក្នុងពេលសម្រុះសម្រួលវិវាទនៅគ្រប់ថ្នាក់ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីធ្វើជាតំណាងរបស់ខ្លួន ក្នុងពេលប្រជុំធ្វើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដី ។

ភាគីវិវាទ មានសិទ្ធិបង្ហាញភស្តុតាងផ្ទាល់មាត់ ឬឯកសារជាក់ស្តែងដែលទាក់ទងនឹងវិវាទ ដែលត្រូវចាត់ទុកជាចំណែកមួយនៃឯកសារផ្លូវការនៃវិវាទ ។

ការប្រជុំរបស់គណៈកម្មការសុរិយោដីត្រូវធ្វើឡើងជាសាធារណៈ ។

គណៈកម្មការសុរិយោដី ត្រូវរក្សាឯកសារផ្លូវការនៃវិវាទនីមួយៗ ដែលរួមមានឯកសារទាំងអស់ និងភស្តុតាងជាក់ស្តែងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ អំពីវិវាទ ។ ឯកសារផ្លូវការដែលទាក់ទងនឹងវិវាទ ត្រូវបានបើកឱ្យភាគីពាក់ព័ន្ធពិនិត្យ ។

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអមដោយរបាយការណ៍ស្តីពីដំណើររឿង និងដំណើរការដោះស្រាយវិវាទ ដែលផ្អែកលើភស្តុតាងទាំងឡាយ ដែលអាចទុកចិត្តបាន និងត្រឹមត្រូវ ដែលជាផ្នែកនៃឯកសារផ្លូវការ ។

ច្បាប់ចម្លងនៃសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱ្យភាគី វិវាទនីមួយៗ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ២៨ ..**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ១១
## ប្រភពធនធាន

**មាត្រា ២៩ .-**

គណៈកម្មការសុរិយោដី មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៣០ .-**

ប្រភពធនធាន និងថវិកា របស់គណៈកម្មការសុរិយោដី ត្រូវបានផ្តល់ដោយ ៖

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេសក្រៅ ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ៣១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត ក្រុងទាំងអស់ និងមន្ត្រី ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៨ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០២

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់នីតិវិធីនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំនូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុងតំបន់ដែលមិនទាន់បានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។

## ជំពូកទី ២

## ភារកិច្ច និងភាតព្វកិច្ច

**មាត្រា ២.-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចណែនាំ សប្រមសម្រួល និងពិនិត្យតាមដានការអនុវត្តអនុក្រឹត្យនេះ ។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវកំណត់ស្តង់ដារបច្ចេកទេសសំរាប់ការកំណត់ព្រំដី ការកសាងប្លង់សុរិយោដី និងការកសាងឯកសារផ្សេងៗ ព្រមទាំងកំណត់គំរូឯកសារដែលត្រូវប្រើក្នុងនីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ ត្រូវទទួលខុសត្រូវក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រាល់ក្បាលដី ដែលស្នើសុំចុះបញ្ជីក្រោមអនុក្រឹត្យនេះក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌណាមួយ មិនអាចបំពេញតាមលក្ខខណ្ឌសំរាប់ការចុះបញ្ជីក្រោមអនុក្រឹត្យនេះ ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ដោយសារតែសមត្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌនោះ អាចស្នើសុំអោយរដ្ឋបាលសុរិយោដីខេត្ត ក្រុង ជួយដល់ការអនុវត្តនូវការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

**មាត្រា ៣.-**

មន្ត្រីទទួលបន្ទុកការងារកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុ នៅពេលធ្វើការអង្កេតវាស់វែង និងអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និង ភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដី ឬសិទ្ធិលើក្បាលដី ។

**មាត្រា ៤.-**

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកងកំលាំងប្រដាប់អាវុធ ឱ្យជួយជ្រោមជ្រែងក្នុងការអនុវត្តការងារវាស់វែង ។

**មាត្រា ៥.-**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដោយផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាង ដែលទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ តាម

សំណូមពររបស់មន្ត្រីទទួលបន្ទុក ។

ក្នុងពេលចុះកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ក្នុងករណីអវត្តមានអ្នកដាក់ពាក្យ ឬតំណាងស្របច្បាប់ ការកំណត់ព្រំក្បាលដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន ឬ/និងភស្តុតាងដែលមានលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ដែលទាក់ទងនឹងព្រំដី ។

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកម្ម ឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ត្រូវទទួលការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥២ នៃច្បាប់ភូមិបាល ។

**មាត្រា ៦.-**

ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួមសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យដោយផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗ តាមសំណូមពររបស់មន្ត្រីទទួលបន្ទុក ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ។

## ជំពូកទី ៣
## អំពីនីតិវិធីនៃការចុះបញ្ជីដី

**មាត្រា ៧.-**

សាមីអ្នកកាន់កាប់ដីដែលស្នើសុំចុះបញ្ជីដី ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីតាមគំរូដែលបានកំណត់ មករដ្ឋបាលសុរិយោដីស្រុក ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

ពាក្យស្នើសុំត្រូវមាន :

- ឈ្មោះ និងស្នាមមេដៃរបស់អ្នកដាក់ពាក្យ
- ការពិពណ៌នាលំអិតអំពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងរបស់ក្បាលដីនោះ
- ឯកសារ ឬ/និងភស្តុតាងផ្សេងៗ ទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី ។

**មាត្រា ៨.-**

ពាក្យស្នើសុំត្រូវបានពិនិត្យដោយរដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ ផ្អែកតាមឯកសារដែលមាន និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជី ។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌត្រូវកត់ត្រាចូលក្នុងសៀវភៅទទួលពាក្យ និងកំណត់កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈមិនសមស្រប រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ ត្រូវចារលើពាក្យដោយបញ្ជាក់ពីមូលហេតុដែលមិនអាចអនុវត្តនីតិវិធីនៃការចុះបញ្ជីបាន ។ អ្នកដាក់ពាក្យមានសិទ្ធិប្តឹងតវ៉ា ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

ក្នុងករណីពិនិត្យឃើញថា មានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ ត្រូវបញ្ជូនវិវាទនោះទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក ខ័ណ្ឌ តាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

**មាត្រា ៩.-**

អភិបាលស្រុក ខ័ណ្ឌ ត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី ទៅអ្នកដាក់ពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃយ៉ាងតិចមុនកាលបរិច្ឆេទ នៃការកំណត់ព្រំដី នៅសាលាស្រុក ខ័ណ្ឌ សាលាឃុំ សង្កាត់ និងនៅទីកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

**មាត្រា ១០.-**

មន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងវាស់វែង ត្រូវកំណត់ព្រំក្បាដីដែលស្នើសុំចុះបញ្ជី តាមពេលវេលាដែលបានជូនដំណឹង ដោយយោងតាមសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំរបស់រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ ។

នៅពេលធ្វើការកំណត់ព្រំក្បាលដី មន្ត្រីទទួលបន្ទុកត្រូវពិនិត្យឯកសារដែលមាន ភស្តុតាង និងព័តិមានជាលាយលក្ខណ៍អក្សរ និងពតិមានផ្ទាល់មាត់ផ្សេងៗ ដែលទាក់ទងនឹងព្រំប្រទល់ក្បាលដី ដែលស្នើសុំចុះបញ្ជី ហើយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម :

ក-ក្នុងករណីអ្នកដាក់ពាក្យ និងម្ចាស់ដីជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមការព្រមព្រៀង ។

ខ-ក្នុងករណីម្ចាស់ដីជាប់ព្រំ មិនមានវត្តមាន ការកំនត់ព្រំដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន និងភស្តុតាងដែលជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ និងភស្តុតាងផ្ទាល់មាត់ ដែលទាក់ទងនឹងព្រំដីនោះ ។

គ-ក្នុងករណីក្បាលដីដែលស្នើសុំចុះបញ្ជីស្ថិតនៅជាប់នឹងដីសាធារណៈ ឬ ជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវធ្វើដោយយោងតាមចំណុច (ក) ឬ (ខ) ខាងលើ ។

វិវាទអំពីព្រំដីដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក ខ័ណ្ឌ តាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី ។

ការវាស់វែង ត្រូវធ្វើក្រោយពីបានកំណត់ព្រំក្បាលដីរួច ។

**មាត្រា ១១.-**

មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវអង្កេតលើឯកសារដែលមាន ភស្តុតាង និងពតិមានជាលាយលក្ខណ៍អក្សរ និងពតិមានផ្ទាល់មាត់ទាក់ទង នឹងសិទ្ធិលើក្បាលដី ដែលស្នើសុំចុះបញ្ជី ។

ចំពោះដីភោគៈ ការវិនិច្ឆ័យត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម :

ក-ដីដែលស្នើសុំចុះបញ្ជី ត្រូវតែបានកាន់កាប់មុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១

ខ-ដីដែលស្នើសុំចុះបញ្ជី ត្រូវបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ :

-ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ហើយចំណុចព្រំក្បាលដី មាននិយាមការច្បាស់លាស់ អាចត្រូវបាន ស្នើផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីនោះ

-ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ប៉ុន្តែចំនុចព្រំក្បាលដី មិនទាន់មាននិយាមកាច្បាស់លាស់ អាចត្រូវបាន ស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ

-ក្នុងករណីកាន់កាប់តិចជាងប្រាំឆ្នាំ អាចត្រូវបានស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ ។

អចលនវត្ថុរបស់រដ្ឋ ត្រូវបានចុះបញ្ជីជាទ្រព្យសម្បត្តិសាធារណៈ ឬជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ស្របតាមបទប្បញ្ញត្តិនៃជំពូកទី ២ នៃច្បាប់ភូមិបាល ។

**មាត្រា ១២.-**

ផ្អែកតាមការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌត្រូវរៀបចំឯកសារ នៃការវិនិច្ឆ័យ រួមមាន :

- ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី
- ផែនទីក្បាលដី និងគំនូសបង្ហាញទីតាំងដី
- បញ្ជីឈ្មោះម្ចាស់ក្បាលដីដែលស្នើសុំចុះបញ្ជី ។

ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី កម្មសិទ្ធិករ ឬភោគី កាលបរិច្ឆេទនៃការកាន់កាប់ដី កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រាល់សិទ្ធិ និងបន្ទុកដែលមានលើក្បាលដីដូចមានចែងក្នុងច្បាប់ភូមិបាល ។

ផែនទីក្បាលដីដែលស្នើសុំចុះបញ្ជី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី រួមមាន លេខក្បាលដី រូបរាង ក្បាលដី លេខក្បាលដី ឬ/និងឈ្មោះម្ចាស់ក្បាលដីជាប់ព្រំ ។

បញ្ជីឈ្មោះម្ចាស់ដីនៃក្បាលដីដែលស្នើសុំចុះបញ្ជី បង្ហាញអំពីឈ្មោះ សាវតា ប្រភេទទ្រព្យរបស់កម្មសិទ្ធិករ ឬភោគីនៃក្បាលដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ ទំហំ និងរូបភាពប្រើប្រាស់ដី ។

**មាត្រា ១៣.-**

បន្ទាប់ពីការពិនិត្យភាពច្បាស់លាស់ខាងបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ ត្រូវចុះហត្ថលេខាលើទម្រង់បែបបទ នៃការប្រមូលទិន្នន័យក្បាលដី ។

ឯកសារនៃការវិនិច្ឆ័យដែលត្រូវផ្សព្វផ្សាយរួមមាន ផែនទីក្បាលដី គំនូសបង្ហាញទីតាំងដី និងបញ្ជីឈ្មោះម្ចាស់ដី ។ ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅសាលាស្រុក ខ័ណ្ឌដែលមានសមត្ថកិច្ច ។ សេចក្តីថតចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយផងដែរ នៅទីស្នាក់ការឃុំ សង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

អភិបាលស្រុក ខណ្ឌ ត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យនេះដល់អ្នកដាក់ពាក្យ

ស្នើសុំចុះបញ្ជីដី ។ សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច ៧( ប្រាំពីរ ) ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញ នៅក្នុងភូមិ នៅសាលាឃុំ សង្កាត់ និងនៅសាលាស្រុក ខ័ណ្ឌ ។

**មាត្រា ១៤.-**

ក្នុងរយៈពេលនៃការផ្សព្វផ្សាយ ជនដែលមានផលប្រយោជន៏ទាក់ទងនឹងក្បាលដីដែលស្នើសុំចុះបញ្ជី អាចជូនដំណឹងអំពីការជំទាស់របស់ខ្លួនទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្នុងករណីពិនិត្យឃើញថា ឯកសារនៃការវិនិច្ឆ័យ ដែលបានបិទផ្សាយជាសាធារណៈ មានលក្ខណៈមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ។ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើការជំទាស់នោះ ដោយផ្អែកតាមឯកសារ និងពតិមានទាំងអស់ ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈសមហេតុផល រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ អាចធ្វើការកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងដែលមិនប៉ះពាល់ដល់ផលប្រយោជន៏ស្របច្បាប់នៃជនណាមួយ ។

ការកែតម្រូវផ្សេងទៀតក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈមិនសមហេតុផល ការជំទាស់ត្រូវបានដាក់ឱ្យធ្វើការសម្រុះសម្រួល និងដោះស្រាយតាមនីតិវិធី ដែលមានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

**មាត្រា ១៥.-**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ ត្រូវបញ្ចូលក្បាលដីទៅក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ ។

ផែនទីមានលក្ខណៈដាច់ដោយដុំគឺជាប្លង់សុរិយោដីដែលបង្ហាញអំពីទីតាំង លេខ និងព្រំប្រទល់នៃក្បាលដីទាំងឡាយដែលបានចុះបញ្ជីរួច និងក្បាលដីដែលស្នើសុំចុះបញ្ជី បន្ទាប់ពីបានបិទផ្សាយជាសាធារណៈ និងបានបញ្ចប់ការសម្រុះសម្រួល និង ការដោះស្រាយទំនាស់ ។

**មាត្រា ១៦.-**

រដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌត្រូវផ្ញើសំណុំឯកសារទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុងដូចមានខាងក្រោម :

- ពាក្យស្នើសុំចុះបញ្ជីដី
- ឯកសារនៃការវិនិច្ឆ័យ
- សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី
- ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ
- សេចក្តីជូនដំណឹងពីការបិទផ្សាយជាសាធារណៈ
- របាយការណ៏ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ

- ពាក្យបណ្តឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន

- លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន

- កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន ។

ក្នុងករណីដែលពិនិត្យឃើញថា ឯកសារទាំងនោះគ្រប់គ្រាន់ និងត្រឹមត្រូវហើយ រដ្ឋបាលសុរិយោដីខេត្ត ក្រុងត្រូវចុះហត្ថលេខា រួចបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល ។

**មាត្រា ១៧.-**

ក្បាលដីត្រូវបានចុះបញ្ជី នៅពេលដែលអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ឬរដ្ឋបាលសុរិយោដីខេត្ត ក្រុងដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកត់ត្រារួចហើយក្នុងសៀវភៅគោលបញ្ជីដី ។

**មាត្រា ១៨.-**

បន្ទាប់ពីក្បាលដីត្រូវបានចុះបញ្ជីរួច រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុឱ្យកម្មសិទ្ធិករនៃក្បាលដីដែលបានចុះបញ្ជី ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឱ្យភោគីដែលបានចុះបញ្ជី ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិអោយខេត្ត ក្រុងណា ដែលមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ។

**មាត្រា ១៩.-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវបញ្ជូនតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុងដែលមិនទាន់បានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា ហើយបញ្ជូនតារាងនេះបន្តទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នាដែរ ។

រដ្ឋបាលសុរិយោដីខេត្ត ក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវផ្ញើតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីស្រុក ខ័ណ្ឌ និងផ្ញើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដើម្បីចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា ។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសារវណបផ្សេងៗ ត្រូវកំណត់ដោយក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ២០.-**

សោហ៊ុយសេវាផ្សេងៗដែលទាក់ទងទៅនឹងការបំពេញភារកិច្ចក្នុងការអនុវត្តអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរួម អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត ក្រុង

-ដូចមាត្រា ២២

-ឯកសារ កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
លេខ :...៣៧៧ សហវ...

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០២

ប្រកាសអន្តរក្រសួង
ស្តីពី
ការកំណត់ចំណូលពីរសាថ៊ុយសេវាសុរិយោដី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ដែលប្រកាសឱ្យ ប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិង សំណង់

-អនុវត្តតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតភ្នាក់ងារ ត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាឯរដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល ។

C:\2002\Land Management\Prokas

-អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

-អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

-អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋនេយ្យ ចំណូល

-តាមការចាំបាច់ក្នុងការអនុវត្តន៍ច្បាប់ភូមិបាល

## សំរេច

**ប្រការ ១:** អនុញ្ញាតឱ្យយកសោហ៊ុយសេវាសុរិយោដីលើការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ការចេញប័ណ្ណទុតិយតា ការចេញប័ណ្ណតតិយតា ការផ្ទេរសិទ្ធិលើអចលនវត្ថុ ការចេញលិខិតបញ្ជាក់សុរិយោដី (ហ៊ីប៉ូតែក បញ្ចាំ ដាក់ធានា) ការចេញសាលាកប័ត្រពត៌មាន ការចេញលិខិតបញ្ជាក់ សុរិយោដី និងការថតចំលងឯកសារ ព្រមទាំងការបំពេញបែបបទ ឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការងារ សុរិយោដី ។

**ប្រការ ២:** សោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់ដូចតទៅ :

| ល.រ | បរិយាយ | សោហ៊ុយសេវាសុរិយោដី | | |
|---|---|---|---|---|
| | | ដីផលិតកម្ម ឬ ដីភោគ | ដីរបំនៅឋ្ឋាន និង ដីសំរាប់សំណង់ទូទៅ | |
| | | | ជនបទ ឬ ក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត |
| ១ | ការចេញប័ណ្ណ ឬ ប័ណ្ណទុតិយតា ឬប័ណ្ណតតិយតា " ក្នុង ១ក្បាលដី " | ៥.០០០៖០០ | ១០០.០០០៖០០ | ៣៥០.០០០៖០០ |
| ២ | ការផ្ទេរអចលនវត្ថុ(ផ្ទេរដោយបំបែក ឬ ផ្ទេរទាំងមូល" ក្នុង ១ប័ណ្ណ" | ៥០.០០០៖០០ | ៨០.០០០៖០០ | ១០០.០០០៖០០ |
| ៣ | ការបង្រួមក្បាលដី " ក្នុង ១ក្បាលដី " | ១០០.០០០៖០០ | ១២០.០០០៖០០ | ១៥០.០០០៖០០ |
| ៤ | ការចេញលិខិតបញ្ជាក់(ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា) ក្នុង ១ក្បាលដី " | ១៥.០០០៖០០ | ១៨.០០០៖០០ | ២០.០០០៖០០ |
| ៥ | ការចេញសាលាកប័ត្រពត៌មាន " ក្នុង ១ក្បាលដី " | ១៥.០០០៖០០ | ១៨.០០០៖០០ | ២០.០០០៖០០ |
| ៦ | ការចេញលិខិតបញ្ជាក់សុរិយោដី ក្នុង ១ក្បាលដី " | ១៥.០០០៖០០ | ១៨.០០០៖០០ | ២០.០០០៖០០ |

C:\2002\Land Management\Prokas

2/5

ចំពោះការផ្ទេរសិទ្ធិលើអចលនវត្ថុ សោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់អ្នកទទួលសិទ្ធិ ។ អ្នកទទួលសិទ្ធិអចលនវត្ថុក៏ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់សារពើពន្ធជាធរមាន ។

ប្រការ៣ : សោហ៊ុយសេវាសុរិយោដីលើការវាស់វែងដីដោយប្រើឧបករណ៍វាស់ស្ទង់ទំនើបត្រូវបាន កំណត់ដូចខាងក្រោម :

| ល.រ | បរិយាយ | សោហ៊ុយក្នុង១ហិកតា |
|---|---|---|
| ១ | ទំហំដីតិចជាង ១០ ហិកតា | ៣០.០០០៛០០ |
| ២ | ទំហំដីចាប់ពី ១០ ហិកតា ដល់ ៥០ ហិកតា | ១៥.០០០៛០០ |
| ៣ | ទំហំដីចាប់ពី ៥១ ហិកតា ដល់ ៣០០ ហិកតា | ១០.០០០៛០០ |
| ៤ | ទំហំដីចាប់ពី ៣០១ ហិកតា ដល់ ១.០០០ ហិកតា | ៨.០០០៛០០ |
| ៥ | ទំហំដីចាប់ពី ១.០០០ ហិកតាឡើងទៅ | ៦.០០០៛០០ |

ចំពោះដីដែលមានទីតាំងឆ្ងាយលើសពី៥០គីឡូម៉ែត្រពីអង្គភាពសុរិយោដី ម្ចាស់ដីត្រូវទទួល បន្ទុកបន្ថែមលើ :

១.សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក របស់មន្ត្រីជំនាញ ។

២.ថ្លៃបង្គោល និងការដាំបង្គោលព្រំ ។

៣.ចំពោះតំបន់ព្រៃភ្នំ សោហ៊ុយសេវាសុរិយោដីត្រូវគិតបន្ថែម២០% លើសោហ៊ុយសេវា វាស់វែងសរុប ។

ប្រការ៤ : រាល់ទំរង់បែបបទឯកសារសុរិយោដីដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមនីតិវិធី សុរិយោដី ។

ប្រការ៥ : -ការបង់ប្រាក់និងការទទួលប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមរយៈ រដ្ឋទេយ្យករចំណូល នៅថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង។

-ក្នុងករណីចាំបាច់អាចបង្កើតរដ្ឋទេយ្យករចំណូលរង នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខ័ណ្ឌ ។

-ការបោះពុម្ពនិងការបើកផ្តល់បណ្ណចំណូលពីសោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់ ថវិការដ្ឋដែលចាត់ចែងអនុវត្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

C:\2002\Land Management\Prokas

<u>ប្រការ៦ :</u> ការគ្រប់គ្រងចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមនិតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ ។

<u>ប្រការ ៧ :</u> ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់បែងចែកដូចខាងក្រោម :

១. ៧៥% សំរាប់បង់ចូលថវិការដ្ឋក្នុងនោះមាន៣៥% ដែលជាចំណែករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សំរាប់ចាត់ចែងចំណាយដល់អង្គភាពជំនាញសុរិយោដីក្រោមឱវាទ ។

២. ១៥% សំរាប់បំរើឱ្យគុណប្រយោជន៍ថវិការបស់ខេត្ត-ក្រុងក្នុងនោះមាន ៥% ដែលជាចំណែករបស់ស្រុក-ខណ្ឌ ។

៣. ១០% សំរាប់បំរើឱ្យគុណប្រយោជន៍ថវិការបស់ឃុំ-សង្កាត់ ។

<u>ប្រការ ៨ :</u> ចំណូលពីសោហ៊ុយសេវាសុរិយោដីត្រូវបង់ចូលថវិការដ្ឋនិងថវិកាខេត្ត-ក្រុងនៅរតនាគារខេត្ត- ក្រុងដោយកត់ត្រានៅក្នុងជំពូក៧១ ប្រការ ០៣ កថាខ័ណ្ឌ១៩ ។ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដី ត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះ ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្នុង១ត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសលាកបត្របង់ប្រាក់ ។

<u>ប្រការ ៩ :</u> ផ្អែកលើការបូកសរុបសភាពការណ៍បង់ចំណូលប្រចាំត្រីមាសដូចមានចែងនៅក្នុងប្រការ៨ខាងលើ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ត្រូវលើកសំណើសុំចំណាយក្នុងរង្វង់ ៣៥%នៃចំណូលដែលបានបង់ចូលថវិការដ្ឋមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួលជូនវិញ តែត្រូវភ្ជាប់មកជាមួយ នូវ :

-សលាកបត្របង់ប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី

-របាយការណ៍ចំណាយនៃចំណែក៣៥%ដែលថវិការដ្ឋបានបើកផ្តល់លើកមុនដោយមានភ្ជាប់មកជាមួយនូវសក្ខីបត្រគ្រប់គ្រាន់និងត្រឹមត្រូវ ។

និតិវិធីនៃការបើកផ្តល់ចំណាយ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក ១១.០១.១៨.០២ ។

<u>ប្រការ ១០ :</u> បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

<u>ប្រការ ១១ :</u> អគ្គលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធានរតនាគារជាតិ អង្គភាពពាក់ព័ន្ធទាំងអស់ ដែល ...

ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់មានភារៈកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ។

<u>ប្រការ ១២ :</u> ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "

- ដូចប្រការ១១ " ដើម្បីអនុវត្ត "
- ឯកសារ និង កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៧ សជណ,បក

# សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល
# ស្តីពី
# គោលនយោបាយដីធ្លី

ដោយយល់ឃើញពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព ផលិតភាព និរន្តរភាពបរិស្ថាន និងដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវចក្ខុវិស័យ គោលបំណង និងសកម្មភាពទាំងឡាយក្នុងវិស័យដីធ្លីដូចខាងក្រោម ÷

ចក្ខុវិស័យនៃគោលនយោបាយដីធ្លីនៅកម្ពុជាគឺ "គ្រប់គ្រង រៀបចំ ប្រើប្រាស់ និងបែងចែកដី ប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព ដើម្បីរួមចំណែកធ្វើឱ្យសំរេចគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាន និងធនធានធម្មជាតិ កិច្ចការពារជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងបរិបទសេដ្ឋកិច្ចទីផ្សារ" ។

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចជំរុញ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយដីធ្លីស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ព្រមទាំងសម្របសម្រួលរវាងអនុវិស័យដីធ្លីទាំងបី (រដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី) ក្នុងការអនុវត្តន៍ច្បាប់ភូមិបាល និងច្បាប់ដទៃទៀត ដែលពាក់ព័ន្ធនឹងបរិស្ថាន ព្រៃឈើ ជលផល ធនធានទឹក ក្រមរដ្ឋប្បវេណី វិមជ្ឈការ និងវិសហមជ្ឈការ ។ល។

គោលបំណង និងសកម្មភាពពាក់ព័ន្ធនឹងអនុវិស័យដីធ្លីទាំងបីរួមមាន ÷

**ក.អនុវិស័យរដ្ឋបាលដីធ្លី** (**Land Administration**)

**គោលបំណងនៃរដ្ឋបាលដីធ្លីគឺ** ធ្វើការចុះបញ្ជីកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុទាំងអស់ (រដ្ឋ និងឯកជន) ឱ្យបានច្បាស់លាស់ ធ្វើការផ្ទេរសិទ្ធិលើទ្រព្យទាំងនោះជាផ្លូវការ ទប់ស្កាត់ និងដោះស្រាយវិវាទដីធ្លី សំដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ធានាបាននូវទំនុកចិត្ត និងប្រសិទ្ធភាពនៃទីផ្សារដីធ្លី ។

ការចុះបញ្ជីដីធ្លីត្រូវគោរពតាមគោលការណ៍អភិបាលកិច្ចល្អ តម្លាភាព វិមជ្ឈការ និងវិសហមជ្ឈការ និងសមធម៌យេនឌ័រ ដើម្បីបង្កើតបានជាវប្បធម៌នៃការចុះបញ្ជីដីធ្លី និងបង្កើនភាពជឿជាក់លើប្រព័ន្ធចុះបញ្ជីដីធ្លី ។ ការងារនេះត្រូវមានលក្ខណៈសាមញ្ញ ច្បាស់លាស់ ឆាប់រហ័ស ងាយទទួលបាន មានតម្លៃទាប ។ ត្រូវរៀបចំឱ្យមានប្រព័ន្ធព័ត៌មានដីធ្លី (Land Information System) ដើម្បីផ្តល់ព័ត៌មានជាក់លាក់ពីអចលនវត្ថុក្នុងតម្លៃសមស្រប ។

**<u>សកម្មភាពនៃអនុវិស័យរដ្ឋបាលដីធ្លី</u>**

១. បង្កើត និងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាក់ព័ន្ធ ដូចជាច្បាប់អស្សាមិករណ៍ (ការដកហូតកម្មសិទ្ធិ - Expropriation Law) ច្បាប់ស្តីពីសិទ្ធិបុព្វក្រៃ (រដ្ឋមានសិទ្ធិទិញមុនអ្នកដទៃ - Pre-emption Law) ច្បាប់ស្តីពីដីកសិកម្ម ការផ្ទេរដី (Land Transfer) ការបង្រួមក្បាលដី (Land Consolidation) ការបំបែកក្បាលដី (Land Sub-division) ពន្ធលើដីធ្លី (Land Taxation) ការវាយតម្លៃថ្លៃដី (Land Valuation) ទីផ្សារដី (Land Market) ធនាគារដី (Land Banking) និងការវាស់វែងដី (Land Survey)...។ ល ។ ព្រមទាំងធ្វើវិសោធនកម្មមាត្រាច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងច្បាប់ភូមិបាលច្បាប់សារពើពន្ធ... ស្របតាមការវិវឌ្ឍនៃសភាពការណ៍ប្រទេសជាតិ ។

២. បង្កើតបញ្ជីសារពើភ័ណ្ឌអចលនវត្ថុ (ដី និងអគារ) របស់រដ្ឋជាជំហានៗឱ្យបានច្បាស់លាស់ និងពេញលេញនៅក្នុងប្រព័ន្ធទិន្នន័យឯកភាពតែមួយ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងអចលនវត្ថុរបស់រដ្ឋ ។

៣. ដំណើរការចុះបញ្ជីដីធ្លីទូទាំងប្រទេសប្រកបដោយតម្លាភាព និងប្រសិទ្ធភាពសម្រាប់អចលនវត្ថុទាំងអស់ ទាំងដីរដ្ឋ (ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ) និងដីឯកជនរបស់បុគ្គលឯកជន ÷

៣.១ បន្តអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈដាច់ដោយដុំ ។

៣.២ ចុះបញ្ជីបន្ត និងធ្វើចរន្តការលើព័ត៌មានសុរិយោដីឱ្យបានឆាប់រហ័ស ដើម្បីបង្កើនចំណូលរបស់រដ្ឋ ។

៣.៣ ធ្វើលេខាចារិកនូវរាល់ហ៊ីប៉ូតែក ការបញ្ចាំ ការដាក់ធានា ការជួលរយៈពេលវែង សម្បទានដីសេដ្ឋកិច្ច ឬសេវភាព ដែលបានបង្កើតឡើងលើទ្រព្យជាអចលនវត្ថុ ។

៣.៤. ជំរុញការចុះបញ្ជីសហកម្មសិទ្ធិ ។

៣.៥. យកចិត្តទុកដាក់លើការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ។

៣.៦. ជំរុញការចុះបញ្ជីដីរដ្ឋ (ដីសាធារណៈ និងដីឯកជនរបស់រដ្ឋ) ។

៣.៧. បង្កើតប្រព័ន្ធព័ត៌មានដីធ្លី (LIS) ដែលអាចផ្តល់ព័ត៌មានជាក់លាក់ជូនអតិថិជន ។ ប្រព័ន្ធព័ត៌មានដីធ្លីជាមូលដ្ឋានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ (National Spatial Data Infrastructure) និងសម្រាប់បម្រើដល់ពហុគោលបំណង ។

៤. បង្កើតប្រព័ន្ធព័ត៌មានធរណីសាស្ត្រ និងធ្វើចំណាត់ថ្នាក់ប្រភេទដី តាមលក្ខណៈពីធម្មជាតិនៃដី (Soil Classification)

៥. ការបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ឱ្យមានការឯកភាពនៅទូទាំងប្រទេស ÷

៥.១. បង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រឯកភាពមួយ (GIS) ក្រោមការសម្របសម្រួលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ បង្កើតផ្នែកទទួលខុសត្រូវបោះពុម្ព និងចែកចាយផែនទីគោល ។

៥.២. បន្តរៀបចំបណ្តាញប្រថពីវិភាគ (Geodetic Network) នៅទូទាំងប្រទេសនិងរៀបចំបង្កើតបណ្តាញរយៈកំពស់ (Leveling Network) ។

៥.៣. រៀបចំបង្កើតស្ថានីយវាស់វែង ជីភីអេស អចិន្ត្រៃយ៍ (Permanent GPS Base Station) ។

៦. រៀបចំប្រព័ន្ធវាយតម្លៃថ្លៃដីដែលមានលក្ខណៈចូលរួម តម្លាភាព និងទទួលស្គាល់ជាផ្លូវការ ។ ការវាយតម្លៃថ្លៃដី ត្រូវផ្អែកលើគុណភាពអំណោយផលពីធម្មជាតិនៃដី និងរាប់បញ្ចូលអចលនវត្ថុទាំងអស់នៅលើដីផងដែរ (Land and Improvements) ដើម្បីបង្កើតជាមូលដ្ឋានមួយសម្រាប់ការលក់-ទិញ ការជួល ការវិនិយោគ ការឱ្យខ្ចីប្រាក់ ការយកពន្ធ (ពន្ធប្រចាំឆ្នាំ ពន្ធលើការផ្ទេរ លើការជួលលើប្រាក់ចំណេញ លើដីធ្លីមិនប្រើប្រាស់) ការកំណត់សេវាសុរិយោដី និងការទូទាត់សំណង...។ល ។

៦.១. ផ្តល់អាជ្ញាប័ណ្ណដល់អ្នកវាយតម្លៃថ្លៃអចលនវត្ថុ ។

៦.២. កសាង និងពង្រឹងសមត្ថភាពដល់អ្នកវាយតម្លៃថ្លៃអចលនវត្ថុ ។

៦.៣. បន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលធ្វើការបង្កបង្កើនផលជាលក្ខណៈគ្រួសារ ។ ទន្ទឹមនេះ ត្រូវផ្តួចផ្តើមសិក្សាការយកពន្ធប្រចាំឆ្នាំលើអចលនវត្ថុក្រៅពីដីកសិកម្មជាលក្ខណៈគ្រួសារ ។

៦.៤. រៀបចំផែនទីតម្លៃថ្លៃដី ។

៦.៥. ដំណើរការវាយតម្លៃថ្លៃអចលនវត្ថុនៅតំបន់ទីប្រជុំជន និងជនបទ និងតាមដានត្រួតពិនិត្យការវាយតម្លៃ ។

៧. លើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជនលើការងារវាស់វែងដីធ្លី ក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលសុរិយោដី ។

៨. បន្តដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការតាមរយៈគណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដីគ្រប់លំដាប់ថ្នាក់ (ថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមចល័ត) និងអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ជាពិសេសចំពោះករណីវិវាទពហុភាគី ។

៩. បង្កើតប្រព័ន្ធស្វ័យគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ផ្នែករដ្ឋបាលដីធ្លី ដោយផ្តើមពីចំណូលបានមកពីការចុះបញ្ជី និងពីសេវាសុរិយោដី ដើម្បីគាំទ្រនិងពន្លឿនដំណើរការចុះបញ្ជីដីនៅទូទាំងប្រទេស ។

## ៩.អនុវិស័យរៀបចំដែនដី (Land Management)

**គោលបំណងនៃការរៀបចំដែនដី** គឺធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌នៅទីប្រជុំជននិងជនបទ ព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដី ដោយដាក់បញ្ញត្តិលើការអភិវឌ្ឍដី (Land Development) ការប្តូរប្រភេទនៃការប្រើប្រាស់ដី (Land Conversion) លើការកែសំរួលក្បាលដី (Land Readjustment) លើការសាងសង់ លើការតាំងទីលំនៅជាថ្មី អនុលោមតាមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី គោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អ ។

ទន្ទឹមនេះ ការងាររៀបចំដែនដី ត្រូវធ្វើឱ្យស្របតាមគោលការណ៍សមធម៌ តម្លាភាព ការចូលរួមការព្រមព្រៀងគ្នា និងគោរពតាមឋានានុក្រមនៃការរៀបចំផែនការ បទបញ្ជា និងនីតិវិធីពាក់ព័ន្ធ ។

### សកម្មភាពនៃអនុវិស័យរៀបចំដែនដី

១. អភិវឌ្ឍគោលនយោបាយជាតិ និងក្របខ័ណ្ឌគតិយុត្ត ព្រមទាំងនីតិវិធីសមស្របសម្រាប់ការគ្រប់គ្រងអភិវឌ្ឍដី នៅទីប្រជុំជននិងជនបទ រួមទាំង ដីបំរើឱ្យផលិតកម្មកសិកម្ម ការសាងសង់ និងការតាំងទីលំនៅជាថ្មី ។

២. បង្កើតប្រព័ន្ធផែនការរៀបចំដែនដី (spatial planning system) ដែលចង្អុលបង្ហាញអំពីការរៀបចំតំបន់ ឬទីតាំងនីមួយៗ ដោយផ្អែកលើលក្ខណៈពិធម្មជាតិនៃដី និងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌ ។ ប្រព័ន្ធផែនការរៀបចំដែនដី (spatial planning system) ត្រូវបង្កើតតាមរយៈ :

២.១ ការកំណត់ខ្លឹមសារ និងឋានានុក្រមនៃផែនការ (រួមមានយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ទីក្រុង) ។

២.២ ការកំណត់សមត្ថកិច្ចកសាង និងអនុម័តផែនការ ។

២.៣ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រការអនុវត្ត ។

៣. រាល់ផែនការប្រើប្រាស់ដីសម្រាប់តំបន់អាទិភាព ដូចជាផែនការអភិវឌ្ឍតំបន់ឆ្នេរ តំបន់ទេសចរណ៍ តំបន់វិនិយោគ តំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច តំបន់ទីប្រជុំជន និងច្រករបៀងសំខាន់ៗ ត្រូវគោរពតាមគោលការណ៍ តម្លាភាព ការចូលរួម ការព្រមព្រៀងគ្នា សមធម៌ និងធានានិរន្តរភាព ។

៤. គ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ដី និងធនធានធម្មជាតិ ដោយប្រើប្រាស់ឧបករណ៍ ÷

៤.១.ផែនការរៀបចំដែនដី ( Spatial Planning ) ។

៤.២.ផែនការប្រើប្រាស់ដី ( Land Use Planning ) ។

៤.៣.ផែនការអភិវឌ្ឍន៍សម្រាប់ទីប្រជុំជន និងជនបទ (Urban and Rural Development PLan)

៤.៤. ការកំណត់តំបន់ប្រើប្រាស់ដី (Zoning) ។

៤.៥. ការត្រួតពិនិត្យប្លង់ទីតាំងសំណង់ ដោយរួមបញ្ចូលទាំងនីតិវិធីរៀបចំដីមិនទាន់អភិវឌ្ឍន៍ (Sub-division Control) ។

៤.៦. ក្រមនគរូនីយកម្ម (Urban Code) ។

៤.៧. ក្រមសំណង់ (Construction Code) ស្តង់ដារសំណង់ និងលិខិតបទដ្ឋានបច្ចេកទេសសំណង់ ។

៤.៨. ការត្រួតពិនិត្យការអភិវឌ្ឍ ( Development Control) ។

៥. ជម្រុញការធ្វើផែនការរៀបចំដែនដីថ្នាក់ជាតិ ថ្នាក់ខេត្ត និងផែនការប្រើប្រាស់ដីថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ហើយដែលក្នុងនោះ ត្រូវរៀបចំ (i).ផែនការរៀបចំដែនដីថ្នាក់ជាតិ (ii). ផែនការរៀបចំដែនដីថ្នាក់ខេត្ត (iii). ប្លង់គោលប្រើប្រាស់ដីធ្លី និង ផែនការប្រើប្រាស់ដី ថ្នាក់រាជធានី (iv).ប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង (v).ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក (vi).ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និង (vii).ផែនការ ប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ ។

៦. ពន្លឿនការរៀបចំគោលការណ៍ណែនាំលើការប្រើប្រាស់ដីនៅមូលដ្ឋាន ដើម្បីគាំទ្រដល់វិមជ្ឈការ និងវិសហមជ្ឈការនៃការរៀបចំដែនដីក្រោមការគាំទ្របច្ចេកទេសពីថ្នាក់ជាតិដល់អាជ្ញាធរមូលដ្ឋាន ។

៧. ជំរុញវិមជ្ឈការនៃការរៀបចំដែនដី ។ ស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋ ត្រូវផ្តល់បញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យក្រសួងនេះធ្វើរបាយការណ៍សរុបជូនរាជរដ្ឋាភិបាល អំពីស្ថានភាពនៃការប្រើប្រាស់ដី។ សាធារណៈជនអាចទទួលបានព័ត៌មាននេះ ពីស្ថាប័នពាក់ព័ន្ធ។ ស្ថាប័ន

ដែលទទួលបានអាណត្តិកាន់កាប់ដីរដ្ឋ រួមជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវទទួលខុសត្រូវក្នុងកិច្ចការពារ និងធានានូវគណនេយ្យភាពចំពោះការគ្រប់គ្រងដីសាធារណៈ និងដីឯកជនរបស់រដ្ឋ ។

៨. ផ្តួចផ្តើមការកែសំរួលក្បាលដី ដើម្បីបង្កើនផលិតភាពសេដ្ឋកិច្ច និងការអភិវឌ្ឍមូលដ្ឋាន រួមទាំងការអភិវឌ្ឍភូមិ (Village Development) ។

## គ.អនុវិស័យបែងចែកដីធ្លី (Land Distribution)

**គោលបំណងនៃការបែងចែកដីធ្លី** គឺផ្តល់ទិសដៅច្បាស់លាស់ដើម្បីធ្វើការបែងចែក និងការប្រើប្រាស់ដីរដ្ឋ សម្រាប់គោលបំណងឯកជន និងសាធារណៈ ប្រកបដោយតម្លាភាព និងសមធម៌ ដោយឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋក្រីក្រ យុទ្ធជនពិការ និងគ្រួសារយុទ្ធជនពលី ដែលគ្មានដី និងខ្វះដីតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច ។

ការបែងចែកដីធ្លី ត្រូវធានាឱ្យបាននូវសមធម៌ ស្ថេរភាពសង្គម សន្តិសុខស្បៀង និងការសំរួលដល់ការវិនិយោគ ដោយផ្អែកលើប្រភេទ និងគុណភាពអំណោយផលពីធម្មជាតិនៃដី ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព ទប់ស្កាត់ការប្រមូលដីទុក និងជំរុញការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងផលិតភាព ។

**សកម្មភាពនៃការបែងចែកដីធ្លី ៖**

១. ជំរុញការប្រមូល និងចងក្រងបញ្ជីសារពើភ័ណ្ឌដីរដ្ឋ សម្រាប់បំរុងទុកក្នុងគោលដៅបែងចែក និងប្រើប្រាស់ដីពេលបច្ចុប្បន្ន និងទៅអនាគតប្រកបដោយសមធម៌ តម្លាភាព និងគណនេយ្យភាព ។

២. បង្កើត និងអនុវត្តយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃផែនការបែងចែកដីធ្លីរយៈពេលមធ្យម និងវែង ដើម្បីបែងចែក និងប្រើប្រាស់ដីសម្រាប់គោលដៅសង្គមកិច្ច និងសេដ្ឋកិច្ច ស្របតាមផែនការថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ដោយធានាតម្លាភាព និងប្រសិទ្ធភាព ចៀសវាងការជះឥទ្ធិពលអវិជ្ជមានដល់សង្គម និងបរិស្ថាន ។

៣. ជម្រុញការបែងចែកដីធ្លីសម្រាប់គោលដៅសង្គមកិច្ចឱ្យបានទាន់ពេលវេលា ដើម្បីរួមចំណែកដោះស្រាយបញ្ហាសង្គម និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ។

៤. អនុវត្តភាពជាដៃគូរវាងម្ចាស់ចំការខ្នាតតូច ខ្នាតធំ និងសាជីវកម្មនៅក្នុងការងារកសិផលិតកម្ម និងរវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច សំដៅបង្កើតការងារធ្វើ និងបង្កើតទីផ្សារ សម្រាប់អ្នករស់នៅក្នុងមូលដ្ឋាន ។

រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមអនុវត្ត គោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ តាមរយៈការបំពេញតួនាទី និងភារកិច្ច តាមវិស័យជំនាញរៀងៗខ្លួន ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលដូចបានសង្ខេបខាងលើនេះ នឹងត្រូវបន្តរៀបចំ "គោលនយោបាយដីធ្លីទូលំទូលាយ" (Comprehensive Land Policy) នៅពេលខាងមុខនេះ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ : ១១២ ដនសង/ប្រក

# ប្រកាស

## ស្តីពី

## គោលការណ៍ណែនាំ និង នីតិវិធី

## របស់គណៈកម្មការសុរិយោដី

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យ លេខ ៤៨ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាស លេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង តួនាទីភារកិច្ចរបស់បណ្ណាការិយាល័យក្រោមឱវាទ

- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## ស ំ រេ ច

## ១. និយមន័យ

**ប្រការ ១ :-**

ប្រកាសនេះកំណត់នីតិវិធីនៃការដាក់ពាក្យប្តឹង ការសម្រុះសម្រួល និង ការសំរេចលើបញ្ហាវិវាទដីធ្លីដែលបានប្តឹងទៅគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ។

**ប្រការ ២ :-**

គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ (គសសខ ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៤ និង មាត្រា ៥ នៃអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ( គសខក ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និង មាត្រា ១២ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ (គសជ ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១៧ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

" គណៈកម្មការរដ្ឋបាល " គឺជាគណៈកម្មការដែលបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ ។ ភារកិច្ចមួយនៃគណៈកម្មការនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងអំឡុងពេលនៃការចុះបញ្ជី

មានលក្ខណៈជាប្រព័ន្ធស្របតាមមាត្រា ៣ នៃអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ។

" ដីដែលមិនទាន់បានចុះបញ្ជីសុរិយោដី " គឺជាក្បាលដីទាំងឡាយដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ឬ មានលក្ខណៈដាច់ដោយដុំស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ។

"បុគ្គល" រួមមាន រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

" ដើមបណ្តឹង" គឺជាជនដែលធ្វើការប្តឹងទាមទារអោយមានការដោះស្រាយវិវាទដោយអនុលោមតាមប្រកាសនេះ ។

" ចុងបណ្តឹង" គឺបុគ្គលដែលជំទាស់ទៅនឹងដើមបណ្តឹង ។

## ២. ការចាប់ផ្តើមដំណើរការដោះស្រាយវិវាទ

**ប្រការ ៣ :-**

បុគ្គលទាំងឡាយដែលទាមទារកម្មសិទ្ធិ ( ឬ សិទ្ធិកម្មសិទ្ធិ ) ឬភោគៈ ( ឬ សិទ្ធិភោគៈ) លើដីមិនទាន់បានចុះបញ្ជីសុរិយោដី ហើយដីនោះមានបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀតបានទាមទារមួយផ្នែកឬទាំងមូលដែរ អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការ សុរិយោដីថ្នាក់ស្រុក ឬ ខណ្ឌ ដែលដីនោះស្ថិតនៅ ។

**ប្រការ ៤ :-**

បុគ្គលដែលប្តឹងទាមទារធ្វើជាកម្មសិទ្ធិករ ឬ ភោគីនៃដីត្រូវដាក់ពាក្យបណ្តឹង លើកលែងតែក្នុងករណីដែលជននោះជាអសមត្ថជន ។ ក្នុងករណីនេះ អ្នកតំណាងស្របច្បាប់របស់ជននោះ អាចដាក់ពាក្យបណ្តឹងក្នុងនាមជននោះបាន ។

**ប្រការ ៥ :-**

បណ្តឹងទាមទារ ត្រូវធ្វើតាមទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមាននៅក្នុងឧបសម្ព័ន្ធទី ១នៃប្រកាសនេះ ។ ដើមបណ្តឹង អាចទទួលយកទម្រង់បែបបទនៃពាក្យបណ្តឹងនេះពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចធ្វើទម្រង់បែបបទនៃពាក្យបណ្តឹងរបស់ខ្លួនបាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែប បទនៃពាក្យបណ្តឹង ដូចមាន កំណត់នៅក្នុងឧបសម្ព័ន្ធទី ១ ។

ពាក្យបណ្តឹង ត្រូវបញ្ចូលពត៌មានស្តីពីដើមបណ្តឹងដូចតទៅ : ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ភេទ ឈ្មោះសហព័ទ្ធ (ប្តី-ប្រពន្ធ) កូន ឃុំ ស្រុក ខេត្ត មុខរបរ អាស័យដ្ឋានបច្ចុប្បន្ន ទីតាំងដីវិវាទ សេចក្តីពណ៌នាពីវិវាទដោយមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន ឯកសារពាក់ព័ន្ធនានា ឈ្មោះ និង អាស័យដ្ឋានរបស់ចុងបណ្តឹង ។ ដើមបណ្តឹងត្រូវផ្តល់រាល់ពត៌មានដូចបានតំរូវនៅក្នុងទម្រង់បែបបទបណ្តឹងហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខា ឬ ផ្តិតមេដៃលើពាក្យបណ្តឹងនោះ ។

ដើមបណ្តឹងត្រូវ ផ្តល់បែបបទបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន ០៤ ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំឯកសាររបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹងនោះដើមបណ្តឹងត្រូវផ្តល់ឯកសារពាក្យបណ្តឹងមួយច្បាប់ៗដល់ចុងបណ្តឹងម្នាក់ៗដែលមានឈ្មោះ ។

**ប្រការ ៦ :-**

នៅពេលទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបើកសំណុំរឿង ហើយត្រូវកំណត់លេខដើម្បី ជាការសំគាល់សំណុំរឿងវិវាទតាម ខេត្ត និងស្រុក ដែលដីវិវាទនោះស្ថិតនៅ ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវចុះលេខសំគាល់សំណុំរឿងវិវាទ ចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនៃពាក្យបណ្តឹងច្បាប់ដើម ហើយផ្តល់ឯកសារដែលបានចុះបញ្ជីមួយច្បាប់ទៅដើមបណ្តឹងវិញ ។ ឯកសារនេះគឺជាភស្តុតាងនៃការដាក់ ពាក្យបណ្តឹងរបស់ដើមបណ្តឹង ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវថតចម្លងឯកសារនានាដែលបានភ្ជាប់មកជាមួយពាក្យបណ្តឹងហើយត្រូវបញ្ចូលឯកសារថតចម្លងទាំងនេះទៅក្នុងសំណុំរឿងផ្លូវការ ។ មន្ត្រីទទួលពាក្យបណ្តឹង ត្រូវបង្វិលឯកសារច្បាប់ដើមទៅអោយដើមបណ្តឹងវិញ ។

**ប្រការ ៧ :-**

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវបិទផ្សាយពាក្យបណ្តឹងនោះរួមជាមួយនិងសេចក្តីជូនដំណឹងអំពីបណ្តឹងរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដែលបញ្ជាក់ថាពាក្យបណ្តឹងនោះបានចុះបញ្ជីហើយ ។ សេចក្តីជូនដំណឹងពីបណ្តឹងត្រូវធ្វើឡើងតាមទម្រង់បែបបទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ២ ។ សេចក្តីជូនដំណឹងនោះ ត្រូវអញ្ជើញបុគ្គលគ្រប់រូបដែលមានផលប្រយោជន៍នៅក្នុងដីវិវាទអោយឆ្លើយតបចំពោះពាក្យបណ្តឹងក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយសេចក្តីជូនដំណឹង និង(ea)ពាក្យបណ្តឹងនោះ ។

ពាក្យបណ្តឹង និង សេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងមួយច្បាប់ត្រូវបិទផ្សាយនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ហើយសាធារណជនអាចចូលមើលបានដោយសេរីក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា ។ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបមើលសេចក្តីជូនដំណឹងដែលបាន បិទផ្សាយនោះដើម្បីអោយដឹងថា តើខ្លួនមានផលប្រយោជន៍នៅក្នុងវិវាទនោះឬទេ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបិទសេចក្តីជូនដំណឹងមួយច្បាប់នៅលើទីតាំងដីដែលមានវិវាទ ។

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងអំពីការប្តឹងទាមទារនោះ តាមរយៈការផ្តល់ដល់ចុងបណ្តឹង នូវពាក្យបណ្តឹងដែលបំពេញរួចម្នាក់មួយច្បាប់ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបចំពោះបណ្តឹងទាមទារនោះ ហើយត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិចូលរួមប្រជុំជាមួយគណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ដើម្បីពិគ្រោះយោបល់អំពីបណ្តឹង ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់អោយចុងបណ្តឹងនូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល។

**ប្រការ ៨ :-**

ចុងបណ្តឹងដែលមានឈ្មោះក្នុងពាក្យបណ្តឹង អាចឆ្លើយតបចំពោះបណ្តឹងតាមរយៈការដាក់សំណុំបែបបទឆ្លើយតបចំពោះបណ្តឹងដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី ៤ ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានទទួលឯកសារចម្លងនៃពាក្យបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ចុងបណ្តឹងនូវឯកសារថតចម្លងមួយច្បាប់នៃពាក្យបណ្តឹង និង សេចក្តីសង្ខេបអំពីរបៀប សម្រុះសម្រួល។

រាល់បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍នៅក្នុងដីវិវាទនេះ ត្រូវដាក់បែបបទឆ្លើយតបចំពោះបណ្តឹងក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីពេលដែលសេចក្តីជូនដំណឹងអំពីបណ្តឹងត្រូវបានបិទផ្សាយនៅការិយាល័យគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង នៅលើទីតាំងដីវិវាទដោយគិតតាមកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងមួយណាដែលបិទក្រោយគេ ។

ចុងបណ្តឹង អាចទទួលបានទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចដាក់ទម្រង់បែបបទរបស់ខ្លួនផ្ទាល់បាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទដូចមាន កំណត់ក្នុងឧបសម្ព័ន្ធទី ៤ ។

ចុងបណ្តឹងនោះ ត្រូវផ្តល់ទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន០៤ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំរឿងរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹង ឬ ដើមបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹង នោះចុងបណ្តឹងត្រូវផ្តល់ឯកសារចម្លងឆ្លើយតបចំពោះបណ្តឹងដល់ចុងបណ្តឹង និង/ឬ ដើមបណ្តឹង ដែលមានឈ្មោះ ម្នាក់ៗមួយច្បាប់ ។

ចុងបណ្តឹង ត្រូវបង្ហាញឯកសារពាក់ព័ន្ធនៅពេលដាក់ពាក្យឆ្លើយតបចំពោះបណ្តឹង ។ មន្ត្រីទទួលពាក្យត្រូវថតចម្លងឯកសារដែលបានដាក់ភ្ជាប់មកជាមួយនោះ រួចហើយបង្វិលឯកសារច្បាប់ដើមទាំងនោះទៅអោយចុងបណ្តឹងវិញ ។

ពាក្យឆ្លើយតប និង ឯកសារដែលបានភ្ជាប់មកជាមួយនោះ ត្រូវបញ្ចូលទៅក្នុងសំណុំរឿងវិវាទផ្លូវការ ។

**ប្រការ ៩ :-**

គ្មានករណីណាមួយដែលដើមបណ្តឹង ឬ ចុងបណ្តឹងណាម្នាក់ត្រូវបានគេសុំ ឬតម្រូវអោយបង់ថ្លៃដាក់ពាក្យបណ្តឹង ឬ ពាក្យឆ្លើយតបឡើយ ។

## ៣ . ការស៊ើបអង្កេត

**ប្រការ ១០ :-**

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីសុរិយោដីចុះទៅធ្វើការស៊ើបអង្កេតបណ្តឹង ។ អ្នកស៊ើបអង្កេតត្រូវចុះទៅជួបភាគីទាំងអស់ កត់ត្រាសេចក្តីអះអាងរបស់ភាគី និងប្រមូលរាល់ពត៌មានទាក់ទងផ្សេងៗ និង ភស្តុតាងផ្សេងៗទាក់ទងនឹងវិវាទនោះ រួមទាំងពត៌មានដែលចាំបាច់ដើម្បីកំណត់ថា តើភាគីពាក់ព័ន្ធទាំងអស់ក្នុងវិវាទដីធ្លីនេះមានឈ្មោះនៅក្នុងសំណុំរឿងវិវាទដែលបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ហើយឬនៅ ថាជាភាគីនៃវិវាទឬ អត់ ។ ការស៊ើបអង្កេតត្រូវចាប់ផ្តើមអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបានបន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ បានទទួលពាក្យបណ្តឹង ។

**ប្រការ ១១ :-**

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវវាស់វែង និងកំណត់ព្រំដីដែលមានវិវាទ ស្របតាមនីតិវិធីដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។ ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ មិនអាចបំពេញការ...

ទទួលខុសត្រូវនេះបានដោយសារតែខ្លួនពុំមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ នោះអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល សុរិយោដីខេត្ត ក្រុង ។

**ប្រការ ១២ :-**

អ្នកស៊ើបអង្កេតមានសិទ្ធិជួបបុគ្គលណាម្នាក់ ឬ មានសិទ្ធិមើលឯកសារដែលកំណត់ថាចាំបាច់សំរាប់ការស៊ើបអង្កេតឱ្យបានពេញលេញ ។

បុគ្គលទាំងឡាយរួមទាំងសាក្សីរបស់ភាគី និង សាក្សីឯទៀតត្រូវជួបជាមួយអ្នកស៊ើបអង្កេត ប្រសិនបើខ្លួនត្រូវបានស្នើសុំដោយអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតត្រូវកំណត់ការប្រជុំតាមពេលវេលា និង ទីកន្លែងដែលងាយស្រួលចំពោះអ្នកពាក់ព័ន្ធ ទាំងឡាយ ។

ឯកសារច្បាប់ដើមទាំងឡាយត្រូវបង្វិលទៅអោយអ្នកដែលផ្តល់ឯកសារនោះវិញ ហើយច្បាប់ថតចម្លងនៃឯកសារនោះត្រូវរក្សាទុកនៅក្នុងកំណត់ហេតុផ្លូវការនៃវិវាទ ។

**ប្រការ ១៣ :-**

ភាគីវិវាទនីមួយៗ ត្រូវមានវត្តមានក្នុងពេលធ្វើការស៊ើបអង្កេតដល់ទីកន្លែង និងត្រូវប៉ាន់ស្មានសោហ៊ុយដែលទាក់ទងទៅនឹងការស៊ើបអង្កេតម្តងទៀតក្នុងករណីដែលមានភាគីណាមួយអវត្តមាន ។ បើអវត្តមានរបស់ភាគីមួយបង្កឡើងដោយសារទង្វើមិនសមរម្យរបស់ភាគីឯទៀត នោះភាគីដែលមានកំហុសត្រូវចេញសោហ៊ុយសំរាប់ថ្លៃការស៊ើបអង្កេតជាថ្មីនោះ។

**ប្រការ ១៤ :-**

ភាគីវិវាទ អាចផ្តល់ភស្តុតាង និងសាក្សីបាន ហើយរាល់ភស្តុតាង និងចម្លើយរបស់សាក្សីទាំងនោះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

អ្នកស៊ើបអង្កេត ត្រូវទទួលយក និង បញ្ចូលជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនូវរាល់ភស្តុតាងដែលត្រូវបានផ្តល់ដោយភាគី ឬ ដែលត្រូវបានប្រមូលក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ។ ភស្តុតាងទាំងនោះមានជាអាទិ៍ :

- ផែនទី ឬ កំណត់ហេតុអង្កេតវាស់វែង
- ឯកសារសំគាល់ការកាន់កាប់ដី
- រូបថត របស់ភាគីកាន់កាប់ដី

- សំបុត្រស្នាមផ្សេងៗដែលបានធ្វើដោយមានចុះអាស័យដ្ឋាននៃដីនោះ សំបុត្រកំណើត ឬ ប័ណ្ណគ្រួសារ ដែលបង្ហាញពីវត្តមានយូរអង្វែងនៅលើដីនោះ ឬសៀវភៅសម្រង់ស្ថិតិរបស់ប្រធានភូមិ
- ចម្លើយរបស់អ្នកជិតខាងថា តើនរណាដែលបានរស់នៅលើដីនោះ
- បង្កាន់ដៃទទួលប្រាក់ ឬ ឯកសារផ្សេងៗទាក់ទងទៅនឹងការទិញដី ឬ ការផ្ទេរសិទ្ធិនៃដីនោះ ។

**ប្រការ ១៥ :-**

អ្នកស៊ើបអង្កេត ត្រូវសម្ភាសន៍សាក្សីទាំងឡាយដែលផ្តល់ដោយភាគីវិវាទ ឬ ដែលអ្នកស៊ើបអង្កេតចាត់ទុកថាចាំបាច់ដើម្បីបញ្ជាក់អង្គហេតុនៃវិវាទ ។ សាក្សីនីមួយៗត្រូវធ្វើសម្បថ ថានឹងនិយាយតែការពិតហើយរាយការណ៍រាល់ព្រឹត្តិការណ៍ និង អង្គហេតុទាំងឡាយដែលសាក្សីយល់ និងជឿថាត្រឹមត្រូវ ។

អ្នកស៊ើបអង្កេត ត្រូវពិនិត្យសាក្សីនីមួយៗដើម្បីកំណត់អំពីភាពគួរអោយជឿបាននៅក្នុងចម្លើយរបស់សាក្សី តើសាក្សីដឹងកំរិតណា ការដឹងរបស់សាក្សីផ្អែកលើព្រឹត្តិការណ៍ទាំងឡាយដែលបានសង្កេតឃើញដោយខ្លួនឯងផ្ទាល់ ឬដោយគ្រាន់តែបានឮពីអ្នកណាម្នាក់ផ្សេងទៀត ។ ចម្លើយសាក្សី និង ការសម្ភាសន៍សាក្សីត្រូវទុកជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

**ប្រការ ១៦ :-**

អ្នកស៊ើបអង្កេត ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការស៊ើបអង្កេតដោយអនុលោមតាមទំរង់នៃស្តង់ដារដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥។ លទ្ធផលទាំងនេះត្រូវរួមបញ្ចូលនូវ ព្រំដីវិវាទ ផែនទី ឬ គំនូសតាងពាក់ព័ន្ធ សេចក្តីសង្ខេបអំពីចម្លើយរបស់សាក្សី និងចម្លើយលាយលក្ខណ៍អក្សរ សេចក្តីសង្ខេបនៃរាល់ឯកសារពាក់ព័ន្ធទៅនឹងដីវិវាទដែលមានការអះអាងដោយអ្នកស៊ើបអង្កេត ឬ ដែលបានទទួលពីភាគីវិវាទ។

## ៤. ការកំណត់អំពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ក្នុងការសម្រុះសម្រួលវិវាទ

**ប្រការ ១៧ :-**

បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកំណត់ថាតើគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសមត្ថកិច្ចធ្វើការសម្រុះសម្រួលវិវាទនោះដែរឬទេ ។

វិវាទទាំងឡាយត្រូវ សម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ លើកលែងតែប្រធានគណៈកម្ម-

ការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាវិវាទនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដោយសំអាងលើហេតុផលនានាដូចមានចែងនៅក្នុងប្រការ ១៨ នៃប្រកាសនេះ ឬ ដោយវិវាទនោះកើតឡើងដោយសារភាគីមួយ ឬច្រើនប្តឹងផ្អែកលើមូលដ្ឋានមិនច្បាស់លាស់ដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ ។

**ប្រការ ១៨ :-**

ប្រសិនបើវិវាទមិនអាចដោះស្រាយបានដោយសមធមិនៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដាក់សំណុំរឿងវិវាទនោះដោយផ្ទាល់ជូនទៅគណៈកម្មសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬ តាមសំណើរបស់ភាគីវិវាទទាំងសងខាងដូចមានចែងនៅក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រសិនបើមានភាគីតែម្ខាង ស្នើអោយបញ្ជូនករណីវិវាទនោះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង វិវាទនោះត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងលើកលែងតែប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ យល់ឃើញថាសំណើនោះមិនសមហេតុផល។ ហេតុផលនៃការបដិសេធសំណើនោះរួមមានការកំណត់របស់ប្រធានគណៈកម្ម-ការដែលយល់ថាសំណើនោះធ្វើឡើងគ្រាន់តែដើម្បីឱ្យមានការយឺតយ៉ាវដល់ការដោះស្រាយវិវាទ ឬ បង្កអោយមានការលំបាកដល់ភាគីម្ខាងទៀត និងអាច មានហេតុផលផ្សេងទៀត ។

ប្រសិនបើប្រធានគណៈកម្មការ បដិសេធមិនបញ្ជូនវិវាទនោះដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមសំណើរបស់ភាគីម្ខាង ប្រធានគណៈកម្មការត្រូវពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធសំណើនោះ ហើយការពន្យល់នេះត្រូវតែជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនោះ ។ ការសម្រុះសម្រួលដែលតម្រូវឱ្យមានការបញ្ជូនករណីវិវាទ ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង រួមមាន :

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
- ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីមានវិវាទពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការថ្នាក់ស្រុក ខណ្ឌ
- វិវាទពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

ក្នុងករណីណាក៏ដោយ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មិនមានសិទ្ធិអំណាចសម្រុះសម្រួលវិវាទដែលទាក់ទងទៅ នឹងដីសាធារណៈរបស់រដ្ឋឡើយ ។

**ប្រការ ១៩ :-**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវច្រានចោលបណ្តឹងទាមទារណាដែលមិនត្រឹមត្រូវ ឬ គ្មានមូលដ្ឋាន ឬ ដែលធ្វើឡើងដើម្បីយាយី ឬ បំភិតបំភ័យភាគីម្ខាង ។ ការច្រានចោលបណ្តឹងមិនមែនជាប្រការគួរលើកទឹកចិត្តអោយធ្វើនោះទេលើកលែងតែក្នុងករណីចាំបាច់ដើម្បីរារាំងភាពអយុត្តិធម៌តែប៉ុណ្ណោះ។

បណ្តឹងមិនត្រឹមត្រូវ គឺបណ្តឹងដែលខ្វះមូលដ្ឋានអង្គហេតុសមហេតុផលឬទាក់ទងទៅនឹងវិវាទដែលស្ថិតនៅក្រៅវង្វង់សមត្ថកិច្ចនៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។ លក្ខខណ្ឌនៃបណ្តឹងដែលមិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ មានជាអាទិ៍ :

- សាក្សី ឬ ភស្តុតាងរបស់ភាគីម្ខាង បង្ហាញថាមានលក្ខណៈក្លែងបន្លំ ឬ ខុស ដូចជា សាក្សីរបស់ភាគីម្ខាងដកពាក្យចម្លើយរបស់ខ្លួនវិញ ឬ ផ្តល់ចម្លើយដែលប្រឆាំងដោយត្រង់ទៅនឹងការទាមទាររបស់ភាគីម្ខាង
- ការស៊ើបអង្កេត និងពត៌មានផ្សេងទៀតដែលភាគីស្នើឡើងមិនបង្ហាញភស្តុតាងណាមួយដែលគាំទ្រដល់ការទាមទាររបស់ភាគីដូចមានក្នុងពាក្យបណ្តឹង ។

ក្នុងករណីបណ្តឹងត្រូវបានច្រានចោល ភាគីអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីណាមួយដែលធ្វើការទាមទារដោយគ្មានមូលដ្ឋាន ឬ មិនមានលក្ខណៈច្បាប់ ត្រូវចេញសោហ៊ុយថ្លៃដំណើរការវិវាទដែលបានចំណាយមកដល់ពេលនោះ និង ត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដោយអនុលោមតាមច្បាប់ភូមិបាល ២០០១ និង ច្បាប់ផ្សេងៗទៀត ។ ត្រូវរារាំងមិនអោយភាគីដែលដាក់ពាក្យបណ្តឹងមិនត្រឹមត្រូវ ប្តឹងទាមទារជាថ្មីម្តងទៀត ។

ភាគីណាដែលបង្ហាញភស្តុតាងក្លែងបន្លំ ត្រូវដកចេញពីដំណើរការវិវាទ ហើយភស្តុតាងត្រូវដកចេញពីកំណត់ហេតុផ្លូវការនៃវិវាទ និងត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដូចមានចែងនៅក្នុងច្បាប់ភូមិបាល ២០០១ និងច្បាប់ផ្សេងៗទៀត។ ភាគីណាដែលត្រូវបានរកឃើញថា បានធ្វើការក្លែងបន្លំភស្តុតាង ឬឯកសារអាចទទួលទោសព្រហ្មទណ្ឌដូចមានចែងនៅក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ និង ច្បាប់ផ្សេងៗទៀត។

## ៥. ការសម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

**ប្រការ ២០ :-**

បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត មិនតិចជាង ៣០ ថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងត្រូវបានបិទផ្សាយដូចមានចែងក្នុងប្រការ ៧នៃប្រកាសនេះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំប្រជុំគណៈកម្មការសុរិយោដី

ថ្នាក់ស្រុក ខណ្ឌដើម្បីសំរេចលើដំណើរការសម្រុះសម្រួលវិវាទ ។ កិច្ចប្រជុំត្រូវធ្វើឡើងនៅលើដីវិវាទ ឬកន្លែងដែលនៅជិតដីវិវាទតាមដែលអាចធ្វើទៅបាន ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និង/ឬ ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញភាគីវិវាទមកចូលរួមការប្រជុំរដ្ឋបាលយ៉ាងហោច ៥ ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃប្រជុំនេះ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ភាគីទាំងអស់នូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល និងត្រូវពន្យល់អំពីពតិមាននេះដល់ភាគីទាំងអស់ ។

នៅពេលប្រជុំរដ្ឋបាលនេះ ភាគីត្រូវជូនដំណឹងដល់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អំពីការស្នើសុំរបស់ខ្លួនឱ្យបញ្ជូនសំណុំរឿងវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍នានា និង ធ្វើការព្រមព្រៀងជាឯកច្ឆ័ន្ទលើសមាសភាពអ្នកសម្រុះសម្រួលដូចមានចែងក្នុង ប្រការ ២២ នៃប្រកាសនេះ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលវិវាទ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយ និង កំណត់ពេលវេលាសំរាប់ការសម្រុះសម្រួលវិវាទ។

**ប្រការ ២១ :-**

ប្រសិនបើ មានសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ។

ប្រសិនបើ មានវិវាទអំពីផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ វិវាទនោះត្រូវដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីអាចប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសំរេចថាតើ សមាជិករូបនោះមានវិវាទអំពីផលប្រយោជន៍ដែលរារាំងមិនឱ្យសមាជិករូបនោះចូលរួមនៅក្នុងការដោះស្រាយវិវាទ ឬទេ ។ វិវាទអំពីផលប្រយោជន៍ដែលចោទប្រកាន់ចំពោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដោះស្រាយតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ ១៨ នៃប្រកាសនេះ ។

**ប្រការ ២២ :-**

ភាគីវិវាទ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជ្ញាធរ និងសមាជិកអចិន្ត្រៃយ៍នៃគណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នៅក្នុងលក្ខខណ្ឌតែមួយគត់គឺភាគីទាំងអស់ព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក្នុងការប្រើអ្នកសម្រុះសម្រួលជាក់លាក់នោះ ។

ក្នុងករណីភាគីវិវាទមិនអាចព្រមព្រៀងគ្នាលើសមាសភាពអ្នកសម្រុះសម្រួលជាក់លាក់ណាមួយមកពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់តាំងអ្នកសម្រុះសម្រួលចេញពីសមាជិកអាជ្ញាធរ និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣ រូប ដែលមានម្នាក់ជាប្រធាន ត្រូវសម្រុះសម្រួលវិវាទ ។

សមាជិកទាំងឡាយនៃក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវមានសមាជិកម្នាក់ដែលបានទទួលការបណ្តុះបណ្តាល ឬមានបទពិសោធន៍នៅក្នុងការសម្រុះសម្រួលវិវាទ និង មានសមាជិកម្នាក់ជាអ្នកដឹងអំពីស្ថានភាព និងសភាពការណ៍នៅក្នុង មូលដ្ឋាន ។

ប្រសិនបើ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាគ្មានសមាជិកណាម្នាក់នៃសមាជិកក្រុមអ្នកសម្រុះសម្រួលមានបទពិសោធន៍ ឬ ការបណ្តុះបណ្តាលនៅក្នុងដំណើរការសម្រុះសម្រួលទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អាចស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ចាត់តាំងអ្នកសម្រុះសម្រួលដែលបានទទួលការបណ្តុះបណ្តាលអោយចូលរួមនៅក្នុងក្រុមអ្នកសម្រុះសម្រួល ។

**ប្រការ ២៣ :-**

ភាគីវិវាទអាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ឱ្យជួយខ្លួននៅគ្រប់ថ្នាក់នៃដំណើរការសម្រុះសម្រួល ។ បុគ្គលរូបនេះហៅថាអ្នកជំនួយការភាគី ឬអ្នកជំនួយការមិនអាចតំណាងឱ្យភាគីបានទេ ប៉ុន្តែអាចផ្តល់យោបល់ដល់ភាគីវិវាទបាន ។ អ្នកជំនួយការភាគី អាចបំភ្លឺយោបល់របស់ភាគី និងអាចចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយជាមួយអ្នក

សម្រុះសម្រួល និងជាមួយភាគីបាន ប៉ុន្តែមិនអាចនិយាយជំនួសភាគីទៅកាន់អ្នកសម្រុះសម្រួល ឬ ភាគីផ្សេងទៀតបានទេ ឬ មិនអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបានឡើយ ។

ប្រសិនបើអ្នកជំនួយការភាគីនោះបំពានវិធាននៃដំណើរការវិវាទ ក្រុមអ្នកសម្រុះសម្រួលត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកជំនួយការនោះ ។ ប្រសិនបើអ្នកជំនួយការនោះបន្តបំពានទៀតក្រុមអ្នកសម្រុះសម្រួលត្រូវហាមឃាត់អ្នកជំនួយការនោះមិនឱ្យចូលរួមនៅក្នុងដំណើរការវិវាទតទៅទៀតឡើយ ។ ប្រសិនបើអ្នកជំនួយការត្រូវបានរារាំង ដំណើរការសម្រុះសម្រួលត្រូវផ្អាកមួយរយៈរហូតដល់ភាគីវិវាទជ្រើសរើសអ្នកជំនួយការថ្មីបាន ឬ ព្រមព្រៀងបន្តដំណើរការដោយពុំចាំបាច់មានអ្នកជំនួយការ ។ អ្នកសម្រុះសម្រួលត្រូវផ្តល់អោយភាគីម្ខាង១នូវឱកាសគ្រប់គ្រាន់ដើម្បីពិគ្រោះយោបល់ជាមួយអ្នកជំនួយការដែលត្រូវបានហាមឃាត់នៅខាងក្រៅកន្លែងធ្វើការសម្រុះសម្រួល ។

**ប្រការ ២៤ :-**

អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយរួមគ្នា ឬ ដាច់ដោយឡែកពីគ្នាប្រសិនបើមានការស្នើសុំដើម្បីពិភាក្សាពីបញ្ហារបស់ភាគី ពន្យល់ករណីវិវាទដល់ភាគីវិវាទដោយផ្អែកលើភស្តុតាង និងពិគ្រោះអំពីលទ្ធភាពដំណោះ-ស្រាយនានាដែលអាចមានចំពោះវិវាទ ។ ការពិគ្រោះត្រូវធ្វើឡើងដោយរក្សាការសំងាត់ក្នុងចំណោមភាគីវិវាទអ្នកជំនួយការរបស់ភាគី និង អ្នកសម្រុះសម្រួលហើយមិនត្រូវយកការពិគ្រោះនេះទៅធ្វើជាផ្អែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទឡើយ ។

អ្នកសម្រុះសម្រួល អាចស្នើដំណោះស្រាយដោយផ្អែកលើការយល់ដឹងរបស់ខ្លួនអំពីបំណងរបស់ភាគីវិវាទលើភស្តុតាងដែលមាន និងផ្អែកលើច្បាប់ពាក់ព័ន្ធប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវបង្ខំឱ្យអនុវត្តតាមសំណើរបស់ខ្លួន ឬ មិនត្រូវធ្វើសេចក្តីសំរេចលើ វិវាទនោះឡើយ ។ មានតែភាគីវិវាទទេដែលមានសិទ្ធិសំរេច ឬបដិសេធដំណោះស្រាយបាន ។

**ប្រការ ២៥ :-**

អ្នកសម្រុះសម្រួលត្រូវវិភាគភស្តុតាង ដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតដើម្បីយល់អោយបានពេញលេញអំពីស្ថានភាពនៃវិវាទ ប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវវាយតំលៃភស្តុតាងក្នុងសមត្ថភាពជាផ្លូវការណាមួយឡើយ ។

អ្នកសម្រុះសម្រួលអាចផ្តល់យោបល់ដល់ភាគីវិវាទ អំពីរបៀបបកស្រាយភស្តុតាងវិវាទ ឬ តំលៃនៃភស្តុតាងអាចត្រូវបានបកស្រាយយ៉ាងណា ប៉ុន្តែយោបល់ទាំងនោះពុំមានតំលៃខាងផ្លូវច្បាប់ និង មិនអាចក្លាយជាលំអានសំរាប់អនុវត្តនៅក្នុងដំណើរការសម្រុះសម្រួល ឬ ការវិនិច្ឆ័យណាមួយឡើយ ។

ការវាយតម្លៃភស្តុតាង អាចបញ្ចូលជាផ្នែកមួយនៃរបាយការណ៍សម្រុះសម្រួលដែលត្រូវបញ្ចូលទៅក្នុងកំណត់ហេតុផ្លូវការ នៃវិវាទ ។

**ប្រការ ២៦ :-**

ប្រសិនបើភាគីទាំងឡាយ អាចឈានដល់ការព្រមព្រៀងក្នុងពេលសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អ្នកសម្រុះសម្រួលត្រូវបំពេញបែបបទបញ្ចប់វិវាទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ ដែលមានរៀបរាប់អំពីដំណើរការដំណោះស្រាយដោយបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងដោះស្រាយនោះ ។ រាល់ឯកសារឬផែនទីនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយនោះត្រូវតម្កល់ជាមួយបែបបទបញ្ចប់វិវាទ ។

អ្នកសម្រុះសម្រួល ត្រូវអានដំណោះស្រាយព្រមព្រៀងអោយភាគីទាំងអស់ស្តាប់ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចព្រមព្រៀងតែក្នុងករណីដែលភាគីនោះយល់ព្រមលើរាល់ចំណុចនៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងនឹងមានសុពលភាពក្នុងករណីដែលភាគីវិវាទទាំងអស់បានព្រមព្រៀង និងបានចុះហត្ថលេខា ឬ បានផ្តិតមេដៃ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបែបបទបញ្ចប់រឿងក្តីរួចតម្កល់បែបបទនោះនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ។ មន្ត្រីទទួលទម្រង់បែបបទបញ្ចប់រឿងក្តីត្រូវចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនេះហើយត្រូវផ្តល់ដល់ភាគីវិវាទនីមួយៗនូវឯកសារថតចម្លងនៃបែបបទនេះ ។ ច្បាប់ថតចម្លងនៃបែបបទបញ្ចប់រឿងក្តីនេះគឺជាភស្តុតាងនៃការដាក់តម្កល់កិច្ចដំណោះស្រាយ ។

រាល់ឯកសារទាក់ទងទៅនឹងលទ្ធផលនៃការដោះស្រាយវិវាទរួមទាំងបែបបទបញ្ចប់រឿងក្តី សេចក្តីពណ៌នានៃកិច្ចដំណោះស្រាយ និង ផែនទី ឬ គំនូសតាងនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយ ត្រូវបិទផ្សាយជាសាធារណៈដែលមានរយៈពេលមិនតិចជាង ១៤ ថ្ងៃ ។ បុគ្គលណាក៏ដោយក៏អាចបញ្ចេញមតិលើឯកសារបញ្ចប់រឿងក្តីនេះក្នុងអំឡុងពេលប្រកាសផ្សាយជាសាធារណៈ ។

ក្រុមអ្នកសម្រុះសម្រួល ត្រូវរាយការណ៍អំពីកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ បន្ទាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះ ។

**ប្រការ ២៧ :-**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវបញ្ជាក់អំពីដំណោះស្រាយជាមួយភាគីវិវាទ និងត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះនៅពេលទទួលបានការបញ្ជាក់ថាដំណោះស្រាយបានសំរេចដោយស្ម័គ្រចិត្ត និង ថាភាគីវិវាទយល់ពីកិច្ចព្រមព្រៀង ។

**ប្រការ ២៨ :-**

ប្រសិនបើភាគីមិនអាចឈានដល់ដំណោះស្រាយ ក្រុមអ្នកសម្រុះសម្រួលត្រូវរៀបចំរបាយការណ៍ស្តីពីដំណើរការសម្រុះសម្រួលអនុលោមតាមបែបបទស្តង់ដារដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៧ ។ របាយការណ៍ត្រូវរួមបញ្ចូលពត៌មានជាមូលដ្ឋានស្តីពីភាគីវិវាទ សេចក្តីសង្ខេបជំហររបស់ភាគីវិវាទនិងសេចក្តីសង្ខេបអំពីដំណើរការសម្រុះសម្រួល។ របាយការណ៍នេះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុសាធារណៈផ្លូវការនៃវិវាទ និង ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

## ៦. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ខេត្ត ក្រុង

**ប្រការ ២៩ :-**

ករណីសម្រុះសម្រួលជំហានដំបូង រួមមានវិវាទដែលត្រូវបានបញ្ជូនទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីធ្វើការសម្រុះសម្រួលដោយផ្ទាល់ដោយអនុលោមតាមប្រការ១៨ និងប្រការ២១ នៃប្រកាសនេះ ។ ករណីសម្រុះ-សម្រួលជំហានដំបូង ត្រូវបានបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញនៃវិវាទទៅអោយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**ប្រការ ៣០ :-**

ករណីសម្រុះសម្រួលជំហានទី២ រួមមានវិវាទដែលដោះស្រាយមិនបានសំរេចនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ ករណីសម្រុះសម្រួលជំហានទី ២ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញ និងរបាយការណ៍សម្រុះ-សម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**ប្រការ ៣១ :-**

ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទសំរាប់ការសម្រុះសម្រួលជំហានដំបូង ឬ ការសម្រុះសម្រួលជំហានទី២ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងភាគីវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងរបស់អាជ្ញាធរដែនដី ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្តក្រុងពាក់ព័ន្ធនានាអោយចូលរួមជាសមាជិកអាដហុកដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និង ការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ ប្រសិនបើមាន ។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសំរាប់វិវាទនោះ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសំរាប់អោយភាគីបង្ហាញភស្តុតាងបន្ថែមនានា និង ពេលវេលាសំរាប់សម្រុះសម្រួលវិវាទ ។

**ប្រការ ៣២ :-**

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងមានផលប្រយោជន៍ក្នុងវិវាទសមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគី អាចដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងណាម្នាក់រួមទាំងប្រធានគណៈកម្មការដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការ ត្រូវសំរេចថាតើសមាជិកដែលត្រូវជំទាស់អំពីវិវាទផលប្រយោជន៍នោះត្រូវរារាំងមិនឱ្យសាមីខ្លួនចូលរួមក្នុង ការដោះស្រាយវិវាទឬទេ ។

**ប្រការ ៣៣ :-**

ភាគីទាំងឡាយ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នៅក្នុងលក្ខខណ្ឌតែមួយគឺ ភាគីវិវាទទាំងអស់ព្រមព្រៀងជាលាយលក្ខណ៍អក្សរចំពោះការប្រើប្រាស់អ្នកសម្រុះសម្រួលនោះ ។ ក្នុងករណីភាគីវិវាទទាំងអស់មិនព្រមព្រៀងលើសមាសភាពអ្នកសម្រុះសម្រួលណាមួយដែលមកពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវចាត់តាំងក្រុមអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ ។ ក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវរួមបញ្ចូលសមាជិកមួយរូបជាអ្នកបានទទួលការបណ្តុះបណ្តាល ឬ មានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទ និង សមាជិកមួយរូបជាអ្នកដឹងពីស្ថានភាព និង សភាពការណ៍នៅក្នុងមូលដ្ឋាន ។

**ប្រការ ៣៤ :-**

អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលនៅលើទីតាំងដី ឬ នៅជិតដីវិវាទ លើកលែងតែមានហេតុផលបញ្ជាក់ថាមានការគំរាមកំហែងដល់សន្តិសុខរបស់មន្ត្រីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ក្នុងករណីអសន្តិសុខដំណើរការសម្រុះសម្រួល វិវាទត្រូវធ្វើឡើងនៅទីកន្លែងដែលមានសន្តិសុខដែលនៅជិតដីវិវាទបំផុត ។

នីតិវិធីរដ្ឋបាលសំរាប់សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៤ នៃប្រកាសនេះ ។

**ប្រការ ៣៥ :-**

នីតិវិធីរដ្ឋបាលនៃដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយសំរាប់កិច្ចដំណោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុង ប្រការ២៦ នៃប្រកាសនេះ ។

អ្នកសម្រុះសម្រួល ត្រូវបញ្ជូនកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ដើម្បីចុះបញ្ជីក្បាលដី ។

**ប្រការ ៣៦ :-**

នីតិវិធីរដ្ឋបាលសំរាប់បញ្ជាក់អំពីកិច្ចដំណោះស្រាយដែលសំរេចបាននៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៧ នៃប្រកាសនេះ ។

**ប្រការ ៣៧ :-**

នីតិវិធីរដ្ឋបាលសំរាប់ការធ្វើរបាយការណ៍សម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៨ នៃ ប្រកាសនេះ ។

## ៧. ដំណើរការដោះស្រាយវិវាទរបស់ គណៈកម្មការសុរិយោដីថ្នាក់ជាតិ

**ប្រការ ៣៨ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិសំរេចវិវាទទាំងឡាយដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល ។

លើកលែងតែក្នុងករណីបន្ទាន់ដូចមានពណ៌នាក្នុងប្រការ៣៩នៃប្រកាសនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិមិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមអ្នកសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិនូវករណីវិវាទអមជាមួយកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួលដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ នៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង ។

**ប្រការ ៣៩ :-**

ក្នុងករណីវិវាទដែលតម្រូវឱ្យមានការសំរេច ឬ ដំណើរការដោះស្រាយជាបន្ទាន់ ដូចជាករណី មានការគំរាមកំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គីភ័យ ការប្រើកំលាំង ឬ ការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិអោយចាត់វិធានការបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ។ ក្នុងស្ថានភាពនេះ ភាគីអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ ជាតិឱ្យចេញសេចក្តីសំរេចបណ្តោះអាសន្ន ដើម្បីធ្វើអោយស្ថានការណ៍មានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និង សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ សេចក្តីសំរេចណ្តោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល ។

**ប្រការ ៤០ :-**

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវកោះប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិ តាមតម្រូវការដើម្បីដោះស្រាយវិវាទ ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធអោយចូលរួមជាសមាជិកអាដហុកដើម្បីដោះស្រាយវិវាទ ។ ប្រធានគប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**ប្រការ ៤១ :-**

បន្ទាប់ពីត្រួតពិនិត្យមើលកំណត់ហេតុផ្លូវការនៃវិវាទ ឬ នៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសំរេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត ។

នៅក្នុងស្ថានភាពនេះនីតិវិធីរដ្ឋបាលដើម្បីសម្រុះសម្រួលនៅថ្នាក់ជាតិត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដូចមានចែងលំអិតក្នុងប្រការ ២៤ នៃប្រកាសនេះ ។

ប្រសិនបើការសម្រុះសម្រួលមិនបានសំរេច ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកំណត់កាលបរិច្ឆេទសំរាប់ការធ្វើសវនាការដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ភាគីអាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យបញ្ជូនក្រុមអ្នកវិនិច្ឆ័យចល័តទៅកាន់ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងភាគី ទីកន្លែងធ្វើសវនាការត្រូវស្ថិតនៅជិតដីវិវាទបំផុត ។ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ គូវិវាទត្រូវកំណត់ពេលវេលាដើម្បីចុះទៅពិនិត្យមើលទីតាំងដីវិវាទ ឬ ព្រមព្រៀងលើកលែងការស៊ើបអង្កេតបន្ថែមទៀតបាន ។

**ប្រការ ៤២ :-**

ប្រសិនបើ សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទ ហើយប្រសិនបើចាំបាច់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគីអាច ដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិករួមទាំងប្រធានគណៈកម្ម-ការសុរិយោដីថ្នាក់ជាតិដោយផ្អែកលើវិវាទអំពីផលប្រយោជន៍របស់សមាជិកនោះ ។ សមាជិកដទៃទៀតនៃ គណៈកម្មការត្រូវសំរេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទអំពីផលប្រយោជន៍នោះត្រូវរារាំងមិនអោយចូលរួមក្នុងការដោះស្រាយវិវាទ ឬ ទេ ។

**ប្រការ ៤៣ :-**

រាល់កិច្ចប្រជុំ ឬសវនាការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងទៅនឹងវិវាទត្រូវបើកចំហជាសាធារណៈ ។

សេចក្តីជូនដំណឹងជាមុនអំពីរាល់កិច្ចប្រជុំ ឬ សវនាការដែលជាការចាត់វិធានការផ្លូវការត្រូវជូនដល់សាធារណជន និង ប្រព័ន្ធសារពត៌មាន ។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរក្សាទុកកំណត់ហេតុនៃដំណើរការរឿងវិវាទទាំងអស់របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយបុគ្គលណាក៏មានសិទ្ធិមើលកំណត់ហេតុទាំងនោះទោះបីបុគ្គលនោះមាន ឬគ្មានផលប្រយោជន៍នៅក្នុងវិវាទនោះក្តី ។

**ប្រការ ៤៤ :-**

លើកលែង តែការប្រជុំសំរាប់ការសម្រុះសម្រួលដែលអាចធ្វើឡើងជាមួយភាគីវិវាទដោយឡែកពីគ្នា គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអញ្ជើញភាគីដែលមានផលប្រយោជន៍ទាំងអស់ឱ្យចូលរួមរាល់កិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ ។ សេចក្តីអញ្ជើញ ត្រូវបញ្ជូនទៅអោយភាគី យ៉ាងហោច ១៥ ថ្ងៃនៃថ្ងៃធ្វើការមុនពេលបើកកិច្ចប្រជុំ ឬ សវនាការ ។

**ប្រការ ៤៥ :-**

ភាគី អាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ អោយតំណាងខ្លួននៅក្នុងរាល់ដំណើរការ នៃរឿងវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បុគ្គលនេះហៅថាអ្នកការពារក្ដី អាចផ្ដល់ការណែនាំ ឬអាចតំណាងភាគីបាន។ អ្នកការពារក្ដីអាចបញ្ជាក់ពីចម្លើយរបស់ភាគី និងអាចចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសុរិយោដីថ្នាក់ជាតិហើយតាមការយល់ព្រមរបស់ភាគីអាចនិយាយ និងអាចធ្វើសេចក្ដីសំរេចក្នុងនាមភាគីបាន ។ ទោះបីជាយ៉ាងណាក្ដីបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់របស់ភាគីទេនោះ អ្នកការពារក្ដីមិនអាចដោះស្រាយវិវាទក្នុងនាមភាគីបានឡើយ ។

ប្រសិនបើ អ្នកការពារក្ដីបំពានវិធាននៃដំណើរការរឿងវិវាទ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្ដល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្ដងដល់អ្នកការពារក្ដី ។ ប្រសិនបើ អ្នកការពារក្ដីនៅតែបន្តបំពានទៀតគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវហាមឃាត់អ្នកការពារក្ដីនោះមិនឱ្យចូលរួមក្នុងដំណើរដោះស្រាយវិវាទទៀតឡើយ ។ ប្រសិនបើអ្នកការពារក្ដីត្រូវបានហាមឃាត់មិនឱ្យចូលរួម ដំណើរការរឿងវិវាទនោះត្រូវផ្អាក រហូតដល់ភាគីជ្រើសរើសអ្នកការពារក្ដីថ្មីបានឬយល់ព្រមឱ្យបន្តដំណើរការដោយមិនមានអ្នកការពារក្ដី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ដល់ឱកាសគ្រប់គ្រាន់ដល់ភាគីដើម្បីពិគ្រោះយោបល់ជាមួយអ្នកការពារក្ដីដែលត្រូវបានហាមឃាត់អោយនៅក្រៅកន្លែងដោះស្រាយ ។

**ប្រការ ៤៦ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចធ្វើសវនាការវិវាទជាក្រុមវិនិច្ឆ័យ ឬ អាចតែងតាំងសមាជិកតែម្នាក់ ឬមន្ត្រីសវនា ការតែមួយរូបឱ្យធ្វើសវនាការបាន ។

រាល់សវនាការ សក្ខីកម្មផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ។

គណៈកម្មការសុរិយោដីថ្នាក់ ជាតិ មិនត្រូវបានតម្រូវអោយគោរពតាមវិធានភស្ដុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែត្រូវធានាឱ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និង ភស្ដុតាងរបស់ខ្លួនដោយយុត្តិធម៌ និង សមធម៌ ។

ភាគីនីមួយៗមានសិទ្ធិបង្ហាញសាក្សី និងបដិសេធភស្ដុតាង ឬសាក្សីដែលផ្ដល់ដោយភាគីផ្សេងទៀត ។ បុគ្គលដែលផ្ដល់សក្ខីកម្មអាចត្រូវបានតម្រូវអោយឆ្លើយនឹងសំនួរបញ្ជាក់អំពីសក្ខីកម្មនោះ ។

**ប្រការ ៤៧ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវស្ដាប់ភស្ដុតាងវិវាទ និង ត្រួតពិនិត្យឯកសារផ្លូវការនៃវិវាទដែលបានប្រមូលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ដោយគណៈកម្មការរដ្ឋបាល ហើយត្រូវចេញសេចក្ដីសំរេចដែលមានប្រសិទ្ធភាពអនុវត្តដោយផ្អែកលើរបាយការណ៍នេះ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចេញសេចក្តីសំរេចនៅពេលធ្វើការសរុបសន្និដ្ឋានការពិភាក្សារបស់ខ្លួនហើយត្រូវធ្វើកំណត់សំគាល់សេចក្តីសន្និដ្ឋានខាងផ្លូវច្បាប់ និង មូលដ្ឋានអង្គហេតុនៃសេចក្តីសំរេចរបស់ខ្លួន ។ សេចក្តីសំរេចស្ថាពរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ចុះហត្ថលេខាដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើអោយភាគីទាំងឡាយតាមរយៈសំបុត្រប្រៃសណីយ៍ និងត្រូវបើកចំហសំរាប់ការពិនិត្យមើលជាសាធារណៈដល់បុគ្គលណាក៏ដោយទោះបីមាន ឬគ្មានផលប្រយោជន៍នៅក្នុងរឿងវិវាទនោះក្តី ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សរ ត្រូវអមជាមួយសេចក្តីជូនដំណឹងដែលជំរាបភាគីវិវាទអំពីសិទ្ធិរបស់ពួកគេក្នុងការប្តឹងតវ៉ាទៅតុលាការឱ្យពិនិត្យមើលឡើងវិញផ្នែកច្បាប់ ចំពោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយត្រូវផ្តល់ពត៌មានអំពីរបៀបប្តឹងទៅតុលាការផង ។

**ប្រការ ៤៨ :-**

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាសេចក្តីសំរេចស្ថាពរនៅក្រោយ រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចនោះត្រូវបានបញ្ជូនទៅដល់ភាគីវិវាទទាំងអស់ លើកលែងតែករណីមានការប្តឹងទៅតុលាការ ឬមានការស្នើសុំ ឱ្យធ្វើការពិនិត្យឡើងវិញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ អនុលោមតាមប្រការ ៤៩ នៃប្រកាសនេះ។

ប្រសិនបើគ្មានការប្តឹងតវ៉ាទៅតុលាការ ឬ គ្មានការស្នើសុំអោយធ្វើសវនាការឡើងវិញត្រូវបានធ្វើឡើងតាមពេលវេលាត្រឹមត្រូវទេលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបញ្ជូនសេចក្តីសំរេចនោះទៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ។ បន្ទាប់មក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលត្រូវបានសំរេចនោះ។

**ប្រការ ៤៩ :-**

ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសម្លេងយល់ព្រមពីសមាជិក ៣ រូប នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលមានភស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការ ។

សំណើសុំធ្វើសវនាការឡើងវិញ ត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅដល់ភាគី ហើយត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនោះដោយត្រូវអមដោយពត៌-មាននិងគំនូសតាងចាំបាច់នានា ។

ការធ្វើសវនាការឡើងវិញ ត្រូវអនុលោមតាមសេចក្តីជូនដំណឹង និង លក្ខខណ្ឌតម្រូវផ្នែកនីតិវិធីដូចសវនាការដើមដែរ ។

ប្រសិនបើមានការបដិសេធចំពោះសំណើសុំអោយមានសវនាការឡើងវិញ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្ដីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនទៅដល់ភាគីវិវាទលើកលែងតែភាគីម្ខាងនៃគូវិវាទជូនដំណឹងអំពីការប្ដឹងជំទាស់ទៅតុលាការតាមពេលវេលាត្រឹមត្រូវ ។

**ប្រការ ៥០ :-**

ភាគីណាក៏ដោយអាចប្ដឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្ដឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្ដីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ ។

ភាគីណាមួយដែលធ្វើបណ្ដឹងទៅតុលាការ ត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្ដឹងជំទាស់នៅលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

លេខាធិការដ្ឋាន ត្រូវធ្វើសេចក្ដីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាការ ។

## ៨. បទប្បញ្ញត្តិរដ្ឋបាល

**ប្រការ ៥១ :-**

ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្ដីពីបណ្ដឹងដែលបានទទួល និង ចំណាត់ការដែលបានធ្វើដោយគណៈកម្មការចំពោះបណ្ដឹងនីមួយៗ ដែលគណៈកម្មការបានធ្វើ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ រាជរដ្ឋាភិបាល ។

របាយការណ៍របស់គណៈកម្មការសុរិយោដី ត្រូវបើកចំហ និង អនុញ្ញាតឱ្យសាធារណជនមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា ។

**ប្រការ ៥២ :-**

គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវរក្សាទុកកំណត់ហេតុផ្លូវការនៃវិវាទនីមួយៗដែលបានប្ដឹងនៅគណៈកម្មការនោះ ។

កំណត់ហេតុផ្លូវការ ត្រូវរួមបញ្ចូលរាល់ឯកសារទាំងអស់ សេចក្តីអះអាងភស្តុតាងផ្សេងៗ និងរបាយការណ៍ផ្សេងៗ ទាក់ទងទៅនឹងវិវាទ ។

ឯកសារផ្លូវការត្រូវបើកចំហជាសាធារណៈ និង អនុញ្ញាតឱ្យសាធារណជនចូលមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា។

បុគ្គលទាំងឡាយដែលចង់ពិនិត្យមើលឯកសារ ត្រូវទៅមើលនៅការិយាល័យគណៈកម្មការសុរិយោដីនោះ និងត្រូវចុះហត្ថលេខាលើសៀវភៅភ្ញៀវ ។

នៅកន្លែងដែលមានសម្ភារៈបរិក្ខារថតចម្លង បុគ្គលទាំងឡាយអាចថតចម្លងឯកសារបាន ។

**ប្រការ ៥៣ :-**

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

**រដ្ឋមន្ត្រី**

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល :</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៥៣
- ឯកសារ កាលប្បវត្តិ

# យន្តការដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជា

## ក. សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញការពារសិទ្ធិមានកម្មសិទ្ធិឯកជនលើអចលនវត្ថុ[1] និងតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនាំឲ្យសិទ្ធិប្រជាពលរដ្ឋក្នុងការមានកម្មសិទ្ធិឯកជនត្រូវបានការពារយ៉ាងរឹងមាំថែមទៀត។ កម្ពុជាបានក្លាយជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន[2] ដែលការពារសិទ្ធិមានកម្មសិទ្ធិឯកជនរួមមានសិទ្ធិមាននិវេសនដ្ឋានសមរម្យ និងមិនទទួលរងការដកហូតតាមអំពើចិត្ត សិទ្ធិមានអាហារហូបចុកគ្រប់គ្រាន់សិទ្ធិធ្វើការងារ សិទ្ធិខាងសុខភាព សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងការប្រជុំ និងសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។

រដ្ឋធម្មនុញ្ញធានាសិទ្ធិប្រជាពលក្នុងការប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទាសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអង្គការរដ្ឋ អង្គការសង្គម ឬបុគ្គលនៃអង្គការទាំងនេះ និងសិទ្ធិទទួលបានដំណោះស្រាយដោយតុលាការឯករាជ្យ។ មាត្រា ១២៨ កថាខណ្ឌ ១ និង ២ នៃរធ្មធម្មនុញ្ញកម្ពុជាចែងថា *"អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការ ជានារក្សាអនាគត និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។"*

ការដោះស្រាយទំនាស់ដីធ្លី គឺអាស្រ័យថាតើដីនោះបានចុះបញ្ជី ឬមិនទាន់បានចុះបញ្ជី។ តើយើងត្រូវប្រើយន្តការបែបណាខ្លះ ដើម្បីការពារនិងធានាសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ? ផ្អែកតាមច្បាប់ភូមិបាលនិងអនុក្រឹត្យលេខ៤៦ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី(២០០២) និងអនុក្រឹត្យលេខ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីមានយន្តការមួយចំនួនសម្រាប់ការដោះស្រាយទំនាស់ក្នុងប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ រួមមាន ១) ក្រុមប្រឹក្សាឃុំ សង្កាត់ ២) គណៈកម្មការសុរិយោដី ៣)គណៈកម្មការរដ្ឋបាល ៤) អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង ៥) ប្រព័ន្ធតុលាការ។

## ១. ក្រុមប្រឹក្សាឃុំសង្កាត់

ក្រុមប្រឹក្សាឃុំសង្កាត់ "ជាអ្នកប្រមូលគំនិតយោបល់ផ្សេងៗ" របស់ប្រជាពលរដ្ឋក្នុងឃុំសង្កាត់ ប៉ុន្តែគ្មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចនោះទេ។[3] នៅពេលគ្មានសេចក្តីសម្រេចជាមុន

[1] មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ

[2] សន្ធិសញ្ញាសំខាន់ៗមានកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ និងកតិកាសញ្ញាស្តីពីសិទ្ធិខាងសេដ្ឋកិច្ច សង្គមនិងវប្បធម៌។

[3] អនុក្រឹត្យលេខ ២២ កណដ/ខដ ស្តីពី វិមជ្ឈការនៃអំណាច តួនាទី និងករណីកិច្ចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ មាត្រា ៦១។

តាមការអនុវត្តជាក់ស្តែង ករណីភាគច្រើនគ្រាន់តែធ្វើសវនកម្មនៅមុខក្រុមប្រឹក្សាឃុំសង្កាត់ មុនពេលបញ្ជូនបន្តទៅថ្នាក់លើ។[4]

## ២. គណៈកម្មការសុរិយោដីធ្លី

កម្មវិធីគ្រប់គ្រងនិងរៀបចំដីធ្លីដែលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ២០០២ គឺជាដំណាក់កាលដំបូងនៃការរៀបចំ ការគ្រប់គ្រង និងការបែងចែកដីធ្លីរបស់រដ្ឋាភិបាល។ កម្មវិធីនេះដំបូងឡើយមានគម្រោងអនុវត្តរយៈពេល១៥ឆ្នាំ និងបានដាក់ចេញនូវទិសដៅសំខាន់ៗមួយចំនួន រួមទាំងការទប់ស្កាត់ និងដោះស្រាយទំនាស់ដីធ្លីនានាផងដែរ។ ប៉ុន្តែធនាគារពិភពលោកជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយជាមួយកម្មវិធីនេះ បានចេញសេចក្តីថ្លែងការណ៍មួយនៅឆ្នាំ២០០៩ ថាកម្មវិធីគ្រប់គ្រង និងរៀបចំដីធ្លីមិនបានសម្រេចលទ្ធផលតាមការគ្រោងទុកនោះទេ ជាពិសេសសំដៅដល់កិច្ចការពារផ្នែកសង្គមនិងបរិស្ថាននៅតាមតំបន់ទំនាស់នានាក្នុងទីក្រុង។ ព្រោះហេតុដូច្នេះ រដ្ឋាភិបាលបានសម្រេចបញ្ចប់ភាពជាដៃគូក្នុងកម្មវិធីគ្រប់គ្រង និងរៀបចំដីធ្លីជាមួយធនាគារពិភពលោកដែលនាំឱ្យមានការបញ្ចប់ការផ្តល់ថវិការបស់ធនាគារពិភពលោកដល់គម្រោងនេះ។

ជាការគួរឱ្យកត់សម្គាល់នោះគឺសមាសភាគចំនួនបួននៃកម្មវិធីគ្រប់គ្រង និងរៀបចំដីធ្លីផ្តោតសំខាន់លើការបង្កើនសមត្ថភាពស្ថាប័នរដ្ឋាភិបាលក្នុងការដោះស្រាយទំនាស់ដីធ្លី ពោលគឺតាមរយៈការបង្កើតយន្តការដោះស្រាយទំនាស់បីថ្នាក់នៃគណៈកម្មការសុរិយោដី។ ច្បាប់ភូមិបាលណែនាំថាជម្លោះកើតឡើងលើដីធ្លីដែលមិនទាន់បានចុះបញ្ជីត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីដើម្បីធ្វើការស៊ើបអង្កេតនិងដោះស្រាយ។[5] គណៈកម្មការសុរិយោដីត្រូវបានគេរំពឹងថានឹងផ្តល់នូវមធ្យោបាយដោះស្រាយករណីវិវាទនោះទាន់ពេលវេលាដោយពុំមានការចំណាយនិងមានការជំទាស់តិចតួច។

យន្តការដោះស្រាយទំនាស់ថ្នាក់ក្រោមចំនួនបី បានបង្កើតឡើងនៅក្រោមគណៈកម្មការសុរិយោដីដើម្បីធ្វើសវនកម្មទំនាស់នានាពាក់ព័ន្ធទៅនឹងដីធ្លីដែលមិនទាន់បានចុះបញ្ជី និងទំនាស់ដែលមិនទាន់បានដោះស្រាយនៅមុខគណៈកម្មការរដ្ឋបាល យន្តការទាំងនេះមាន ១)នៅថ្នាក់ស្រុកខណ្ឌ ២) នៅថ្នាក់ខេត្តក្រុង និង ៣)នៅថ្នាក់ជាតិ។ ទំនាស់ដីធ្លីជាដំបូង ត្រូវដោះស្រាយនៅថ្នាក់ស្រុកខណ្ឌដែលមានសមត្ថកិច្ចត្រឹមតែផ្តល់ការគាំទ្រឱ្យមានការផ្សះផ្សា។[6] ប្រសិនបើមិនអាចឈានដល់ការព្រមព្រៀងគ្នានៅថ្នាក់ស្រុកខណ្ឌទេ ករណីនេះត្រូវបញ្ជូនទៅថ្នាក់ខេត្តក្រុងដើម្បីផ្សះផ្សាថែម

[4] របាយការណ៍របស់អ្នកតំណាងពិសេស ឆ្នាំ២០១២។

[5] ច្បាប់ភូមិបាលអនុក្រឹត្យលេខ ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ឆ្នាំ២០០២។

[6] ប្រភពខាងលើមាត្រា ៦។

ទៀត។[7] ដោយហេតុថា នៅឆ្នាំ២០០៩ គណៈកម្មការសុរិយោដីខេត្តទទួលបានប្រតិភូកម្មអំណាចឱ្យចេញសេចក្តីសម្រេចក្នុងករណីនានានៅពេលដែលដំណោះស្រាយមិនអាចទៅរួច។[8] នៅថ្នាក់ស្រុកខណ្ឌ និងថ្នាក់ខេត្តក្រុង គណៈកម្មការសុរិយោដីដឹកនាំដោយអភិបាលស្រុកខណ្ឌនិងថ្នាក់ខេត្តក្រុង។[9] ប្រសិនបើករណីនោះមិនអាចដោះស្រាយបាននៅថ្នាក់ស្រុកខណ្ឌ និងខេត្តក្រុងនោះទេ ករណីវិវាទនេះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីធ្វើការវិនិច្ឆ័យ។[10]

## ៣. គណៈកម្មការរដ្ឋបាល

គណៈកម្មការរដ្ឋបាល ធ្វើប្រតិបត្តិការនៅគ្រប់តំបន់នានា ហើយករណីដំបូងកើតឡើងនៅក្នុងអំឡុងពេលយុទ្ធនាការចុះបញ្ជីដីធ្លីឧបត្ថម្ភដោយរដ្ឋាភិបាល។[11] ទោះបីជាគណៈកម្មការរដ្ឋបាលពុំមានអំណាចចេញសេចក្តីសម្រេចចងកាតព្វកិច្ចក្តីក៏អាចជួយភាគីមានជម្លោះក្នុងការដោះស្រាយទំនាស់នោះបានផងដែរ។[12]

## ៤. អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

នៅក្នុងខែមីនា ឆ្នាំ២០០៦ មានព្រះរាជក្រឹត្យ[13]បង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ ការបង្កើតអាជ្ញាធរជាតិនេះគឺធ្វើឡើងតាមរយៈព្រះរាជក្រឹត្យជាជាងច្បាប់ភូមិបាលបង្កើតដោយសភាដែលបង្កការលំបាកក្នុងការផ្សះផ្សាជាមួយនឹងស្ថាប័នដោះស្រាយទំនាស់ដីធ្លីដទៃទៀត។

---

[7] ប្រភពខាងលើមាត្រា១៥។

[8] ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការធ្វើប្រតិភូតកម្មអំណាចដល់អភិបាលនៃគណៈអភិបាលខេត្ត/ក្រុង ប្រធានគណៈកម្មការសុរិយោដីខេត្តក្រុងតាមការចេញសេចក្តីសម្រេចលើទំនាស់ដីធ្លីតាមយន្តការដោះស្រាយរបស់គណៈកម្មការសុរិយោដី ថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ សារាចរណែនាំរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់លេខ១ ស្តីពីការអនុវត្តនីតិវិធីសម្រេចលើករណីវិវាទដីធ្លីនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។

[9] ធនាគារពិភពលោក មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងជីអាយហ្សេត "តើឆ្ពោះទៅរកស្ថាប័នយុត្តិធម៌? ការត្រួតពិនិត្យទៅលើការងាររបស់គណៈកម្មការសុរិយោដីនៅកម្ពុជាពាក់ព័ន្ធទៅនឹងដំណោះស្រាយទំនាស់ដីធ្លី" ទំព័រ១២ (ខែតុលា ឆ្នាំ២០០៦) អាចរកបានតាមរយៈ ៖ http//bit.ly/1n30yAW។

[10] ច្បាប់ភូមិបាល មាត្រា ១៦។

[11] រដ្ឋាភិបាលបង្កើតកម្មវិធីចុះបញ្ជីដីធ្លីចំនួនពីគឺ ៖ ១) កម្មវិធីចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ និង ២) កម្មវិធីចុះបញ្ជីដីធ្លីម្តងម្កាល។ ការចុះបញ្ជីដីធ្លីជាប្រព័ន្ធគឺផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល ដែលកំណត់តំបន់មួយនៅពេលបានវាស់វែង និងផ្តល់ប័ណ្ណកម្មសិទ្ធិរួចហើយ និងមានគោលបំណងធ្វើឱ្យដីដែលពុំមានលក្ខណៈគ្រប់គ្រាន់តាមច្បាប់នោះជាដីស្របច្បាប់។

[12] សមាសភាព និងតួនាទីរបស់គណៈកម្មការគ្រប់គ្រងដីធ្លីមានចែងនៅក្នុងអនុក្រឹត្យលេខ ៤៦ កណដ/ខដ ស្តីពីនីតិវិធីបង្កើតផែនទីឧបសម្ព័ន្ធសុរិយោដី និងបញ្ជីដីធ្លី ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។

[13] ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកដោះស្រាយទំនាស់ដីធ្លី ណស/ជន/០២០៦/០៩៧ (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦)។

ម្យ៉ាងវិញទៀត ការពុំបានចែងពីរបៀបការអនុវត្តរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីក្នុងច្បាប់ភូមិបាលបានលើកជាមន្ទិលសង្ស័យជាខ្លាំងពីធម្មនុញ្ញភាពរបស់ស្ថាប័ននេះ។[14] បច្ចុប្បន្ននេះ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដឹកនាំដោយឧបនាយករដ្ឋមន្ត្រី[15]រួមទាំងសមាជិកសភា ទីប្រឹក្សារដ្ឋាភិបាល និងអ្នកច្បាប់។ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តល់ឱកាសឱ្យតែងតាំងតំណាងមួយរូបចូលរួមក្នុងគណៈកម្មការនេះ តែពួកគេបានបដិសេធក្នុងការចូលរួមដោយសំអាងថា ពួកគេមិនចង់ពាក់ព័ន្ធជាមួយស្ថាប័ន ព្រោះខ្លួនពុំមានឥទ្ធិពលនោះទេ។[16]

សមាសភាពអនុប្រធាន រួមមានរដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស។[17] អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានអគ្គលេខាធិការដ្ឋានដឹកនាំដោយរដ្ឋលេខាធិការនៅទីស្តីការគណរដ្ឋមន្ត្រី។[18] ការសិក្សាមួយបានរកឃើញថាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបញ្ជូនកិច្ចការទាំងអស់ទៅនាយករដ្ឋមន្ត្រីដើម្បីធ្វើសេចក្តីសម្រេចចុងក្រោយ។ សមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបង្ហាញថាខ្លួនត្រូវបានគ្រប់គ្រងទាំងស្រុងដោយមន្ត្រីឬសមាជិករបស់រដ្ឋាភិបាលដែលជាការគំរាមធ្ងន់ធ្ងរដល់ឯករាជ្យភាព និងភាពត្រឹមត្រូវនៃអាជ្ញាធរជាតិនេះ។ ការសិក្សាដដែលនេះបានរកឃើញថាបុគ្គលិកនៅក្នុងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានការស្ទាក់ស្ទើរក្នុងការផ្តល់ព័ត៌មានសំខាន់ៗដល់សាធារណៈជន។[19]

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានឥទ្ធិពលដោះស្រាយទំនាស់ដីធ្លីតាមរយៈការកំណត់ថាតើភាគីណាមួយត្រូវទទួលយកហើយភាគីណាមួយត្រូវបញ្ជូនទៅស្ថាប័នដទៃទៀត (រួមទាំងតុលាការ) និងពីរបៀបដែលខ្លួនស៊ើបអង្កេត។[20] សេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយ

---

[14] ដាណៃ អេដលើ "អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីកម្ពុជា៖ ការសិក្សាពិសេស" មជ្ឈមណ្ឌលដើម្បីការសិក្សាឈានមុខ និងធនាគារពិភពលោក យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋក្រក្រី (ខែមករា ឆ្នាំ២០០៨) អាចរកបានតាមរយៈ៖ http://bit.ly/T2yNwO។

[15] ម៉ាយ ទិត្យថារា "ទំនាស់ដីធ្លីភាគច្រើននៅកម្ពុជាមិនត្រូវបានដោះស្រាយ" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣) អាចរកបានតាមរយៈ ៖ http://bit.ly/1nzKxPZ។

[16] របាយការណ៍របស់អ្នករាយការណ៍ពិសេស ឆ្នាំ២០១២។

[17] អនុក្រឹត្យលេខ១២២៧ ស្តីពីការរៀបចំនៃសមាសភាពរបស់គណៈកម្មការជាតិដោះស្រាយទំនាស់ដីធ្លី ខែវិច្ឆិកា ឆ្នាំ២០១១។

[18] ប្រភពខាងលើ។

[19] ដាណៃល អេដលើ "អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីកម្ពុជា៖ ការសិក្សាពិសេស" មជ្ឈមណ្ឌលដើម្បីការសិក្សាស្រាវជ្រាវជាន់ខ្ពស់និងធនាគារពិភពលោក យុត្តិធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ (ខែមករា ឆ្នាំ២០០៨) អាចរកបានតាម៖ http://bit.ly/T2yNwO។

[20] ប្រភពខាងលើ។

ទំនាស់ដីធ្លីអាចប្តឹងឧទ្ធរណ៍ទៅតុលាការបានដរាបណាសេចក្តីសម្រេចនោះអាចត្រូវកំណត់បាន តែទោះបីជាមានការកំណត់ដូច្នេះក៏ដោយ សិទ្ធិនេះមិនទាន់ត្រូវបានប្រើប្រាស់នៅឡើយទេ។[21]

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបំពេញមុខងារបន្ថែមដល់គណៈកម្មការសុរិយោដី និងត្រូវបានផ្តល់សិទ្ធិឱ្យធ្វើសវនកម្មលើករណីទំនាស់ដីធ្លីនានាដែល"ផុតពីដែនយុត្តាធិការ" របស់គណៈកម្មការសុរិយោដី។[22] ដោយហេតុថា ករណីទាំងនោះពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់ ឬបុគ្គលមានឥទ្ធិពលដែលត្រូវបានបញ្ជូនមកកាន់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អាជ្ញាធរនេះត្រូវបានគេរិះគន់ជុំវិញការអនុវត្តរំលងយុត្តាធិការដ៏ត្រឹមត្រូវរបស់គណៈកម្មការសុរិយោដីនិងតុលាការ។ ជាងនេះទៅទៀតនោះ អាណត្តិការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីត្រូវបានគេរិះគន់ថាមានភាពមិនច្បាស់លាស់និងមានដែនសមត្ថកិច្ចហួសហេតុលើច្បាប់ភូមិបាល។

## ៥. តុលាការ

តុលាការកម្ពុជាមានយុត្តាធិការទៅលើទំនាស់ដីណាដែលបានចុះបញ្ជី និងដីដែលបានផ្តល់ប័ណ្ណកម្មសិទ្ធិរួចហើយ។[23] ប្រសិនបើភាគីមិនពេញចិត្តអាចប្តឹងទៅសាលាឧទ្ធរណ៍បាន។ ភាគីដែលមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសុរិយោដីថ្នាក់ជាតិអាចប្តឹងទៅតុលាការផងដែរ។[24] តុលាការក៏មានយុត្តាធិការដែរទៅលើករណីវិវាទកិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជាវិវាទអំពីការបែងចែកមរតក និងវិវាទអំពីកិច្ចសន្យាទិញ លក់ ជួល បញ្ចាំជាដើម។[25] ប្រសិនបើករណីនោះពាក់ព័ន្ធនឹងដីធ្លីដែលមិនទាន់ចុះបញ្ជីភាគីត្រូវតែបញ្ជូនករណីនោះជាដំបូងទៅកាន់គណៈកម្មាធិការសុរិយោដី។

ក្រៅពីយន្តការផ្លូវការដែលបានរៀបរាប់ខាងលើ ប្រជាពលរដ្ឋអាចដាក់ពាក្យសុំអន្តរាគមន៍ទៅក្រសួងមន្ទីរពាក់ព័ន្ធនិងស្ថាប័នភាគីពាក់ព័ន្ធនានាដើម្បីឲ្យជួយសម្រួលនិងពន្លឿនទៅលើការងារដំណោះស្រាយទំនាស់ដីធ្លីនោះ។

[21] ប្រភពខាងលើ។

[22] ព្រះរាជក្រឹត្យ ណស/ទនដ/០២០៦/៦៩៧ មាត្រា៣។

[23] ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ប្រកាសរួមលេខ ៣ ស្តីពីការកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីទាក់ទិននឹងទំនាស់ដីធ្លី ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ មាត្រា១ ។

[24] អនុក្រឹត្យលេខ ៤៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ មាត្រា ២៣។

[25] ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ប្រកាសរួមលេខ ៣ ស្តីពីការកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីទាក់ទិននឹងទំនាស់ដីធ្លី ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ មាត្រា ៤។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំចុះបញ្ជីដី

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ.................................. ភេទ........... អាយុ........... ឆ្នាំ សញ្ជាតិ........ ប្រពន្ធ/ប្ដីឈ្មោះ............................................ មានទីលំនៅផ្ទះលេខ.................. ផ្លូវលេខ................. ភូមិ............................ ឃុំ/សង្កាត់........................ក្រុង/ស្រុក/ខណ្ឌ..........................រាជធានី/ខេត្ត . ............................... លេខទូរស័ព្ទទំនាក់ទំនង.........................................................................................។

**សូមគោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**តាមរយៈ** ៖ លោក/លោកស្រីចៅសង្កាត់ ..........................................................................

**កម្មវត្ថុ** ៖សំណើសុំចុះបញ្ជីដី

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមអនុញ្ញាតស្នើសុំចុះបញ្ជីដីមួយកន្លែងប្រភេទ(១)........... មានទំហំប្រមាណ................ស្ថិតនៅភូមិ......................... សង្កាត់.......................... ខណ្ឌ.................... រាជធានីភ្នំពេញ មានព្រំប្រទល់ ៖

-ខាងជើងទល់នឹង...............................................................................................

-ខាងត្បូងទល់នឹង.............................................................................................

-ខាងកើតទល់នឹង..............................................................................................

-ខាងលិចទល់នឹង.............................................................................................

ដីនេះខ្ញុំបាទ នាងខ្ញុំបានកាន់កាប់ប្រើប្រាស់ចាប់ពីឆ្នាំ............មកដល់បច្ចុប្បន្ន ដែលបានមកពី(១) .............. ដីក្នុងតំបន់នេះត្រូវបានចុះបញ្ជីតាមនីតិវិធីមានលក្ខណៈជាប្រព័ន្ធរួចហើយ ប៉ុន្តែក្បាលដីរបស់ខ្ញុំបាទ/នាងខ្ញុំ មិនទាន់បានចុះបញ្ជីនៅឡើយ ដោយមូលហេតុ(៣)..............................................................................

អាស្រ័យហេតុនេះ សូម**ឯកឧត្តមអភិបាល**មេត្តាពិនិត្យ និងសម្រេចធ្វើការចុះបញ្ជីដីឲ្យខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ។

ខ្ញុំបាទ/នាងខ្ញុំ សូមប្ដេជ្ញាថា អនុវត្តរាល់កាតព្វកិច្ច និងបទបញ្ជាផ្សេងៗ ដែលរដ្ឋបានកំណត់។

ថ្ងៃ......................ខែ...........ឆ្នាំ.................ព.ស២៥...

លេខ.......................

រាជធានីភ្នំពេញ,ថ្ងៃទី.........ខែ...........ឆ្នាំ២០.....

ស្នាមម្រាមដៃ

បានឃើញ និងបញ្ជូនមកលោក

ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល

ដើម្បីពិនិត្យ និងសម្រេចតាមការគួរ។

ថ្ងៃ......................ខែ..............ឆ្នាំ.......................ពស២៥ ......

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ..............ឆ្នាំ២០......

**ចៅសង្កាត់**

កំណត់សំគាល់

(១) ដីលំនៅដ្ឋាន ឬដីសាងសង់ ឬដីផលិតកម្មកសិកម្ម

(២) រដ្ឋចែកឲ្យ ឬទិញពីឈ្មោះ ឬប្រទានកម្ម-សន្តតិកម្ម

(៣) សំរាប់ចុះបញ្ជីបំពេញបន្ថែម

ក្រដាសពុម្ពលេខ ២
ទីទុកឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌ:…………………..
លេខ:…………………………….

# សេចក្តីជូនដំណឹង

សូមប្រកាសជូនសាធារណៈជនឱ្យបានជ្រាបថា តាមពាក្យស្នើសុំចុះបញ្ជីដីធ្លីរបស់ ៖

១-ឈ្មោះ…………………………………………… ដែលស្ថិតក្នុងភូមិ…………………………. ឃុំ សង្កាត់……………………………
មានព្រំប្រទល់ : ខាងជើងទល់នឹង……………………………………ខាងត្បូងទល់នឹង … … ……………………………..
ខាងកើតទល់នឹង……………………………………ខាងលិចទល់នឹង … … ……………………………..។

២-ឈ្មោះ…………………………………………… ដែលស្ថិតក្នុងភូមិ…………………………. ឃុំ សង្កាត់……………………………
មានព្រំប្រទល់ : ខាងជើងទល់នឹង……………………………………ខាងត្បូងទល់នឹង … … ……………………………..
ខាងកើតទល់នឹង……………………………………ខាងលិចទល់នឹង … … ……………………………..។

៣-ឈ្មោះ…………………………………………… ដែលស្ថិតក្នុងភូមិ…………………………. ឃុំ សង្កាត់……………………………
មានព្រំប្រទល់ : ខាងជើងទល់នឹង……………………………………ខាងត្បូងទល់នឹង … … ……………………………..
ខាងកើតទល់នឹង……………………………………ខាងលិចទល់នឹង … … ……………………………..។

៤-ឈ្មោះ…………………………………………… ដែលស្ថិតក្នុងភូមិ…………………………. ឃុំ សង្កាត់……………………………
មានព្រំប្រទល់ : ខាងជើងទល់នឹង……………………………………ខាងត្បូងទល់នឹង … … ……………………………..
ខាងកើតទល់នឹង……………………………………ខាងលិចទល់នឹង … … ……………………………..។

ដែលនឹងត្រូវចុះអង្កេតវាស់វែងនៅថ្ងៃ…………………………………………………។

អាស្រ័យហេតុនេះ សូមអញ្ជើញសាមីអ្នកស្នើសុំចុះបញ្ជីដី អ្នកមានដីជាប់ព្រំ និងជនដែលមានការពាក់ព័ន្ធនឹងក្បាលដី ស្នើសុំចុះបញ្ជី ចូលមកបង្ហាញខ្លួននៅទីតាំងដីខាងលើ នៅថ្ងៃ………………………..វេលាម៉ោង……………………ដើម្បីបំពេញបែបបទតាមនីតិវិធីនៃការចុះបញ្ជីដីធ្លីជាធរមាន។ ក្នុងករណីអវត្តមានអាជ្ញាធរស្រុក ខណ្ឌ មិនទទួលខុសត្រូវចំពោះបញ្ហាផ្សេងៗដែលអាចកើតឡើងជាយថាហេតុឡើយ ។

ថ្ងៃ…………………………ខែ……………………ឆ្នាំ………………………..ព.ស២៥……

រាជធានីភ្នំពេញ ថ្ងៃទី………..ខែ……………ឆ្នាំ២០……

**អភិបាល នៃគណៈអភិបាលខណ្ឌ**

<u>សេចក្តីជូនដំណឹងនេះបិទនៅ</u>:
-រដ្ឋបាលខណ្ឌ…………………………………….. ១ច្បាប់
-សាលាសង្កាត់…………………………………. ១ច្បាប់
-ទីស្នាក់ការភូមិ (ទីកន្លែង)……………………….. ១ច្បាប់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌ :…………………….. ថ្ងៃ………………………….ខែ………………..ឆ្នាំ……………………..៣៥៦៤….
លេខ :………………………. រាជធានីភ្នំពេញ ថ្ងៃទី………ខែ…………ឆ្នាំ២០……

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

យោងតាមអនុក្រឹត្យលេខ៤៨ អនក្រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ និងយោងអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា ៩ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ រដ្ឋបាលខណ្ឌ………………………………… សូមជូនដំណឹងដល់សាធារណជន ពិសេសអ្នកកាន់កាប់ដី ព្រមទាំងតំណាងគ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធនឹងក្បាលដីចំនួន …………ស្ថិតនៅភូមិ……………… សង្កាត់…………………… ខណ្ឌ……………………….រាជធានីភ្នំពេញ ឱ្យបានជ្រាបថា: ដើម្បីអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ នឹងធ្វើការបិទផ្សាយជាសាធារណៈ នូវឯកសារទិន្នន័យនៃការវិនិច្ឆ័យ រួមមានផែនទីក្បាលដីគំនូសបង្ហាញទីតាំងក្បាលដី និងបញ្ជីឈ្មោះម្ចាស់ដី ដែលផ្ទុកនូវទិន្នន័យប្រមូលបានកន្លងមក នៅសាលាសង្កាត់ …………………. និងរដ្ឋបាលរាជធានីភ្នំពេញ។

អាស្រ័យហេតុនេះ សូមសាធារណៈជន អ្នកកាន់កាប់ដី ព្រមទាំងតំណាងគ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធនឹងក្បាលដីខាងលើ អញ្ជើញចូលរួមពិនិត្យទិន្នន័យក្នុងឯកសារ ដែលនឹង បិទផ្សាយដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬខុសឆ្គងដែលត្រូវកែតម្រូវ ឬជំទាស់តវ៉ា ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទី …………ខែ…………ឆ្នាំ២០……… ដល់ថ្ងៃទី…………ខែ…………ឆ្នាំ២០……… ជាកំហិត នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌ។

ផុតរយៈពេលកំណត់ខាងលើ បើគ្មានការជំទាស់តវ៉ា ឬសុំកែតម្រូវទេ នោះទិន្នន័យដែលបានបិទផ្សាយត្រូវបានសន្មត់ថា មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ និងមិនអាចជំទាស់តវ៉ា ឬសុំកែតម្រូវ នៅពេលក្រោយទៀតបានឡើយ ហើយសមត្ថកិច្ចជំនាញនឹងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃ ការវិនិច្ឆ័យ ជូនអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ពិនិត្យសម្រេចមុននឹងផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនម្ចាស់សំណើតាមការស្នើសុំ។

**អភិបាល នៃគណៈអភិបាលខណ្ឌ**……………………

ចម្លងជូន :
-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
-រដ្ឋបាលរាជធានីភ្នំពេញ
-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
-សាលាសង្កាត់
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតថ្លែងអំណរគុណ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។

យើងខ្ញុំជាប្រជាពលរដ្ឋរស់នៅភូមិ......[illegible]...... ឃុំ...[illegible]... ស្រុក...គិរីវង់......... ខេត្តតាកែវ ដែលមានការពាក់ព័ន្ធនឹងដី...[illegible]...................របស់យើងខ្ញុំ ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នៃព្រះរាជាណាចក្រកម្ពុជា** ដោយយើងខ្ញុំមានសេចក្តីរីករាយសប្បាយជាទីបំផុតរកអ្វីប្រៀបផ្ទឹមពុំបានឡើយ និងចងចាំអស់មួយជីវិតដែល **សម្តេចតេជោ** បានចាត់អោយ **ឯកឧត្តមជា សុផារ៉ា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ដឹកនាំដោះស្រាយវិវាទ និងបានផ្តល់យុត្តិធម៌ពិតប្រាកដដល់យើងខ្ញុំ ។ យើងខ្ញុំសូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយបីបាច់ថែរក្សា **សម្តេចតេជោ និងក្រុមគ្រួសារ** ជួបតែសេចក្តីសុខ សុភមង្គល និងជោគជ័យលើគ្រប់ភារកិច្ច ។

យើងខ្ញុំសូមប្តេជ្ញាបន្តគាំទ្រការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជារៀងរហូត ដើម្បីសុខសន្តិភាព ការអភិវឌ្ឍ និងជីវភាពរស់នៅរបស់យើងខ្ញុំ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដោយសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំទាំងអស់គ្នា ។

ធ្វើនៅ ថ្ងៃទី27 ខែ03 ឆ្នាំ2018

**ស្នាមមេដៃប្រជាពលរដ្ឋ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតថ្លែងអំណរគុណ

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ជាទីគោរពដ៏ខ្ពង់ខ្ពស់។

យើងខ្ញុំជាប្រជាពលរដ្ឋរស់នៅភូមិ.ទំព្រាធំ..... ឃុំ.ព្រះបាទជាន់ជុំ.ស្រុក.គីរីវង់..... ខេត្តតាកែវ ដែលមានការពាក់ព័ន្ធនឹងដី..គិរីភ្នំ.....របស់យើងខ្ញុំ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៃព្រះរាជាណាចក្រកម្ពុជា** ដោយយើងខ្ញុំមានសេចក្តីរំភើបសប្បាយជាទីបំផុត រកអ្វីប្រៀបផ្ទឹមពុំបានឡើយ និងចងចាំអស់មួយជីវិតដែល **សម្តេចតេជោ** បានចាត់អោយ **ឯកឧត្តម ជា សុផារ៉ា ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ដឹកនាំដោះស្រាយវិវាទ និងបានផ្តល់យុត្តិធម៌ពិតប្រាកដដល់យើងខ្ញុំ។ យើងខ្ញុំសូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តសិទ្ធិក្នុងលោកតាម ជួយបីបាច់ថែរក្សា **សម្តេចតេជោ និងក្រុមគ្រួសារ** ជួបតែសេចក្តីសុខ សុភមង្គល និងជោគជ័យលើគ្រប់ភារកិច្ច។

យើងខ្ញុំសូមប្តេជ្ញាបន្តគាំទ្រការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដោយសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំទាំងអស់គ្នា។

ធ្វើនៅគីរីវង់..ថ្ងៃទី.04.ខែ..05..ឆ្នាំ.2018

**ស្នាមមេដៃប្រជាពលរដ្ឋ**